## សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច

## Université Royale de Droit et des Sciences Economies

## Royal University of Law and Economics

# សារណាបញ្ចប់ការសិក្សា

# ការគ្រប់គ្រងរដ្ឋបាលសង្កាត់ចាក់អង្រែក្រោម

# ឆ្នាំ ២០១៧ ដល់ ២០២៣

ស្រាវជ្រាវពីថ្ងៃ០៨ ខែមេសា ឆ្នាំ២០២៤ ដល់ថ្ងៃ១០ ខែសីហា ឆ្នាំ២០២៤


ស្រាវជ្រាវដោយ

និស្សិតឈ្មោះ៖ កញ្ញា **សុខ ចន្ថា**

កញ្ញា **ម៉េង ជីឡាង**

ណែនាំដោយ

បណ្ឌិត **ឌឹត សំណាង**


ថ្នាក់បរិញ្ញាបត្រ **រដ្ឋបាលសាធារណៈ**

ជំនាន់ទី ១៧ (អាហារូបករណ៍)

ឆ្នាំចូលសិក្សា ២០២០

ឆ្នាំសរសេរណា ២០២៤

# សេចក្តីថ្លែងអំណរគុណ

នាងខ្ញុំទាំងពីររូបឈ្មោះ កញ្ញា **សុខ ចន្ថា** និង កញ្ញា **ម៉េង ជីឡាង** ជានិស្សិតថ្នាក់បរិញ្ញាបត្ររដ្ឋបាលសាធារណៈ ក្រុម P៤B០១ ជំនាន់ទី១៧ ( អាហារូបករណ៍ ) ឆ្នាំសិក្សា ២០២៣ ដល់ ២០២៤ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។

សូមគោរពដឹងគុណ និងថ្លែងអំណរគុណប្រកបដោយកតញ្ញូតាធម៌ជូនចំពោះ៖

_ លោកឪពុក និងអ្នកម្តាយ ដែលបានផ្តល់កំណើត និងខិតខំចិញ្ចឹមបីបាច់ថែរក្សាដោយពុំខ្លាចភាពនឿយហត់ព្រមទាំងទំនុកបម្រុងផ្តល់ឲ្យនូវផ្នែកថវិកា សម្ភារៈសិក្សា និងជាពិសេសនោះគឺការជួយគាំទ្រជ្រោមជ្រែងផ្តល់ឱកាសឲ្យកូនបានបន្តការសិក្សារៀនសូត្រតាំងពីថ្នាក់បឋមរហូតមកដល់ពេលបច្ចុប្បន្ននេះ។

_ ឯកឧត្តមសាស្ត្រាចារ្យបណ្ឌិត **លុយ ចន្ធ្នា** សាកលវិទ្យាធិការនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចថ្នាក់ដឹកនាំព្រមទាំងសាស្ត្រាចារ្យគ្រប់រូបដែលបានជួយអប់រំបង្ហាត់បង្រៀនផ្តល់នូវដំបូន្មានល្អៗផ្ទេរនូវចំណេះដឹងជម្រុញលើកទឹកចិត្តដល់និស្សិតគ្រប់រូបដោយពុំមានការរើសអើង និងរៀបចំកម្មវិធីសិក្សាតាមប្រកបដោយគុណភាព និងប្រសិទ្ធភាពខ្ពស់។

_ សាស្ត្រាចារ្យបណ្ឌិត **ឌីត សំណាង** ជាសាស្ត្រាចារ្យណែនាំដល់រូបនាងខ្ញុំទាំងពីរដែលលោកបានចំណាយពេលវេលាដ៏មានតម្លៃនៅក្នុងការបង្ហាត់បង្រៀន ជួយពន្យល់កែសម្រួល និងព្យាយាមរកនូវដំណោះស្រាយល្អៗដល់រូបនាងខ្ញុំទាំងពីរស្វែករកឯកសារត្រួតពិនិត្យវាយតម្លៃដើម្បីឈានទៅរកភាពត្រឹមត្រូវមួយដែលប្រកបទៅដោយស្តង់ដារ និងប្រសិទ្ធភាព។

_ លោក **ខា សុខៃ** ចៅសង្កាត់ចាក់អង្រែក្រោមដែលបានអនុញ្ញាតឲ្យនាងនាងខ្ញុំទាំងពីរបានចុះស្រាវជ្រាវស្វែងរកឯកសារទាក់ទងនឹងប្រធានបទ នៅសង្កាត់ចាក់អង្រែក្រោម។

_ លោក **ជឹម សុរិទ្ធិ** ជាសមាជិកក្រុមប្រឹក្សាសង្កាត់ចាក់អង្រែក្រោមដែលលោកបានលះបង់ពេលវេលាដ៏មានតម្លៃរបស់លោកក្នុងការជួយនាងខ្ញុំទាំងពីរក្នុងការឆ្លើយនូវសំណួរដែលនាងខ្ញុំបានសួរ និងលោកក៏បានស្វះស្វែងរកនូវឯកសារពាក់ព័ន្ធនានា យកមកពន្យល់ដល់រូបនាងខ្ញុំទាំងពីរដែលធ្វើឲ្យកិច្ចការមួយនេះដំណើរការទៅដោយរលូន និងប្រកបទៅដោយគុណភាព។

_ មិត្តៗរួមជំនាន់ទាំងអស់ដែលបានគាំទ្រ និងជំរុញលើកទឹកចិត្ត ផ្តល់ជាឯកសារនានា និងចែករំលែកនូវមេរៀនថ្មីៗក្នុងការជួយឲ្យនាងខ្ញុំទាំងពីររូបមានគំនិតកាន់តែច្រើនក្នុងការសរសេរប្រធានបទនេះ។

# **អារម្ភកថា**

នាងខ្ញុំទាំងពីររូបឈ្មោះ កញ្ញា **សុខ ចន្ថា** និង កញ្ញា **ម៉េង ជីឡាង** ជានិស្សិតថ្នាក់បរិញ្ញាបត្ររដ្ឋបាលសាធារណៈ ក្រុម P4B0១ ជំនាន់ទី១៧ (អាហារូបករណ៍) ឆ្នាំសិក្សា ២០២៣ ដល់ ២០២៤ យោងទៅតាមការសិក្សាផ្នែកទ្រឹស្តីនៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដោយក្រុមនាងខ្ញុំបានសម្រេចជ្រើសយកប្រធានបទស្តីពី «**ការគ្រប់គ្រងរដ្ឋបាលសង្កាត់ចាក់អង្រែក្រោម ចាប់ពីឆ្នាំ ២០១៧ ដល់ ២០២៣**» មកសរសេរសារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រក្រុមការដឹកនាំ និងណែនាំដោយសាស្ត្រាចារ្យបណ្ឌិត **ឌឹត សំណាង**។

សារណានេះពិតជាមានសារៈសំខាន់ខ្លាំងណាស់ចំពោះនិស្សិតសាមណនិស្សិតគ្រប់រូបដែលរៀនផ្នែករដ្ឋបាលសាធារណៈព្រោះប្រធានបទដែលនាងខ្ញុំទាំងពីរបានសរសេរនេះឆ្លុះបញ្ចាំងដោយផ្ទាល់ពីរបៀបនៃការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់បញ្ហាដែលបានកើតមានឡើង និងដំណោះស្រាយដើម្បីទប់ស្កាត់ក៏ដូចជាគោលដៅនៅថ្ងៃអនាគតរបស់រដ្ឋបាលឃុំ សង្កាត់ដែលជាភាពងាយស្រួលដល់និស្សិតផ្សេងៗក្នុងការស្រាវជ្រាវយល់ដឹងបន្ថែមពីការងាររដ្ឋបាលនៅឃុំ សង្កាត់។

នាងខ្ញុំទាំងពីររូបពិតជាមានសេចក្តីសោមនស្សរីករាយយ៉ាងក្រៃលែងក្នុងការចែករំលែកនូវចំណេះដឹងមួយនេះទៅកាន់អ្នកសិក្សាទាំងអស់ដើម្បីជាជំនួយបន្ថែមក្នុងការសិក្សារបស់ពួកគេឲ្យកាន់តែមានប្រសិទ្ធភាព និងមានគុណភាពទោះបីជានាងខ្ញុំទាំងពីរបានចំណាយនូវពេលវេលា ថវិកា និងលះបង់កម្លាំងកាយចិត្តក៏ដោយក៏ពួកយើងរីករាយនឹងចែករំលែកទៅកាន់និស្សិតជំនាន់ក្រោយ។

អាស្រ័យហេតុនេះនាងខ្ញុំទាំងពីររូបសូមខន្តី និងអភ័យទោសចំពោះចំណុចចន្លោះខ្វះខាត និងចំណុចខុសឆ្គងដោយអចេតនាពីសំណាក់លោកឯកត្តម សាស្ត្រាចារ្យ លោក លោកស្រី អ្នកនាង កញ្ញា និងប្រិយមិត្តអ្នកអានទាំងអស់ជាពិសេសនាងខ្ញុំទាំងពីររូបមានសេចក្តីរីករាយចំពោះការទទួលយកការរិះគន់នៅក្នុងន័យស្ថាបនាកែលម្អ និងបំពេញនូវការខ្វះខាតក្នុងអត្ថបទសារណានេះដើម្បីឲ្យខ្លឹមសារកាន់តែល្អអត្ថន័យត្រឹមត្រូវ និងសុក្រឹត្យថែមទៀត។

# មាតិកា

ទំព័រ

**សេចក្តីផ្តើម** ........ ១
១. លំនាំបញ្ហា ........ ១
២. ចំណោទបញ្ហា ........ ២
៣. គោលបំណងនៃការសិក្សាស្រាវជ្រាវ ........ ២
៤. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ ........ ២
៥. សារៈសំខាន់នៃការសិក្សាស្រាវជ្រាវ ........ ៣
៦. វិធីសាស្រ្តស្រាវជ្រាវ ........ ៤
៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ ........ ៤

## ជំពូកទី១
## សញ្ញាណទូទៅនៃការគ្រប់គ្រងរដ្ឋបាល

**១.១. ការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់** ........ ៥
១.១.១. ការគ្រប់គ្រងរដ្ឋបាល ........ ៥
១.១.២. វិមជ្ឈការ និងសហវិមជ្ឈការនៅកម្ពុជា ........ ៥
១.១.២.១. ចរន្តនៃអភិបាលកិច្ចមូលដ្ឋាន ........ ៥
១.១.២.២. វិមជ្ឈការ ........ ៦
១.១.២.៣. អត្ថន័យនៃវិមជ្ឈការ និងវិសហមជ្ឈការនៅកម្ពុជា ........ ៦
១.១.៣. ក្របខណ្ឌគោលនយោបាយសម្រាប់កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ........ ៧
១.១.៣.១. យុទ្ធសាស្រ្តចតុកោណដំណាក់កាលទី១ ទី២ និងទី៣ ........ ៧
១.១.៣.២. ក្របខ័ណ្ឌយុទ្ធសាស្រ្តស្តីពីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ........ ៨
១.១.៤. គោលការណ៍នៃការរៀបចំអភិបាលកិច្ចមូលដ្ឋាននៅកម្ពុជា ........ ៨
១.១.៥. ការរៀបចំប្រព័ន្ធអភិបាលកិច្ចមូលដ្ឋាននៅកម្ពុជា ........ ១៣
១.១.៥.១. ការរៀបចំប្រព័ន្ធរដ្ឋបាលនៅថ្នាក់ក្រោមជាតិ ........ ១៣

១.១.៥.២. ឋានៈផ្លូវច្បាប់នៃរដ្ឋបាលថ្នាក់ក្រោមជាតិ........................................................................១៥

១.១.៦. គោលបំណងនៃការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ............................................................ ១៦

**១.២. ការរៀបចំរដ្ឋបាលឃុំ សង្កាត់**............................................................................................ ១៧

១.២.១. ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់..............................................................១៧

១.២.២. រចនាសម្ព័ន្ធនៃរដ្ឋបាលឃុំ សង្កាត់......................................................................................... ១៨

១.២.៣. តួនាទី មុខងារ និងអំណាចរបស់រដ្ឋបាលឃុំ សង្កាត់.................................................... ១៩

**១.៣. កិច្ចប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់**............................................................................................២១

**១.៤. កិច្ចការរដ្ឋបាលឃុំ សង្កាត់**..................................................................................................២៣

១.៤.១. លិខិតបទដ្ឋានគតិយុត្ត.......................................................................................................២៣

១.៤.១.១. ដីកា ..............................................................................................................................២៣

១.៤.១.២. សេចក្តីសម្រេច ................................................................................................................ ២៤

១.៤.២. លិខិតរដ្ឋបាល..................................................................................................................... ២៤

១.៤.២.១. ប្រភេទលិខិតរដ្ឋបាល ........................................................................................................ ២៤

១.៤.២.២. ការងាររបៀប .................................................................................................................... ២៦

១.៤.២.៣. ការតាក់តែងលិខិត ........................................................................................................... ២៦

១.៤.២.៤. ការគ្រប់គ្រងឯកសារ .........................................................................................................២៧

១.៤.២.៥. ការគ្រប់គ្រងសម្ភារបរិក្ខារ.....................................................................................................២៧

**១.៥. ផែនការអភិវឌ្ឍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ សង្កាត់**.............................................២៧

១.៥.១. សនិទានភាព ....................................................................................................................... ២៨

១.៥.២. តួអង្គសំខាន់ៗ ...................................................................................................................... ២៩

១.៥.៣. គោលការណ៍ ......................................................................................................................៣០

**១.៦. ការគ្រប់គ្រងហិរញ្ញវត្ថុ និងលទ្ធកម្ម**...................................................................................៣១

១.៦.១. ប្រភពចំណូលរបស់ឃុំ សង្កាត់...........................................................................................៣១

១.៦.១.១. ចំណូលផ្ទាល់.......................................................................................................................៣១

១.៦.១.២. ចំណូលពីថ្នាក់ជាតិ ..... ៣១
១.៦.១.៣. មូលនិធិឃុំ សង្កាត់ ..... ៣២
១.៦.១.៤. ធនធានបន្ថែមពីថវិការដ្ឋសម្រាប់ចំណាយអភិវឌ្ឍន៍មូលដ្ឋាន ..... ៣៣
១.៦.២. ចំណូលពីការអនុវត្តមុខងារជាភ្នាក់ងារ ..... ៣៤
១.៦.៣. ប្រព័ន្ធទូទាត់ និងគណនេយ្យឃុំ សង្កាត់ ..... ៣៤
១.៦.៣.១. គោលការណ៍ទូទៅ ..... ៣៤
១.៦.៣.២. ប្រព័ន្ធទូទាត់ ..... ៣៥
១.៦.៤. ប្រព័ន្ធគណនេយ្យ ..... ៣៥
១.៦.៥. ថវិកាឃុំ សង្កាត់ ..... ៣៥
១.៦.៥.១. គោលការណ៍ថវិកាសំខាន់ៗនៃការរៀបចំគម្រោងថវិកាឃុំ សង្កាត់ ..... ៣៦
១.៦.៥.២. ការរៀបចំ និងការអនុម័តគម្រោងថវិកា ..... ៣៦
១.៦.៦. ការអនុវត្តថវិកាឃុំ សង្កាត់ ..... ៣៧
១.៦.៧. របាយការណ៍ហិរញ្ញវត្ថុឃុំ សង្កាត់ ..... ៣៨
១.៦.៨. ទ្រព្យសម្បត្តិឃុំ សង្កាត់ ..... ៣៩
១.៦.៩. កិច្ចលទ្ធកម្មឃុំ សង្កាត់ ..... ៤០
១.៦.៩.១. គោលការណ៍សំខាន់ៗនៃកិច្ចលទ្ធកម្ម ..... ៤០
១.៦.៩.២. សមាសភាពគណៈកម្មការលទ្ធកម្ម ..... ៤០
១.៦.៩.៣. សវនកម្មគណនី និងសវនកម្មប្រតិបត្តិការរបស់ឃុំ សង្កាត់ ..... ៤១
**១.៧. ការផ្តល់សេវាសាធារណៈ** ..... ៤១
១.៧.១. ប្រភេទនៃសេវាសាធារណៈ ..... ៤២
១.៧.២ គោលដៅ ..... ៤៦

# ជំពូកទី២
# ដំណើរការប្រព្រឹត្តទៅនៃការគ្រប់គ្រងរដ្ឋបាលសង្កាត់ចាក់អង្រែក្រោម


**២.១. ស្ថានភាពទូទៅ**.......... ៤៨
២.១.១. ទីតាំងភូមិសាស្ត្រ និងប្រជាសាស្ត្រ.......... ៤៨
២.១.២. ស្ថានភាពសេដ្ឋកិច្ច.......... ៤៩
២.១.៣. ស្ថានភាពសង្គមកិច្ច.......... ៤៩
**២.២. រចនាសម្ព័ន្ធសង្កាត់ចាក់អង្រែក្រោម**.......... ៤៩
២.២.១. ក្រុមប្រឹក្សា.......... ៤៩
២.២.១.១. អាណត្តិរបស់ក្រុមប្រឹក្សាឃុំ សង្កាត់.......... ៤៩
២.២.១.២. សមាសភាពក្រុមប្រឹក្សាសង្កាត់ចាក់អង្រែក្រោម.......... ៤៩
២.២.១.៣. លក្ខខណ្ឌនៃការឈរឈ្មោះ.......... ៥០
២.២.១.៤. ការងារត្រូវធ្វើក្រោយប្រកាសចូលកាន់តំណែង.......... ៥០
២.២.១.៥. ភារកិច្ចក្រុមប្រឹក្សាឃុំ សង្កាត់.......... ៥៦
២.២.១.៦. ការប្រជុំរបស់ក្រុមប្រឹក្សាឃុំ សង្កាត់.......... ៥៦
២.២.២. មេឃុំ ចៅសង្កាត់.......... ៥៧
២.២.២.១. លក្ខខណ្ឌនៃការជ្រើសរើសមេឃុំ ចៅសង្កាត់.......... ៥៧
២.២.២.២. តួនាទីភារកិច្ចមេឃុំ  សង្កាត់.......... ៥៧
២.២.២.៣. សមាសភាពចៅសង្កាត់ចាក់អង្រែក្រោម.......... ៥៧
២.២.៣. ជំទប់ ឬចៅសង្កាត់រង.......... ៥៨
២.២.៣.១. លក្ខខណ្ឌនៃការជ្រើសរើស.......... ៥៨
២.២.៣.២. តួនាទី និងភារកិច្ច.......... ៥៨
២.២.៣.៣. សមាសភាពជំទប់ទី១ និងជំទប់ទី២ សង្កាត់ចាក់អង្រែក្រោម.......... ៥៩
២.២.៤. ស្មៀនឃុំ សង្កាត់.......... ៥៩
២.២.៤.១. លក្ខខណ្ឌនៃការតែងតាំង.......... ៥៩

២.២.៤.២. តួនាទីភារកិច្ច ........ ៥៩
២.២.៥. មេភូមិ និងជំនួយការភូមិ ........ ៦០
២.២.៥.១. លក្ខខណ្ឌនៃការជ្រើសរើស ........ ៦០
២.២.៥.២. អាណត្តិការងារ ........ ៦០
២.២.៥.៣. តួនាទីភារកិច្ច ........ ៦១
**២.៣. ការគ្រប់គ្រងរដ្ឋបាលសង្កាត់ចាក់អង្រែក្រោម** ........ ៦៣
២.៣.១. ការងាររដ្ឋបាល ........ ៦៣
២.៣.២. ការគ្រប់គ្រងធនធានមនុស្ស ........ ៦៤
២.៣.៣. ការវិនិយោគបីឆ្នាំរំកិល ........ ៦៤
២.៣.៣.១. និយមន័យ ........ ៦៤
២.៣.៣.២. គោលការណ៍ ........ ៦៤
២.៣.៣.៣. យន្តការ និងភារកិច្ច ........ ៦៥
**២.៤. ការគ្រប់គ្រងហិរញ្ញវត្ថុសង្កាត់ចាក់អង្រែក្រោម** ........ ៦៧
២.៤.១. ការរៀបចំ និងអនុម័តថវិការសង្កាត់ ........ ៦៨
២.៤.២. ចំណូល និងចំណាយថវិកា ........ ៧០

## ជំពូកទី៣

## សមិទ្ធផល បញ្ហាប្រឈម និងដំណោះស្រាយ

**៣.១. ស្ថានភាពបច្ចុប្បន្ន និងបញ្ហាប្រឈម** ........ ៧២
៣.១.១. ស្ថានភាពសេដ្ឋកិច្ច ........ ៧២
៣.១.១.១. ការងារអាជីវកម្ម ........ ៧២
៣.១.១.២. ការងារសាធារណៈ ........ ៧២
៣.១.២. ផ្នែកសង្គមកិច្ច ........ ៧៣
៣.១.២.១. ការងារអប់រំ ........ ៧៣
៣.១.២.២. សុខាភិបាល ........ ៧៣

៣.១.២.៣. វប្បធម៌និងសាសនា ..... ៧៣
៣.១.២.៤. យេនឌ័រ ..... ៧៤
៣.១.៣. ផ្នែកធនធានធម្មជាតិនិងបរិស្ថាននិងការបន្សាំនឹងការប្រែប្រួលអាកាសធាតុ ..... ៧៤
៣.១.៣.១. ការគ្រប់គ្រងដីធ្លី ..... ៧៤
៣.១.៣.២. ការងារលូទឹក ..... ៧៤
៣.១.៣.៣. ការងារបរិស្ថាន ..... ៧៥
៣.១.៤. ផ្នែករដ្ឋបាល និងសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ ..... ៧៥
៣.១.៤.១. ផ្នែករដ្ឋបាល ..... ៧៥
៣.១.៤.២. ការងារសន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ ..... ៧៥
**៣.២. ដំណោះស្រាយ** ..... ៧៦
៣.២.១. ហេដ្ឋារចនាសម្ព័ន្ធ ..... ៧៦
៣.២.២. ការលើកម្ពស់គុណភាពវិស័យអប់រំ ..... ៧៦
៣.២.៣. ការរក្សាសន្តិសុខ និងសណ្តាប់ធ្នាប់ ..... ៧៦
**៣.៣. ទិសដៅអនាគត** ..... ៧៧
៣.៣.១. ការអភិវឌ្ឍផ្នែកហេដ្ឋារចនាសម្ព័ន្ធ ..... ៧៧
៣.៣.២. ពង្រឹងផ្នែកសណ្តាប់ធ្នាប់សាធារណៈ ..... ៧៧
៣.៣.៣. យន្តការសេវាសាធារណៈ ..... ៧៨
**សេចក្តីសន្និដ្ឋាន** ..... ៧៩
**អនុសាសន៍** ..... ៨០
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# សេចក្ដីផ្ដើម

# សេចក្តីផ្តើម

## ១. លំនាំបញ្ហា

ប្រទេសកម្ពុជាបានឆ្លងកាត់ការផ្លាស់ប្តូររបបនយោបាយជាច្រើន និងបានឆ្លងកាត់សង្គ្រាមស៊ីវិលជាច្រើនលើកច្រើនសារជាពិសេសនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យពីឆ្នាំ១៩៧៥ ដល់ដើមឆ្នាំ១៩៧៩ ដែលមានការកាត់ផ្តាច់គ្នាពីរបបមួយទៅរបបមួយទៀតទាំងឥរិយាបថទាំងរបៀបរបបធ្វើការងារ និងច្បាប់។ យ៉ាងណាមិញការស្រាវជ្រាវអំពីស្ថាប័នរដ្ឋបាលថ្នាក់ជាតិ និងស្ថាប័នរដ្ឋបាលថ្នាក់ក្រោមជាតិវាក៏បានឆ្លុះបញ្ចាំងឲ្យឃើញពីភាពខុសគ្នាលើរចនាសម្ព័ន្ធនៃការគ្រប់គ្រង និងវិធានការណ៍គ្រប់គ្រងក៏ដូចជាគោលដៅ និងគោលបំណងនៃការគ្រប់គ្រងស្ថាប័នរដ្ឋបាលនាពេលបច្ចុប្បន្ននេះ។ ដោយហេតុថារាជរដ្ឋាភិបាលបានធ្វើការកំណែទម្រង់យ៉ាងច្រើនជាបន្តបន្ទាប់ដើម្បីឆ្លើយតបតាមតម្រូវការរីកចម្រើននៃប្រទេសជាតិនិងពង្រឹងលទ្ធិប្រជាធិតេយ្យនៅមូលដ្ឋាន។ ក្នុងការគ្រប់គ្រងស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិនេះជាការអនុវត្តគោលនយោបាយនៅមូលដ្ឋាន និងគ្រប់គ្រងចាត់ចែងនឹងនៅកៀកជាប់ប្រជាពលរដ្ឋផ្ទាល់ដែលបានបម្រើផលប្រយោជន៍ទូទៅនឹងអនុវត្តការងារផ្សេងៗដើម្បីធ្វើការគ្រប់គ្រង និងផ្តល់សេវាសាធារណៈដល់ប្រជាពលរដ្ឋនៅមូលដ្ឋានឃុំ សង្កាត់នីមួយៗ។ ចំពោះក្រុមប្រឹក្សាឃុំ សង្កាត់គឺជាអាជ្ញាធរវិមជ្ឈការដែលត្រូវបានទទួលស្គាល់ថាជាតំណាងរបស់រដ្ឋមួយដែលមានទីតាំងនៅតាមមូលដ្ឋាននានាទូទាំងប្រទេស។ មិនតែប៉ុណ្ណោះក្រុមប្រឹក្សាឃុំ សង្កាត់គឺជាសេនាធិការរបស់រាជរដ្ឋាភិបាលរដ្ឋមានភាពស្និទ្ធស្នាលជាមួយអាជ្ញាធររបស់ខ្លួនថែមទៀតផង។

ទន្ទឹមនឹងនេះក្រុមប្រឹក្សាឃុំ សង្កាត់គឺជាអ្នកដែលយល់ច្បាស់អំពីតម្រូវការរបស់ប្រជាពលរដ្ឋជាងគេនឹងដឹងច្បាស់ថាត្រូវកសាងអ្វីខ្លះដែលជាកង្វះខាត ឬជួសជុលអ្វីនៅមូលដ្ឋានរបស់ខ្លួនដើម្បីបង្កភាពងាយស្រួលជូនដល់ប្រជាពលរដ្ឋ។ ដោយឡែកការគ្រប់គ្រងរដ្ឋបាលនៅសង្កាត់ចាក់អង្រែក្រោមនៅមិនទាន់មានដំណើរការរលូននោះទេព្រោះជាក់ស្តែងការគ្រប់គ្រងរដ្ឋបាលសង្កាត់នេះហាក់ដូចជាមិនទាន់បានឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋចង់បាននៅឡើយ។ យើងសង្កេតឃើញថាការគ្រប់គ្រងរដ្ឋបាលសង្កាត់ចាក់អង្រែក្រោមនៅមានបញ្ហារាំងស្ទះមួយចំនួនចំពោះកិច្ចដំណើរការនៃការអនុវត្ត។ ហេតុដូចនេះហើយបានជាក្រុមយើងខ្ញុំជាក្រុមសារណាបានសម្រេចចិត្តជារួមក្នុងការជ្រើសរើសយកនូវប្រធានបទអំពីការគ្រប់គ្រងរដ្ឋបាលសង្កាត់ចាក់អង្រែក្រោមដែលពាក់ព័ន្ធយ៉ាងសំខាន់ក្នុងកម្មវិធីសិក្សាបរិញ្ញាបត្ររដ្ឋបាលសាធារណៈនឹងបានលើកយកមកដើម្បីធ្វើការសរសេរ និងធ្វើបទបង្ហាញក្នុងការបញ្ចប់ការសិក្សា។

ដោយហេតុនេះហើយទើបក្រុមយើងខ្ញុំនិងធ្វើការសិក្សាស្រាវជ្រាវទៅលើកិច្ចការនៃការគ្រប់គ្រងរដ្ឋបាលរបស់សង្កាត់ចាក់អង្រែក្រោមដោយផ្ទាល់ ឬដោយប្រយោលថាតើមានដំណើរការប្រព្រឹត្តទៅយ៉ាងណា?

## ២. ចំណោទបញ្ហា

បើយោងទៅតាមលំនាំបញ្ហាយើងឃើញថាការគ្រប់គ្រងរដ្ឋបាលនៅសង្កាត់ចាក់អង្រែក្រោមមានការគ្រប់គ្រងរដ្ឋបាលការគ្រប់គ្រងធនធានមនុស្ស ការផ្តល់សេវាសាធារណៈ ការយកចិត្តទុកដាក់ក្នុងការអភិវឌ្ឍសង្កាត់មានការអភិវឌ្ឍឆាប់រហ័សបម្រើប្រជាពលរដ្ឋបានល្អប្រសើរតាមសេចក្តីត្រូវការលើកកម្ពស់ជីវភាពប្រជាពលរដ្ឋ និងជាពិសេសខាងសង្កាត់ក៏បានដោះស្រាយបញ្ហាប្រឈមដែលបានកើតមានទាន់ពេលវេលាជូនប្រជាពលរដ្ឋ។ ដូច្នេះហើយចំណុចសំខាន់នៅក្នុងការសិក្សាស្រាវជ្រាវទាក់ទងទៅនឹងប្រធានបទស្តីពីការគ្រប់គ្រងរដ្ឋបាលសង្កាត់ចាក់អង្រែក្រោមតាមបែបវិមជ្ឈការផ្តោតសំខាន់លើបញ្ហាដូចខាងក្រោម៖

- តើដំណើរការនៃការគ្រប់គ្រងរដ្ឋបាលសង្កាត់ចាក់អង្រែក្រោមប្រព្រឹត្តទៅយ៉ាងដូចម្តេច?
- តើដំណើរការនៃការគ្រប់គ្រងរដ្ឋបាលរបស់សង្កាត់ចាក់អង្រែក្រោមបានជួបប្រទះនូវបញ្ហាអ្វីខ្លះ?
- តើការអនុវត្តកន្លងមកទទួលបានលទ្ធផលបែបណាខ្លះហើយនៅសង្កាត់ចាក់អង្រែក្រោមនេះមានទិសដៅអនាគតបែបណា?

## ៣. គោលបំណងនៃការសិក្សាស្រាវជ្រាវ

ក្នុងការសិក្សាស្រាវជ្រាវទៅលើប្រធានបទនេះគឺយើងមានបំណងដើម្បីចងក្រងទុកជាឯកសារមួយដែលនឹងមានប្រយោជន៍សម្រាប់អ្នកសិក្សាជំនាន់ក្រោយឲ្យបានយល់ដឹងពីការប្រព្រឹត្តិទៅនៃការគ្រប់គ្រងរដ្ឋបាលតាមបែបវិមជ្ឈការនៅថ្នាក់ក្រោមជាតិនៃព្រះរាជាណាចក្រកម្ពុជា។

ការសិក្សាស្រាវជ្រាវលើប្រធានបទនេះផ្តោតសំខាន់ទៅលើចំណុចមួយចំនួនដូចខាងក្រោម ៖

- ស្វែងយល់អំពីការអនុវត្តការងារក្នុងដែនសមត្ថកិច្ចរបស់រដ្ឋបាលសង្កាត់
- សិក្សាស្វែងយល់អំពីដំណើរការគ្រប់គ្រង និងរចនាសម្ព័ន្ធរបស់រដ្ឋបាលសង្កាត់
- ស្វែងយល់ពីសមិទ្ធផលដែលបានសម្រេចវិធីសាស្ត្រក្នុងការដោះស្រាយបញ្ហាប្រឈមរួមទាំងការកំណត់ទិសដៅអនាគតរបស់រដ្ឋបាលសង្កាត់ចាក់អង្រែក្រោម

## ៤. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ

ចំពោះដែនកំណត់ និងទំហំនៃការស្រាវជ្រាវទៅលើប្រធានបទការគ្រប់គ្រងរដ្ឋបាលតាមបែបវិមជ្ឈការក្នុងសង្កាត់ចាក់អង្រែក្រោមខណ្ឌមានជ័យរាជធានីភ្នំពេញមានវិសាលភាពគ្របដណ្តប់តែទៅលើសកម្មភាពការងាររបស់រដ្ឋបាលសង្កាត់ចាក់អង្រែក្រោមដែលស្ថិតក្នុងរាជធានីភ្នំពេញដែលជាទីតាំងត្រូវចុះធ្វើការសិក្សាស្រាវជ្រាវ។ ការចុះស្រាវជ្រាវរកឯកសារបានប្រព្រឹត្តទៅអស់រយៈពេល១៤ថ្ងៃដោយយើងធ្វើការរាប់ចាប់ពីថ្ងៃទី២០ ឧសភា ឆ្នាំ២០២៤ ដល់ថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០២៤។ ការកំណត់នូវទំហំនៃការស្រាវជ្រាវបែបនេះគឺដើម្បីងាយស្រួលក្នុងការកំណត់វិធីសាស្ត្រនៃការស្រាវជ្រាវលើប្រធានបទ។

## ៥. សារៈសំខាន់នៃការសិក្សាស្រាវជ្រាវ

ជាទូទៅការសិក្សាស្រាវជ្រាវតែងតែមានគុណតម្លៃដល់អ្នកអាន និងអ្នកសិក្សាគ្រប់រូបលើប្រធានបទឬមុខជំនាញដែលខ្លួនជ្រើសរើសមានសារៈសំខាន់ក្នុងការសិក្សាស្រាវជ្រាវបានយល់ដឹងនិងចងចាំយ៉ាងច្បាស់កាន់តែលម្អិតលើប្រធានបទ។ បន្ទាប់មកវាបានផ្តល់សារៈប្រយោជន៍ជាច្រើនទៀតដល់អ្នកអាន និងអ្នកសិក្សាជំនាន់ក្រោយដែលបានសិក្សាអាននូវស្នាដៃស្រាវជ្រាវនេះ។

សារប្រយោជន៍ដោយផ្អែកលើចំណុចមួយចំនួនដូចខាងក្រោមៈ

❖ ប្រយោជន៍សម្រាប់ប្រជាពលរដ្ឋមូលដ្ឋាន និងរដ្ឋបាលសង្កាត់ចាក់អង្រែក្រោម
- ➢ យល់ដឹងពីរបៀបរៀបចំការងាររដ្ឋបាលក្នុងសង្កាត់ចាក់អង្រែក្រោម
- ➢ យល់ដឹងពីគម្រោងការអភិវឌ្ឍរបស់រដ្ឋបាលសង្កាត់ចាក់អង្រែក្រោម
- ➢ យល់ដឹងបន្ថែមពីការគ្រប់គ្រងរចនាសម្ព័ន្ធ តួនាទី និងភារកិច្ចរបស់រដ្ឋបាលសង្កាត់ចាក់អង្រែក្រោម
- ➢ យកចិត្តទុកដាក់របស់រដ្ឋបាលសង្កាត់ចាក់អង្រែក្រោមចំពោះប្រជាពលរដ្ឋមូលដ្ឋាន។

❖ ប្រយោជន៍សម្រាប់និស្សិត
- ➢ ស្របតាមទិសដៅរបស់សាកលវិទ្យាល័យក្នុងការបញ្ចប់ថ្នាក់បរិញ្ញាប័ត្របានដោយជោគជ័យ
- ➢ ស្វែងយល់អំពីដំណើរការយន្តការនៃការគ្រប់គ្រងរដ្ឋបាល និងអនុវត្តកិច្ចការរដ្ឋបាលសង្កាត់ចាក់អង្រែក្រោមនាពេលបច្ចុប្បន្ន
- ➢ យល់ដឹងពីយុទ្ធសាស្ត្រក្របខណ្ឌច្បាប់និងគោលនយោបាយក្នុងការបម្រើសេវាសាធារណៈនិងអភិបាលកិច្ចល្អជូនប្រជាពលរដ្ឋ។

❖ ប្រយោជន៍សម្រាប់សាកលវិទ្យាល័យសាធារណៈជន និងប្រទេសជាតិ
- ➢ សាកលវិទ្យាល័យទទួលបានឯកសារសម្រាប់តម្កល់ទុក
- ➢ និស្សិតអ្នកអាននិងសាធារណៈជនអាចស្វែងយល់បន្ថែមពីទ្រឹស្តីមួយចំនួនក្នុងការសិក្សាស្រាវជ្រាវ និងយល់ដឹងច្បាស់ពីការងាររដ្ឋបាលរបស់សង្កាត់
- ➢ សង្កាត់មានសណ្តាប់ធ្នាប់ល្អ និងមានសុវត្ថិភាពការអភិវឌ្ឍច្រើនដោយមានការខិតខំប្រឹងប្រែងរបស់សង្កាត់ចាក់អង្រែក្រោម
- ➢ បង្ហាញពីភាពស្មោះត្រង់របស់ថ្នាក់ដឹកនាំ និងការចូលរួមមិនអាចខ្វះបានពីប្រជាពលរដ្ឋនាំឲ្យមានការរីកលូតលាស់លឿនធ្វើឲ្យប្រទេសជាតិមានការរីកចម្រើន

➢ ការផ្ដល់សេវាសាធារណៈជូនប្រជាពលរដ្ឋបានល្អមានតម្លាភាពសន្តិភាពតាងនាមជាអ្នកដឹកនាំដោះស្រាយបញ្ហាផ្សេងៗជូនប្រជាពលរដ្ឋ។

## ៦. វិធីសាស្ត្រស្រាវជ្រាវ

ការប្រើប្រាស់វិធីសាស្ត្រស្រាវជ្រាវលើប្រធានបទនេះគឺធ្វើឡើងដោយប្រើទិន្នន័យពីរប្រភេទដូចខាងក្រោម៖

- **ទិន្នន័យបន្ទាប់បន្សំ៖** ជាទិន្នន័យដែលមានស្រាប់ដូចជាច្បាប់ លិខិតបទដ្ឋានគតិយុត្ត ឯកសារផ្ទាល់ពីរដ្ឋបាលសង្កាត់ចាក់អង្រែក្រោមឯកសារជាសៀវភៅដែលមានក្នុងបណ្ណាល័យ អ៊ីនធឺណេត និងGoogle ជាដើម។
- **ទិន្នន័យចម្បង៖** ជាការចុះទៅជួបសម្ភាសន៍ផ្ទាល់ជាមួយនិងក្រុមប្រឹក្សាសង្កាត់ ចៅសង្កាត់ សមាជិកក្រុមប្រឹក្សា ស្មៀន ព្រមទាំងបុគ្គលិកដែលកំពុងបំពេញការងារនៅសង្កាត់ចាក់អង្រែផ្ទាល់ផងដែរ។

## ៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

នៅក្នុងរចនាសម្ព័ន្ធនៃការស្រាវជ្រាវនេះបានធ្វើការបែងចែកជាបីជំពូកដែលរួមមានដូចជា៖

- សេចក្ដីផ្ដើម
- ជំពូកទី១៖ សញ្ញាណទូទៅនៃការគ្រប់គ្រងរដ្ឋបាល
- ជំពូកទី២៖ ដំណើរការប្រព្រឹត្តទៅនៃការគ្រប់គ្រងរដ្ឋបាលសង្កាត់ចាក់អង្រែក្រោម
- ជំពូកទី៣៖ សមិទ្ធផល បញ្ហាប្រឈម និងដំណោះស្រាយ
- សេចក្ដីសន្និដ្ឋាន
- អនុសាសន៍
- ឯកសារយោង
- ឧបសម្ព័ន្ធ។

# ជំពូកទី ១

# សញ្ញាណទូទៅនៃការគ្រប់គ្រងរដ្ឋបាល

# ជំពូកទី១

# សញ្ញាណទូទៅនៃការគ្រប់គ្រងរដ្ឋបាល

## ១.១. ការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់

### ១.១.១. ការគ្រប់គ្រងរដ្ឋបាល

ការគ្រប់គ្រងរដ្ឋទាមទារឲ្យមានការរៀបចំរដ្ឋបាលមួយច្បាស់លាស់ទៅតាមរបបនៃរដ្ឋនោះ។ គ្រប់រដ្ឋនីមួយៗនៅលើពិភពលោកយើងនេះ បានរៀបចំរដ្ឋបាលខុសៗគ្នាផងដែរ។ យើងដឹងថារដ្ឋបាលកណ្តាល រឺរដ្ឋបាលថ្នាក់ជាតិ គឺជាបណ្តុំនៃអាជ្ញាធរជាច្រើនរួមគ្នាដែលបង្កើតបានជាអំណាចមួយដែលមានឈ្មោះថា នីតិប្រតិបត្តិ។ រដ្ឋបាលកណ្តាលនេះមានតួនាទីបំពេញមុខងាររដ្ឋបាលនៅថ្នាក់ខ្ពស់បំផុតនិងស្ថិតក្រោមក្របខណ្ឌជាតិទាំងស្រុង ហើយអំណាចកណ្តាលគឺជាអ្នកមានសមត្ថកិច្ចដឹកនាំជាតិទាំងមូលដោយផ្ទាល់ រឺក៏តាមរយៈតំណាងនានារបស់រដ្ឋាភិបាលនៅថ្នាក់ក្រោមជាតិ។

ដើម្បីងាយស្រួលក្នុងការដឹកនាំ រឺគ្រប់គ្រងរដ្ឋគេបានបែងចែកប្រព័ន្ធគ្រប់គ្រងជាបីមានដូចជា៖ ប្រព័ន្ធគ្រប់គ្រងបែបមជ្ឈការ បែបវិសហមជ្ឈការ និងបែបវិមជ្ឈការ។

ដោយបច្ចុប្បន្ននេះប្រព័ន្ធរដ្ឋបាលនៅប្រទេសកម្ពុជាត្រូវបានគេកែទម្រង់ ដោយប្រើតែប្រព័ន្ធគ្រប់គ្រងបែបវិមជ្ឈការ និងសហវិមជ្ឈការ។

### ១.១.២. វិមជ្ឈការ និងសហវិមជ្ឈការនៅកម្ពុជា

#### ១.១.២.១. ចរន្តនៃអភិបាលកិច្ចមូលដ្ឋាន

ការធ្វើកំណែទម្រង់វិមជ្ឈការនៅកម្ពុជាពុំមែនជាយុទ្ធសាស្ត្រ ឬជាមធ្យោបាយពិសេសដោយឡែកសម្រាប់តែនៅកម្ពុជានោះឡើយ។ ចាប់តាំងពីចុងទសវត្សរ៍ទី៩០វិមជ្ឈការបានក្លាយជាប្រធានបទ និងជាមធ្យោបាយដ៏មានប្រជាប្រិយភាពដែលត្រូវបានយកទៅអនុវត្តនៅក្នុងការរៀបចំប្រព័ន្ធគ្រប់គ្រងនៅរដ្ឋបាលថ្នាក់ក្រោមជាតិនៅតាមបណ្តាប្រទេសនានាជាច្រើននៅលើពិភពលោករាប់ចាប់តាំងពីតំបន់អាស៊ីអឺរ៉ុប និងអាមេរិកជាដើម។

ទោះជាយ៉ាងនេះក្តីប្រទេសនីមួយៗអនុវត្តវិមជ្ឈការដោយមានមូលហេតុផ្សេងៗគ្នាផ្អែកទៅតាមកត្តានយោបាយភូមិសាស្ត្រ ប្រជាសាស្ត្រ សេដ្ឋកិច្ច វប្បធម៌ និងប្រពៃណីជាដើម។ នៅអឺរ៉ុបខាងកើតនិងអតីតសហភាពសូវៀត វិមជ្ឈការគឺជាផ្នែកមួយនៃការផ្លាស់ប្តូរនយោបាយ និងសេដ្ឋកិច្ចដែលកើតឡើងបន្ទាប់ពីការដួលរលំនៃការគ្រប់គ្រងតាមបែបមជ្ឈការយ៉ាងតឹងរ៉ឹងរបស់សហភាពសូវៀត។ នៅអាហ្វ្រិចខាងត្បូង និងស្រីលង្កា វិមជ្ឈការគឺជាយុទ្ធសាស្ត្រដើម្បីបន្ធូរបន្ថយបញ្ហាខ្វែងគំនិតគ្នាក៏ដូចជាជម្លោះក្នុងចំណោមជនជាតិ

ឬតំបន់។ យុទ្ធសាស្ត្រនេះក៏ត្រូវបានអនុវត្តនៅឥណ្ឌូនេស៊ីដោយសារឥណ្ឌូនេស៊ីជាប្រទេសពោរពេញទៅដោយប្រជុំកោះមានទំហំធំប្រជាជនច្រើន និងសំបូរទៅដោយជនជាតិផ្សេងៗ ។

ក្រៅពីមូលហេតុខាងលើជាទូទៅ វិមជ្ឈការត្រូវបានគេមើលឃើញថាជាមធ្យោបាយដ៏មានប្រសិទ្ធភាពក្នុងការដោះស្រាយបញ្ហាភាពក្រីក្រវិសមភាពយេនឌ័របញ្ហាបរិស្ថាន និងការលើកកម្ពស់ការថែទាំសុខភាពការអប់រំ និងការទទួលបានបច្ចេកវិទ្យា។ ទន្ទឹមនេះវិមជ្ឈការមិនត្រឹមតែជះឥទ្ធិពលដល់រដ្ឋាភិបាល និងការផ្តល់សេវាប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងជាលក្ខខណ្ឌចាំបាច់ក្នុងការទាក់ទាញអង្គការសហគមន៍អ្នកពាក់ព័ន្ធក្នុងវិស័យឯកជនដៃគូអភិវឌ្ឍន៍ និងប្រជាពលរដ្ឋថែមទៀតផង"។

**១.១.២.២. វិមជ្ឈការ**

ក្នុងក្របខ័ណ្ឌទូទៅវិមជ្ឈការត្រូវបានគេឲ្យនិយមន័យថាជាដំណើរការមួយដែលសិទ្ធិអំណាច និងការទទួលខុសត្រូវនៃមុខងារសាធារណៈត្រូវបានផ្ទេរពីរដ្ឋាភិបាលកណ្តាលទៅឲ្យរដ្ឋាភិបាលមូលដ្ឋាន។ វិមជ្ឈការមានទំនាក់ទំនងយ៉ាងជិតស្និទ្ធទៅនឹងគោលគំនិតស្តីពី **"Subsidiarity"** ដែលគោលគំនិតនេះបានកំណត់ថារាល់មុខងារត្រូវផ្ទេរទៅឲ្យថ្នាក់ទាបបំផុតណាដែលមានសមត្ថភាពអាចបំពេញមុខងារនោះបាន។ កម្មវិធីអភិវឌ្ឍន៍អង្គការសហប្រជាជាតិ (UNDP) បានឲ្យនិយមន័យនៃអភិបាលកិច្ចតាមបែបវិមជ្ឈការថាជាការរៀបចំឡើងវិញនូវសមត្ថកិច្ចដើម្បីឲ្យមានប្រព័ន្ធមួយដែលមានការសហការទទួលខុសត្រូវរវាងស្ថាប័នអភិបាលកិច្ចនៅថ្នាក់កណ្តាល ថ្នាក់តំបន់ និងថ្នាក់មូលដ្ឋានដោយឈរលើគោលការណ៍នៃ Subsidiarity ដែលកត្តានេះនឹងនាំមកនូវការលើកកម្ពស់គុណភាព និងប្រសិទ្ធភាពនៃប្រព័ន្ធអភិបាលកិច្ចដើរទន្ទឹមនឹងការកើនឡើងនូវសិទ្ធិអំណាច និងលទ្ធភាពនៅថ្នាក់ក្រោមជាតិ។

**១.១.២.៣. អត្ថន័យនៃវិមជ្ឈការ និងវិសហមជ្ឈការនៅកម្ពុជា**

នៅកម្ពុជាគោលបំណងជាយុទ្ធសាស្ត្រនៅក្នុងការអនុវត្តកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការត្រូវបានកំណត់នៅក្នុងក្របខ័ណ្ឌយុទ្ធសាស្ត្រស្តីពីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការដូចខាងក្រោម៖

- ដើម្បីពង្រឹង និងពង្រីកលទ្ធិប្រជាធិបតេយ្យសេរីពហុបក្សនៅកម្ពុជាឲ្យចាក់ឫសរឹងមាំចាប់ពីមូលដ្ឋានមក
- ដើម្បីជំរុញកិច្ចអភិវឌ្ឍន៍មូលដ្ឋាន និងការចូលរួមកាត់បន្ថយភាពក្រីក្រ។

ក្នុងបរិបទរបស់ប្រទេសកម្ពុជាពាក្យវិមជ្ឈការ និងវិសហមជ្ឈការត្រូវបានកំណត់និយមន័យដូចខាងក្រោម៖

**១.១.៣. ក្របខណ្ឌគោលនយោបាយសម្រាប់កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ**

❖ **វិមជ្ឈការ**គឺជាការដែលរាជរដ្ឋាភិបាលប្រគល់ឲ្យក្រុមប្រឹក្សានូវភាពជាម្ចាស់លើមុខងារសិទ្ធិអំណាច និងធនធានដើម្បីឆ្លើយតបទៅនឹងសេចក្តីត្រូវការរបស់មូលដ្ឋានហើយក្រុមប្រឹក្សាត្រូវមាន

គណនេយ្យភាពចំពោះប្រជាពលរដ្ឋនៅមូលដ្ឋានលើបញ្ហាទាំងនេះ។ ក្នុងន័យនេះរាល់កិច្ចការនានាដែលបានផ្ទេរមជ្ឈការទៅឲ្យក្រុមប្រឹក្សាក្រុមប្រឹក្សាមានឆន្ទានុសិទ្ធិពេញលេញក្នុងការ។

❖ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់

- ច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់
- ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- ច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សា ក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ។

ទន្ទឹមនឹងការដាក់ចេញនូវក្របខ័ណ្ឌគោលនយោបាយ និងក្របខ័ណ្ឌច្បាប់ខាងលើនេះរាជរដ្ឋាភិបាលកម្ពុជាក៏បានរៀបចំនូវកម្មវិធីជាតិរយៈពេល១០ឆ្នាំសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។ កម្មវិធីជាតិនេះគឺជាផែនទីបង្ហាញផ្លូវសម្រាប់ការអនុវត្តកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការដែលការអនុវត្តកម្មវិធីជាតិនេះត្រូវបានចែកចេញជាបីដំណាក់កាលតាមរយៈការរៀបចំឲ្យមានផែនការអនុវត្តន៍លម្អិតតាមដំណាក់កាលនីមួយៗ។ រហូតមកទល់ពេលនេះផែនការអនុវត្តន៍៣ឆ្នាំដំណាក់កាលទី១ (ផអ៣ទី១៖ ២០១១-២០១៤) និងដំណាក់កាលទី២ (ផអ៣ទី២៖ ២០១៥-២០១៧) បានបញ្ចប់ហើយបច្ចុប្បន្នកំពុងបន្តអនុវត្តផែនការអនុវត្តន៍៣ឆ្នាំដំណាក់កាលទី៣ (ផអ៣ទី៣) ដែលជាដំណាក់កាលចុងក្រោយនៃកម្មវិធីជាតិ។

**១.១.៣.១. យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី១ ទី២ និងទី៣**

ក្នុងការអនុវត្តកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជាសម្រាប់នីតិកាលទី៣ ទី៤ និងទី៥នៃរដ្ឋសភារាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញនូវយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី១ ទី២ និងទី៣។ នៅក្នុងឯកសារយុទ្ធសាស្ត្រទាំងបីអភិបាលកិច្ចល្អត្រូវបានចាត់ទុកជាស្នូលនៃយុទ្ធសាស្ត្រចតុកោណ និងជាបុរេលក្ខខណ្ឌដ៏សំខាន់សម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព សមធម៌ និងយុត្តិធម៌សង្គម។ ដើម្បីសម្រេចបាននូវគោលដៅនៃអភិបាលកិច្ចល្អរាជរដ្ឋាភិបាលកម្ពុជាបានផ្តោតការយកចិត្តទុកដាក់ធ្វើកំណែទម្រង់លើវិស័យចំនួនបួនរួមមាន៖

- ការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ
- កំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌
- កំណែទម្រង់រដ្ឋបាលសាធារណៈក្នុងនោះរួមទាំងកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការកំណែទម្រង់កងកម្លាំងប្រដាប់អាវុធ។

កំណែទម្រង់ទាំងបួននេះត្រូវបានពង្រឹងពង្រីក និងយកចិត្តទុកដាក់អនុវត្តកាន់តែស៊ីជម្រៅពីដំណាក់កាលមួយទៅដំណាក់កាលមួយ។ ជាពិសេសពាក់ព័ន្ធកំណែទម្រង់រដ្ឋបាលសាធារណៈរាជរដ្ឋាភិបាលកម្ពុជាបានចាត់

ទុកកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការជាកំណែទម្រង់ដ៏មានសារៈសំខាន់បំផុតក្នុងការលើកកម្ពស់គុណភាព និងប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋានប្រកបដោយគុណភាព មានការចូលរួម គណនេយ្យភាព សមធម៌ និងបរិយាប័ន្ន។

**១.១.៣.២. ក្របខ័ណ្ឌយុទ្ធសាស្ត្រស្តីពីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ**

ដើម្បីអនុវត្តយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី១ នៅក្នុងឆ្នាំ២០០៥រាជរដ្ឋាភិបាលកម្ពុជាបានអនុម័តនូវក្របខ័ណ្ឌយុទ្ធសាស្ត្រស្តីពីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការក្នុងគោលបំណងកំណត់អំពីៈ

- ចក្ខុវិស័យរបស់រាជរដ្ឋាភិបាលកម្ពុជាពាក់ព័ន្ធនឹងកំណែទម្រង់អភិបាលកិច្ចនៅថ្នាក់ក្រោមជាតិ
- គោលដៅនៃយុទ្ធសាស្ត្រជាតិក្នុងកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ
- វិសាលភាពនៃការអនុវត្តកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ
- របៀបរៀបចំរចនាសម្ព័ន្ធគ្រប់គ្រងនៅតាមរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ
- ការណែនាំដល់ការងារកំណែទម្រង់ទាំងអស់ ដែលមានផលប៉ះពាល់ដល់ប្រព័ន្ធ
- គ្រប់គ្រងនៅតាមរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ។

ក្របខ័ណ្ឌយុទ្ធសាស្ត្រនេះរៀបចំឡើងដោយឈរលើមូលដ្ឋាននៃមេរៀន និងបទពិសោធន៍ដែលទទួលបានពីការអនុវត្តកំណែទម្រង់នៅថ្នាក់ឃុំ សង្កាត់តាមរយៈច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ និងច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់នៅក្នុងឆ្នាំ២០០១។ ផ្អែកតាមក្របខ័ណ្ឌយុទ្ធសាស្ត្រនេះច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានីក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សា ស្រុក ក្រុមប្រឹក្សាខណ្ឌត្រូវបានរៀបចំ និងដាក់ឲ្យប្រើនៅក្នុងឆ្នាំ២០០៨។

ក្នុងការដាក់ឲ្យដំណើរការនូវរចនាសម្ព័ន្ធ និងប្រព័ន្ធគ្រប់គ្រងថ្មីនៅរដ្ឋបាលថ្នាក់ក្រោមជាតិផ្អែកតាមស្មារតីនៃច្បាប់រៀបចំអង្គការខាងលើបានតម្រូវឲ្យដាក់ចេញនូវព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស និងលិខិតបទដ្ឋានពាក់ព័ន្ធដទៃទៀតជាច្រើនដើម្បីធានាឲ្យប្រព័ន្ធអភិបាលកិច្ចមូលដ្ឋានអាចដំណើរការទៅបានប្រកបដោយភាពរលូនមានប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធិ។

**១.១.៤. គោលការណ៍នៃការរៀបចំអភិបាលកិច្ចមូលដ្ឋាននៅកម្ពុជា**

មាត្រា២នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ បានចែងថា "**រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌត្រូវគ្រប់គ្រងតាមគោលការណ៍នៃរដ្ឋបាលឯកភាពដើម្បីបង្កើត ជំរុញ និងធ្វើឲ្យមានចីរភាពដល់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យតាមរយៈនយោបាយវិម ជ្ឈការ និងវិសហមជ្ឈការ**"។ មាត្រានេះបានផ្តល់នូវគោលការណ៍សំខាន់០២ក្នុងការរៀបចំប្រព័ន្ធអភិបាលកិច្ចនៅរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។

ទីមួយគឺការរៀបចំរដ្ឋបាលឯកភាព និងទីពីរគឺការធានាបាននូវចីរភាពនៃការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ នៅថ្នាក់រដ្ឋបាលទាំងនេះរួមទាំងរដ្ឋបាលឃុំ សង្កាត់។

ការរៀបចំរដ្ឋបាលរាជធានីខេត្ត ក្រុង ស្រុក ខណ្ឌជារដ្ឋបាលឯកភាពមានន័យថាក្រុមប្រឹក្សានៃថ្នាក់រដ្ឋបាលទាំងនេះត្រូវម្ចាស់ការក្នុងការគ្រប់គ្រងចាត់ចែងមុខងារ និងធនធានដែលបានមកពីការផ្ទេរពីថ្នាក់ជាតិទៅឲ្យក្រុមប្រឹក្សា ឬបានមកពីប្រភពនៅមូលដ្ឋានឬប្រភពផ្សេងៗទៀត។ ស្របតាមគោលការណ៍នៃការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យហើយក្រុមប្រឹក្សានីមួយៗមានសមត្ថភាពសម្របសម្រួលប្រកបដោយប្រសិទ្ធភាពនូវសកម្មភាពនៃការផ្តល់សេវាកម្ម និងការអភិវឌ្ឍផ្សេងៗទៀតដែលមាននៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួនរួមទាំងការផ្តល់សេវាកម្ម និងការអភិវឌ្ឍដែលធ្វើឡើងដោយក្រសួង ស្ថាប័ននានារបស់រាជរដ្ឋាភិបាលសំដៅឆ្លើយតបសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋនៅមូលដ្ឋាន។ គោលការណ៍ដែលតម្រូវឲ្យរៀបចំរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌជារដ្ឋបាលឯកភាពគឺដោយសារមុនឆ្នាំ២០០៩ (មុនការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ) មុខងារធនធាន សមត្ថកិច្ច និងការទទួលខុសត្រូវនៅថ្នាក់រដ្ឋបាលទាំងនេះត្រូវគ្រប់គ្រងតាមខ្សែបណ្តោយតាមវិស័យនានាដែលប្រព័ន្ធគ្រប់គ្រងនេះតម្រូវឲ្យមន្ទីរអង្គភាពជំនាញនានាធ្វើគណនេយ្យភាពតាមឋានានុក្រមទៅក្រសួង ស្ថាប័នរបស់ខ្លួន។ ដោយឡែកគោលការណ៍នៃការរៀបចំរដ្ឋបាលឯកភាពគឺសំដៅធានាឲ្យមានការសម្របសម្រួលរវាងខ្សែបណ្តោយ (ក្រសួង ស្ថាប័ន មន្ទីរ អង្គភាពខ្សែបណ្តោយ) ជាមួយខ្សែទទឹង (ក្រុមប្រឹក្សាដែលជាប់ឆ្នោត និងគណៈអភិបាលដែលតែងតាំងដោយរាជរដ្ឋាភិបាល) ដើម្បីកែលម្អខ្សែគណនេយ្យភាពសំដៅរួមគ្នាឆ្លើយតបតម្រូវការជាអាទិភាពរបស់ប្រជាពលរដ្ឋនៅមូលដ្ឋាន។

ចំពោះការរៀបចំប្រព័ន្ធអភិបាលកិច្ចមូលដ្ឋានស្របតាមគោលការណ៍នៃការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យគឺជាការរៀបចំប្រព័ន្ធអភិបាលកិច្ចនៅរដ្ឋបាលថ្នាក់ក្រោមជាតិឲ្យមានលក្ខណៈឆ្លើយតបទៅនឹងសមាសធាតុទាំង៨នៃការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យដូចដែលបានកំណត់នៅក្នុងមាត្រា១២នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌក្នុងនោះរួមានៈ

- ភាពជាតំណាងសាធារណៈ
- ស្វ័យភាពរបស់មូលដ្ឋាន
- ការពិគ្រោះយោបល់ និងការចូលរួម
- ការឆ្លើយតប និងគណនេយ្យភាព
- ការលើកកម្ពស់គុណភាពជីវិតរបស់ប្រជាជននៅក្នុងមូលដ្ឋាន
- ការលើកស្ទួយសមធម៌
- តម្លាភាព និងសុចរិតភាព

- វិធានការប្រឆាំងអំពើពុករលួយ និងការរំលោភអំណាច។

ការដាក់បញ្ចូលក្នុងក្របខ័ណ្ឌច្បាប់នូវគោលការណ៍នៃការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ មិនសំដៅតែទៅលើរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌប៉ុណ្ណោះទេប៉ុន្តែគោលការណ៍នេះគ្របដណ្តប់ទាំងថ្នាក់ឃុំ សង្កាត់ផងដែរ។ នៅថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌមានក្រុមប្រឹក្សាដែលបានបង្កើតឡើងតាមការបោះឆ្នោតអសកល ដោយសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងមុខតំណែងជាអ្នកបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សានៅថ្នាក់រដ្ឋបាលទាំងរដ្ឋាភិបាលនៅរក្សាសិទ្ធិអំណាចក្នុងការតែងតាំងគណៈអភិបាលដើម្បីអនុវត្តសេចក្តីសម្រេចទាំងសេចក្តីសម្រេចខាងបញ្ញត្តិ និងសេចក្តីសម្រេចខាងប្រតិបត្តិរបស់ក្រុមប្រឹក្សានៅតាមថ្នាក់រដ្ឋបាលទាំងនេះ។ ប្រព័ន្ធនេះបានតម្រូវឲ្យរៀបចំឡើងវិញនូវខ្សែគណនេយ្យភាពផ្ទៃក្នុង (ក្រុមប្រឹក្សា និងគណៈអភិបាល) ខ្សែគណនេយ្យភាព និងទំនាក់ទំនងក្នុងចំណោមថ្នាក់រដ្ឋបាលនានានៅថ្នាក់ក្រោមជាតិ (ទំនាក់ទំនង និងគណនេយ្យភាពរវាងខេត្ត ស្រុក ក្រុង ឃុំ សង្កាត់ និងរវាងរាជធានី ខណ្ឌ សង្កាត់) ទំនាក់ទំនង និងគណនេយ្យភាពរវាងថ្នាក់រដ្ឋបាលនីមួយៗនៅថ្នាក់ក្រោមជាតិជាមួយប្រជាពលរដ្ឋ និងទំនាក់ទំនង និងគណនេយ្យភាពរវាងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។

ដូច្នេះគោលការណ៍ទាំង០៨ខាងលើគឺជាការកំណត់អំពីមូលដ្ឋានគ្រឹះដែលត្រូវដាក់បញ្ចូលទៅក្នុងកិច្ចដំណើរការអភិបាលកិច្ចនៅថ្នាក់ក្រោមជាតិតាមរយៈការរៀបចំរចនាសម្ព័ន្ធប្រព័ន្ធបែបបទនីតិវិធីបំពេញការងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិទំនាក់ទំនង និងគណនេយ្យភាពថ្មីដែលត្រូវបានរៀបចំឡើងដូចបានគូសបញ្ជាក់ខាងលើ។ ច្បាប់ និងលិខិតបទដ្ឋាននានាពាក់ព័ន្ធថ្នាក់ក្រោមជាតិដែលត្រូវរៀបចំឡើងត្រូវធានាឲ្យមានសង្គតិភាពជាមួយគោលការណ៍នៃការអភិវឌ្ឍតាមបែបប្រជាធិប តេយ្យនៅថ្នាក់ក្រោមជាតិ។ ខ្លឹមសារសំខាន់ៗនៃគោលការណ៍ទាំង០៨ មានដូចខាងក្រោម៖

**ទី១. ភាពជាតំណាងសាធារណៈ**

ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាគ្រប់ថ្នាក់នៅថ្នាក់ក្រោមជាតិតាមគោលការណ៍នៃការបោះឆ្នោតតាមបែបប្រជាធិបតេយ្យសេរី ពហុបក្សគឺជាការផ្តល់ភាពជាតំណាងសាធារណៈដល់ក្រុមប្រឹក្សាជាប់ឆ្នោតគ្រប់លំដាប់ថ្នាក់នៃរដ្ឋបាលថ្នាក់ក្រោមជាតិ។ ក្រុមប្រឹក្សានីមួយៗត្រូវធ្វើសកម្មភាពនានាក្នុងនាមផលប្រយោជន៍ និងសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋទាំងអស់ក្នុងមូលដ្ឋានរបស់ខ្លួនដោយមិនមានការរើសអើងខាងនយោបាយពណ៌សម្បុរ ជំនឿសាសនា ជនជាតិ និងទ្រព្យធននោះឡើយ។

**ទី២. ស្វ័យភាពរបស់មូលដ្ឋាន**

ស្វ័យភាពមូលដ្ឋានមានន័យថារដ្ឋបាលថ្នាក់ក្រោមជាតិមានសិទ្ធិធ្វើសេចក្តីសម្រេច និងអនុវត្តសេចក្តីសម្រេចរបស់ខ្លួនដើម្បីបម្រើផលប្រយោជន៍ និងសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋទាំងអស់នៅមូលដ្ឋានរបស់ខ្លួន។

**ទី៣. ការពិគ្រោះយោបល់ និងការចូលរួម**

ការពិគ្រោះយោបល់ និងការចូលរួមគឺជាកិច្ចដំណើរការដ៏សំខាន់សម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិស្វែងយល់អំពីបំណងប្រាថ្នា និងសេចក្តីត្រូវការរបស់សហគមន៍ផ្សេងៗគ្នាក្នុងមូលដ្ឋានរបស់ខ្លួនដើម្បីរដ្ឋបាលថ្នាក់ក្រោមជាតិដាក់បញ្ចូលនូវផលប្រយោជន៍ និងសេចក្តីត្រូវការដែលមានលក្ខណៈផ្សេងៗគ្នានៅមូលដ្ឋាន (ឧទាហរណ៍តម្រូវការរបស់ស្ត្រី កុមារ យុវជន មនុស្សចាស់ជរា ជនជាតិ ជនក្រីក្រ... ជាដើម) ទៅក្នុងផែនការអភិវឌ្ឍ និងកម្មវិធីវិនិយោគរបស់ខ្លួនសំដៅឆ្លើយតបបានកាន់តែប្រសើរទៅនឹងផលប្រយោជន៍ និងសេចក្តីត្រូវការជាក់ស្តែងរបស់ប្រជាពលរដ្ឋទាំងអស់នៅក្នុងមូលដ្ឋានរបស់ខ្លួន។

**ទី៤. ការឆ្លើយតប និងគណនេយ្យភាព**

ក្នុងនាមជាតំណាងប្រជាពលរដ្ឋក្រុមប្រឹក្សាត្រូវឆ្លើយតបចំពោះសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋរបស់ខ្លួនក្នុងការធ្វើគោលនយោបាយសេចក្តីសម្រេចចិត្តសកម្មភាព និងការបំពេញការងាររបស់ខ្លួនប្រកបដោយការទទួលខុសត្រូវនូវអ្វីដែលខ្លួនបានអនុវត្ត។ ក្រុមប្រឹក្សាក៏ទទួលខុសត្រូវផងដែរចំពោះរាជរដ្ឋាភិបាលក្នុងការប្រតិបត្តិតាមរដ្ឋធម្មនុញ្ញ និងច្បាប់នានា។

**ទី៥. ការលើកកម្ពស់គុណភាពជីវិតរបស់ប្រជាពលរដ្ឋនៅមូលដ្ឋាន**

ការលើកកម្ពស់គុណភាពជីវិតរបស់ប្រពលរដ្ឋនៅមូលដ្ឋានគឺជាកិច្ចខិតខំប្រឹងប្រែងដើម្បីបង្កើត និងធ្វើឲ្យមាននិរន្តរភាពនូវបរិយាកាសមួយប្រកបដោយសន្តិភាព សុវត្ថិភាព និងសុខុមាលភាពតាមរយៈការលើកកម្ពស់ការអភិវឌ្ឍសង្គម សេដ្ឋកិច្ច និងលើកកម្ពស់ផាសុកភាព និងគុណភាពជីវិតនៃប្រជាពលរដ្ឋក្នុងមូលដ្ឋាន។ តម្រូវការរបស់ប្រជាពលរដ្ឋមានលក្ខណៈផ្សេងៗគ្នាទៅតាមសហគមន៍ និងក្រុមប្រជាពលរដ្ឋដែលមានដូចជាយុវជន ស្ត្រី កុមារ ជនពិការ ចាស់ជរាជនជាតិដើមភាគតិចក្រុមជនក្រីក្រជាដើមហេតុនេះក្រុមប្រឹក្សាត្រូវខិតខំស្វែងយល់ឲ្យបានគ្រប់ជ្រុងជ្រោយពីតម្រូវការផ្សេងៗគ្នារបស់អ្នកទាំងនោះតាមរយៈការលើកកម្ពស់ការពិគ្រោះយោបល់ និងការចូលរួម។ ទន្ទឹមនេះក្រុមប្រឹក្សាត្រូវខិតខំប្រើប្រាស់ធនធានដ៏មានកម្រិតរបស់ខ្លួនឲ្យមានប្រសិទ្ធភាពដើម្បីឆ្លើយតបទៅនឹងតម្រូវការទាំងនោះ។

**ទី៦. ការលើកស្ទួយសមធម៌**

ជាគោលការណ៍ទន្ទឹមនឹងការលើកកម្ពស់ការឆ្លើយតបគណនេយ្យភាព និងការលើកកម្ពស់គុណភាពជីវិតរបស់ប្រជាពលរដ្ឋ រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗត្រូវខិតខំលើកស្ទួយសមធម៌សង្គមក្នុងមូលដ្ឋានរបស់ខ្លួនផងដែរ។

ការលើកស្ទួយសមធម៌សង្គមគឺជាកិច្ចដំណើរការដែលតម្រូវឲ្យរដ្ឋបាលថ្នាក់ក្រោមជាតិប្រឹងប្រែងធានាឲ្យមានការពិគ្រោះយោបល់ការចូលរួមកាន់តែស៊ីជម្រៅជាមួយក្រុមផ្សេងៗគ្នាដូចជាស្ត្រី កុមារក្រុមជនងាយរងគ្រោះសហគមន៍ក្រីក្រ ជនជាតិភាគតិច...។ល។ សំដៅធ្វើការផ្តល់សេវា និងការអភិវឌ្ឍឆ្លើយតបតម្រូវការចំពោះក្រុមជនទាំងនោះ។ ក្នុងន័យនេះការផ្តល់សេវា និងការអភិវឌ្ឍត្រូវតែផ្តោតការយកចិត្តទុកដាក់ជាចម្បងដល់ក្រុមជនខាងលើនេះដើម្បីឲ្យក្រុមជនទាំងនេះទទួលបាននូវឱកាសកាន់តែច្រើនអត្ថប្រយោជន៍កាន់តែច្រើនពីការផ្តល់សេវា និងការអភិវឌ្ឍក្នុងមូលដ្ឋានរបស់ខ្លួន។

**ទី៧. តម្លាភាព និងសុចរិតភាព**

តម្លាភាព និងសុចរិតភាពគឺជាគោលការណ៍ស្នូលនៃអភិបាលកិច្ចល្អ។ កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការតាមគោលការណ៍នៃការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិត្រូវធានារៀបចំស្ថាប័នរដ្ឋបាលថ្នាក់ក្រោមជាតិគ្រប់ថ្នាក់ជាស្ថាប័នប្រកបដោយតម្លាភាព និងមាន សុចរិតភាព។ ជាក្រឹត្យក្រម តម្លាភាព និងសុចរិតភាពមិនអាចកើតឡើងដោយឯកឯងបានឡើយ។ តម្លាភាព និងសុចរិតភាពទាមទារត្រូវរៀបចំឲ្យមានរចនាសម្ព័ន្ធប្រព័ន្ធ និងនីតិវិធីច្បាស់លាស់សម្រាប់ស្ថាប័ននីមួយៗហើយថ្នាក់ដឹកនាំនៃស្ថាប័ននោះត្រូវមានការប្តេជ្ញាចិត្តក្នុងការកសាងស្ថាប័នរបស់ខ្លួនប្រកបដោយតម្លាភាព និងមានសុចរិតភាព។ ក្នុងន័យនេះក្រុមប្រឹក្សាគណៈអភិបាលត្រូវមានការប្តេជ្ញាចិត្តកសាងរដ្ឋបាលរបស់ខ្លួនឲ្យក្លាយជារដ្ឋបាលដែលមានលក្ខណៈបើកចំហមានតម្លាភាពដោយត្រូវធានាឲ្យបានថាសមាជិកក្រុមប្រឹក្សាគ្រប់ៗរូបអភិបាល អភិបាលរង មន្ត្រី បុគ្គលិកទាំងអស់ត្រូវបំពេញការងារប្រកបដោយតម្លាភាព និងត្រូវប្រកាន់យកគោលការណ៍សុចរិតភាពក្នុងការបំពេញការងារការផ្តល់សេវា និងការអភិវឌ្ឍក្នុងមូលដ្ឋានរបស់ខ្លួន។ កិច្ចប្រជុំជាសាធារណៈរបស់ក្រុមប្រឹក្សាការប្រជុំគណៈអភិបាល ការកសាងរបៀបធ្វើការជាក្រុមក្នុងក្រុមប្រឹក្សា គណៈអភិបាល និងមន្ត្រីនៃរដ្ឋបាលរបស់ខ្លួនការរៀបចំ និងដាក់ឲ្យអនុវត្តប្រព័ន្ធត្រួតពិនិត្យការងារផ្ទៃក្នុងសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗការរៀបចំ និងដាក់ឲ្យអនុវត្តនូវប្រព័ន្ធសវនកម្មផ្ទៃក្នុង ផ្ទៃក្រៅ និងប្រព័ន្ធ នីតិវិធីនានាជាច្រើនដែលបានដាក់ឲ្យប្រើប្រាស់កន្លងមកនេះ គឺមានគោលបំណងគាំទ្រដល់ការលើកកម្ពស់តម្លាភាព និងសុចរិតភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។

**ទី៨. វិធានការប្រឆាំងអំពើពុករលួយ និងការរំលោភអំណាច**

ការប្រយុទ្ធប្រឆាំងអំពើពុករលួយ និងការរំលោភអំណាចគឺជាកាតព្វកិច្ចរបស់ស្ថាប័នសាធារណៈគ្រប់ថ្នាក់ ផ្នែកឯកជន សង្គមស៊ីវិល និងប្រជាពលរដ្ឋគ្រប់ៗរូប សំដៅកសាងសង្គមមួយប្រកបដោយភាពស្អាតស្អំ និងយុត្តិធម៌ដើម្បីធានាឲ្យមានការអភិវឌ្ឍសង្គមប្រកបដោយចីរភាព និងសមធម៌។

ព្រះរាជាណាចក្រកម្ពុជាបានដាក់ចេញនូវច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយនាខែមេសា ឆ្នាំ២០១០។ លើមូលដ្ឋាននៃច្បាប់នេះកម្ពុជាកំពុងចាត់វិធានការតាមគ្រប់រូបភាពដើម្បីប្រយុទ្ធប្រឆាំងអំពើពុករលួយក្នុងសង្គមទាំងមូល។

រដ្ឋបាលគ្រប់ថ្នាក់នៅថ្នាក់ក្រោមជាតិជារដ្ឋបាលដែលកើតចេញពីការបោះឆ្នោតត្រូវមានគណនេយ្យភាពដោយផ្ទាល់ចំពោះប្រជាពលរដ្ឋរបស់ខ្លួនហេតុនេះរដ្ឋបាលនីមួយៗត្រូវដាក់ចេញនូវវិធានការប្រកបដោយប្រសិទ្ធភាព និងមានភាពសក្តិសិទ្ធិក្នុងការប្រយុទ្ធប្រឆាំងអំពើពុករលួយតាមគ្រប់រូបភាពក្នុងស្ថាប័នរបស់ខ្លួន។ ទន្ទឹមនឹងការដាក់ចេញនូវវិធានប្រយុទ្ធប្រឆាំងអំពើពុករលួយនៅក្នុងស្ថាប័នរបស់ខ្លួនរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗក៏ត្រូវសហការចូលរួមក្នុងការប្រយុទ្ធប្រឆាំងអំពើពុករលួយដែលកើតមានឡើងក្នុងដែនសមត្ថកិច្ចរបស់ខ្លួនផងដែរ។ វិធានការទាំងនេះត្រូវធានាឲ្យមានការចូលរួមពីផ្នែកឯកជនសង្គមស៊ីវិល និងប្រជាពលរដ្ឋទាំងមូលផងដែរ។ ទន្ទឹមនេះរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗក៏ត្រូវចាត់វិធានការចំពោះសកម្មភាពរំលោភអំណាចដែលកើតមានក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។ មាត្រា៤៨នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌបានគូសបញ្ជាក់យ៉ាងច្បាស់អំពីនិយមន័យ និងសកម្មភាពនានាដែលកំណត់ថាជាការរំលោភអំណាចហើយច្បាប់ក៏បានចង្អុលបង្ហាញនូវវិធានសម្រាប់ដោះស្រាយក្នុងករណីមានសកម្មភាពរំលោភអំណាចកើតមានក្នុងដែនសមត្ថកិច្ចរបស់ខ្លួនផងដែរ។[១]

សរុបមកវិញគោលការណ៍ទាំង០៨នេះមានទំនាក់ទំនងផ្សារភ្ជាប់គ្នា និងជះឥទ្ធិពលឲ្យគ្នាទៅវិញទៅមក។ ភាពទន់ខ្សោយក្នុងការអនុវត្តសមាសធាតុណាមួយ ឬមួយចំនួន ឬការខកខានមិនបានដាក់បញ្ចូលនូវសមាសធាតុណាមួយ ឬមួយចំនួនក្នុងកិច្ចដំណើរការនៃកំណែទម្រង់នឹងជះឥទ្ធិពលមិនល្អដល់សមាសធាតុផ្សេងៗទៀតហើយធ្វើឲ្យប៉ះពាល់ដល់ចីរភាពនៃដំណើរការកំណែទម្រង់ទាំងមូល។

### ១.១.៥. ការរៀបចំប្រព័ន្ធអភិបាលកិច្ចមូលដ្ឋាននៅកម្ពុជា

#### ១.១.៥.១. ការរៀបចំប្រព័ន្ធរដ្ឋបាលនៅថ្នាក់ក្រោមជាតិ

ក្រោយការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ ក្រុមប្រឹក្សាសង្កាត់ និងក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ នៅក្នុងឆ្នាំ២០០២ និងឆ្នាំ២០០៩ រចនាសម្ព័ន្ធ និងប្រព័ន្ធ

១ ប្រព័ន្ធគ្រប់គ្រងរដ្ឋបាលនៅថ្នាក់ក្រោមជាតិ

គ្រប់គ្រងនៅរដ្ឋបាលឃុំ សង្កាត់ និងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌត្រូវបានរៀបចំឡើងវិញស្របតាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ និងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។

បច្ចុប្បន្ន ប្រព័ន្ធរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានចែកចេញជាពីរប្រភេទគឺៈ

- **ប្រព័ន្ធរដ្ឋបាលខេត្ត** ដែលមានចរិតលក្ខណៈជារដ្ឋបាលតំបន់
- **ប្រព័ន្ធរដ្ឋបាលមូលដ្ឋាន** ដែលរួមមាន ប្រព័ន្ធ០២ថ្នាក់ និងប្រព័ន្ធ០៣ថ្នាក់
  - ប្រព័ន្ធ០២ថ្នាក់ៈ ស្រុក-ឃុំ និងក្រុង-សង្កាត់
  - ប្រព័ន្ធ០៣ថ្នាក់ៈ រាជធានី-ខណ្ឌ-សង្កាត់

តើរដ្ឋបាលខេត្ត និងរដ្ឋបាលមូលដ្ឋានមានលក្ខណៈខុសគ្នាដូចម្តេច?

រដ្ឋបាលខេត្ត ប្រទេសភាគច្រើនហៅថា **"រដ្ឋបាលតំបន់"** មានមុខងារសំខាន់ៗ០៣ គឺៈ

១.អនុវត្តមុខងារជាតំណាងរាជរដ្ឋាភិបាលតំណាងក្រសួង ស្ថាប័ននៅថ្នាក់ជាតិក្នុងការគាំទ្រ និងសម្របសម្រួលរដ្ឋបាលមូលដ្ឋានក្នុងដែនដីរបស់ខ្លួនទាំងរដ្ឋបាលទីប្រជុំជន(ក្រុង) និងជនបទ (ស្រុក ឃុំ និងសង្កាត់ក្នុងស្រុក)។ (តាមប្រព័ន្ធវិសហមជ្ឈការ)

២.អនុវត្តមុខងាររបស់ថ្នាក់ជាតិដែលថ្នាក់ជាតិធ្វើប្រតិភូកម្មពិសេសមុខងារពាក់ព័ន្ធសន្តិសុខសណ្តាប់ធ្នាប់សាធារណៈច្បាប់ យុត្តិធម៌សង្គម ឬមុខងារពាក់ព័ន្ធការអភិវឌ្ឍ ការផ្តល់ សេវាសង្គមដែលថ្នាក់ជាតិមិនទាន់ប្រគល់ឲ្យពេញលេញ។ (តាមប្រព័ន្ធវិសហមជ្ឈការ)

៣.អនុវត្តមុខងារក្នុងការផ្តល់សេវា និងការអភិវឌ្ឍដែលមានផលប៉ះពាល់ក្នុងក្របខ័ណ្ឌខេត្តទាំងមូលហើយដែលមិនអាចរ៉ាប់រងអនុវត្តបានដោយរដ្ឋបាលមូលដ្ឋាន។ (**តាមប្រព័ន្ធវិមជ្ឈការ**)

រដ្ឋបាលមូលដ្ឋាន គឺជារដ្ឋបាលដែលនៅកៀក ឬនៅជាប់ផ្ទាល់ជាមួយប្រជាពលរដ្ឋដែលមាន លទ្ធភាពសមត្ថភាពក្នុងការផ្តល់សេវា និងការអភិវឌ្ឍបានឆាប់រហ័សជាងថ្នាក់ជាតិមានប្រសិទ្ធភាពនិងមានភាពឆ្លើយតបជាងថ្នាក់ជាតិចំពោះសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋតាមមូលដ្ឋានខុសៗគ្នា។ ជាគោលការណ៍ និងជាបទពិសោធន៍អន្តរជាតិ ថ្នាក់ជាតិតែងតែផ្ទេរមុខងារ ទាំងមុខងារតាមប្រព័ន្ធ វិមជ្ឈការ(ការប្រគល់) និងមុខងារតាមប្រព័ន្ធវិសហមជ្ឈការ(ការធ្វើប្រតិភូកម្ម) កាន់តែច្រើនឡើងៗឲ្យទៅរដ្ឋបាលមូលដ្ឋានដើម្បីបង្កិតសេវា និងការអភិវឌ្ឍឲ្យកៀកជិតនឹងប្រជាជនពីព្រោះតម្រូវការក្នុងជីវភាពប្រចាំថ្ងៃរបស់ប្រជាជនមានការកើនឡើងជារៀងរាល់ថ្ងៃ។

ទន្ទឹមនេះការរៀបចំឡើងវិញនេះគឺជាតម្រូវការចាំបាច់ក្នុងការរៀបចំឲ្យមានប្រព័ន្ធអភិបាលកិច្ចសម្រាប់តំបន់ទីប្រជុំជន និងតំបន់ជនបទដែលតម្រូវឲ្យមានការកំណត់មុខងារក្នុងការផ្តល់សេវា និងការអភិវឌ្ឍរវាងទីក្រុង និងជនបទ មិនដូចគ្នាឡើយ។

ចំនួនក្រសួង ស្ថាប័ននៅថ្នាក់ជាតិ និងចំនួនរដ្ឋបាលនៅរដ្ឋបាលថ្នាក់ក្រោមជាតិមានដូចខាងក្រោម៖




ចាប់ពីឆ្នាំ១៩៩០ អត្រានៃនគរូបនីយកម្ម (ទីក្រុង/ទីប្រជុំជន) មានការកើនឡើងយ៉ាងខ្លាំង។ មានការធ្វើចំណាត់ថ្នាក់នគរូបនីយកម្មចំនួន០២លើក (នៅឆ្នាំ២០០៤ និងនៅឆ្នាំ២០១១) ដោយក្រសួងផែនការ។ ចំណាត់ថ្នាក់ចុងក្រោយបង្អស់បានរកឃើញថាប្រជាជនរស់នៅតំបន់ទីប្រជុំជនបានកើនឡើងពី១៩,៥% ដល់ ២៧%។

បើយើងពិនិត្យមើលដង់ស៊ីតេរបស់ប្រជាពលរដ្ឋដែលរស់នៅតាមប្រភេទនៃរដ្ឋបាលនីមួយៗ យើងសង្កេតឃើញថាមានភាពខុសគ្នាខ្លាំងរវាងតំបន់ទីប្រជុំជន និងតំបន់ជនបទ។ ប្រជាពលរដ្ឋភាគច្រើនបានប្រមូលផ្តុំមករស់នៅរាជធានីភ្នំពេញដែលធ្វើឲ្យដង់ស៊ីតេប្រជាពលរដ្ឋនៅរាជធានីភ្នំពេញកើនឡើងជាច្រើនដងបើប្រៀបធៀបទៅនឹងដង់ស៊ីតេប្រជាពលរដ្ឋនៅតាមខេត្ត។ ដោយឡែកដង់ស៊ីតេមធ្យមរវាងក្រុង និងស្រុកខុសគ្នាប្រមាណ០២ដង។ ខាងក្រោមនេះជាតួលេខមធ្យមភាគដែលឆ្លុះបញ្ចាំងអំពីលក្ខណៈភូមិសាស្ត្រ និងប្រជាសាស្ត្រនៃដែនដីរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ។

**១.១.៥.២. ឋានៈផ្លូវច្បាប់នៃរដ្ឋបាលថ្នាក់ក្រោមជាតិ**

មាត្រា៩ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងមាត្រា២ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ បានកំណត់ឲ្យរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់គឺជានីតិបុគ្គលនៃនីតិសាធារណៈ។ នីតិបុគ្គលនីមួយៗ រួមមានដែនដី និងប្រជាពលរដ្ឋនៅក្នុងដែនដីនោះ និងមានក្រុមប្រឹក្សាមួយជាតំណាងដែលកើតឡើងពីការបោះឆ្នោតជ្រើសរើសស្របតាមច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា

រាជធានីក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក និងក្រុមប្រឹក្សាខណ្ឌ និងច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់។[២]

ការផ្តល់ភាពជានីតិបុគ្គលចំពោះរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់គឺក្នុងគោលបំណងផ្តល់សិទ្ធិអំណាចមុខងារ ធនធាន និងទ្រព្យសម្បត្តិឲ្យដល់ក្រុមប្រឹក្សាដើម្បីក្រុមប្រឹក្សាអាចគ្រប់គ្រងចាត់ចែងកិច្ចការនានានៅមូលដ្ឋានសំដៅឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋដែលជាម្ចាស់ឆ្នោត និងអភិវឌ្ឍមូលដ្ឋានប្រកបដោយចីរភាព ប្រសិទ្ធភាព សមធម៌ និងបរិយាប័ន្ន។

### ១.១.៦. គោលបំណងនៃការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់

គោលបំណងនៃការគ្រប់គ្រងឃុំ សង្កាត់គឺ៖

- ផ្តល់ឱកាសដល់ប្រជាពលរដ្ឋឲ្យចូលរួមកាន់តែទូលំទូលាយនៅក្នុងការធ្វើសេចក្តីសម្រេចចិត្តដែលមានផលប៉ះពាល់ទៅលើជីវភាពរស់នៅ និងអនាគតរបស់ខ្លួន
- លើកកម្ពស់លទ្ធិប្រជាធិបតេយ្យ អភិបាលកិច្ច និងគុណភាពនៃជីវភាពរស់នៅ
- ធានាការអភិវឌ្ឍប្រកបដោយចីរភាព
- ផ្តល់ឱកាសដល់ប្រជាពលរដ្ឋឲ្យចូលរួមកាន់តែទូលំទូលាយនៅក្នុងការធ្វើសេចក្តីសម្រេចចិត្តដែលមានផលប៉ះពាល់ទៅលើជីវភាពរស់នៅ និងអនាគតរបស់ខ្លួន។[៣]

តាមរយៈប្រព័ន្ធអភិបាលមូលដ្ឋាននៅថ្នាក់ឃុំ សង្កាត់ ប្រជាពលរដ្ឋគ្រប់រូប (ស្ត្រី បុរស ចាស់ ក្មេង ជនងាយរងគ្រោះ) មានសិទ្ធិចូលរួមយ៉ាងសកម្មនៅក្នុងសកម្មភាពរបស់ឃុំ សង្កាត់ និងដំណើរការនៃការអភិវឌ្ឍមូលដ្ឋានដូចជាការបញ្ចេញមតិ និងការរួមចំណែកតាមមធ្យោបាយផ្សេងៗ។ ប្រជាពលរដ្ឋមានសិទ្ធិលើកឡើងអំពីសេចក្តីត្រូវការ និងផលប្រយោជន៍របស់ខ្លួនតាមរយៈនីតិវិធី និងយន្តការដែលបានកំណត់ក្នុងលិខិតបទដ្ឋាន និងសេចក្តីណែនាំនានា។

ការលើកកម្ពស់ការចូលរួមរបស់ប្រជាពលរដ្ឋ គឺជាភារកិច្ចយ៉ាងសំខាន់របស់ក្រុមប្រឹក្សាឃុំ សង្កាត់។ ការចូលរួមនេះជួយឲ្យក្រុមប្រឹក្សាឃុំ សង្កាត់ស្វែងយល់ពីសេចក្តីត្រូវការ និងផលប្រយោជន៍របស់ប្រជាពលរដ្ឋ ហើយបង្កើតកម្មវិធីដើម្បីដោះស្រាយសេចក្តីត្រូវការទាំងនោះ។ ប្រសិនបើប្រជាពលរដ្ឋបានចូលរួមប្រជាពលរដ្ឋមានអារម្មណ៍ថានឹងមានការទទួលខុសត្រូវចំពោះការអភិវឌ្ឍនៅក្នុងមូលដ្ឋានរបស់ខ្លួន។

- ការលើកកម្ពស់លទ្ធិប្រជាធិបតេយ្យអភិបាលកិច្ចល្អ និងគុណភាពនៃជីវភាពរស់នៅ

[២] មាត្រា៩ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់

[៣] សៀវភៅណែនាំស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ២០២២

- វិមជ្ឈការត្រូវបានចាត់ទុកថាជាមធ្យោបាយដ៏មានប្រសិទ្ធភាពក្នុងការជំរុញអភិបាលកិច្ចល្អ។ អភិបាលកិច្ចល្អគឺជាការអនុវត្តការងារឲ្យបានសមស្របទៅនឹងទិដ្ឋភាពសំខាន់ៗមួយចំនួនដូចខាងក្រោម៖
    - ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវបំពេញការងារដោយអនុលោមតាមច្បាប់ និងលិខិតបទដ្ឋាននានា
    - ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវបោះឆ្នោតជ្រើសរើសឡើងដោយប្រជាពលរដ្ឋរបស់ខ្លួនតាមបែបលទ្ធិប្រជាធិបតេយ្យ។ ដូច្នេះអ្វីដែលក្រុមប្រឹក្សាឃុំ សង្កាត់បានសម្រេច និងអនុវត្តគឺត្រូវទទួលខុសត្រូវ យ៉ាងពេញលេញចំពោះប្រជាពលរដ្ឋរបស់ខ្លួន។ នេះមានន័យថាក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវ៖
        - ធ្វើផែនការឲ្យឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋ
        - ផ្តល់ព័ត៌មានពីរបៀបប្រើប្រាស់ធនធានដែលខ្លួនមាន
        - ធានាថាធនធានទាំងនោះពិតជាត្រូវបានប្រើប្រាស់ដើម្បីបម្រើឲ្យផលប្រយោជន៍របស់ប្រជាពលរដ្ឋប្រកបដោយតម្លាភាព និងគណនេយ្យភាព។
- ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវមានតម្លាភាពនៅក្នុងការងារទាំងអស់ដែលខ្លួនបានបំពេញ។ ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវជម្រាបជូនសាធារណជនពីកិច្ចការនានា ដែលខ្លួនបានពិភាក្សា ឬពីសេចក្តីសម្រេចដែលខ្លួនបានធ្វើ ដូចជាការផ្សព្វផ្សាយដល់សាធារណជន និងការទទួលមតិយោបល់របស់សាធារណជនអំពីការកសាងផែនការអភិវឌ្ឍ និងការរៀបចំថវិកាឃុំ សង្កាត់ការផ្សព្វផ្សាយជាសាធារណៈអំពីសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់តាមរយៈការបិទផ្សាយនៅលើក្តារខៀនព័ត៌មានឃុំ សង្កាត់ឬតាមមធ្យោបាយផ្សេងៗទៀតនៅមូលដ្ឋាន
- ការចូលរួមរបស់ប្រជាពលរដ្ឋគឺជាសមាសធាតុយ៉ាងសំខាន់មួយទៀតនៅក្នុងអភិបាលកិច្ចល្អ។

## ១.២. ការរៀបចំរដ្ឋបាលឃុំ សង្កាត់

### ១.២.១. ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់

ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់គឺជាការបោះឆ្នោតសកល (បោះដោយផ្ទាល់ពីប្រជាពលរដ្ឋដែលមានសិទ្ធិ ១៨ឆ្នាំឡើងទៅ) សម្រាប់ការជ្រើសរើសតំណាងប្រជាពលរដ្ឋនៅតាមមូលដ្ឋានគឺឃុំ-សង្កាត់ ។ ជាទូទៅនៅប្រទេសកម្ពុជាការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់មានអាណត្តិ៥ឆ្នាំម្តង។[៤] គណបក្សដែលទទួលបានអាសនៈឬការគាំទ្រច្រើនជាងគេនឹងទទួលបានការដឹកនាំ ឬជាមេឃុំ-ចៅសង្កាត់ គណបក្សឈ្នះ

[៤] មាត្រា៣ ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់

បន្ទាប់នឹងទទួលបានតួនាទីជាជំទប់ ឬចៅសង្កាត់រង ទី១ និងទី២។ ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់នៅក្នុងប្រទេសកម្ពុជាចាប់ផ្តើមឡើងដំបូងនៅឆ្នាំ២០០២។

ការបង្កើតឲ្យមានក្រុមប្រឹក្សាឃុំ-សង្កាត់តាមរយៈការបោះឆ្នោតជាសាកលគឺជារបត់នយោបាយដ៏សំខាន់មួយនៅកម្ពុជា។ សំខាន់នៅត្រង់ថាអាជ្ញាធរមូលដ្ឋានជាអ្នកដឹកនាំផ្ទាល់ និងនៅកៀកប្រជាពលរដ្ឋនោះធ្លាប់តែទទួលការតែងតាំងពីថ្នាក់លើ។ ប៉ុន្តែចាប់តាំងពីឆ្នាំ២០០២មកក្រុមប្រឹក្សាឃុំ-សង្កាត់ត្រូវបានប្រជាពលរដ្ឋជាអ្នកបោះឆ្នោតជ្រើសរើសដោយផ្ទាល់។

យោងតាមនីតិវិធីនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់ដើម្បីអាចចូលរួមឈរឈ្មោះឲ្យគេបោះឆ្នោត និងចូលរួមបោះឆ្នោតបានត្រូវ៖

- បេក្ខភាពក្រុមប្រឹក្សាឃុំ-សង្កាត់ដែលជាអ្នកឈរឈ្មោះឲ្យគេបោះឆ្នោតត្រូវបានជ្រើសមកពីគណបក្សនយោបាយដែលបានចុះបញ្ជីចូលរួមបោះឆ្នោតជាមួយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប)។ បេក្ខភាពក្រុមប្រឹក្សាឃុំ-សង្កាត់ក៏ត្រូវបានចុះបញ្ជីឈ្មោះជាមួយ គ.ជ.បផងដែរ។
- ប្រជាពលរដ្ឋ ឬអ្នកដែលអាចបោះឆ្នោតបានត្រូវមានឈ្មោះក្នុងបញ្ជីបោះឆ្នោត និងមានអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ឬឯកសារបញ្ជាក់អត្តសញ្ញាណបម្រើឲ្យការបោះឆ្នោត។

### ១.២.២. រចនាសម្ព័ន្ធនៃរដ្ឋបាលឃុំ សង្កាត់

ជំពូកទី៣ (មាត្រា២៥ ដល់មាត្រា៤០ ) នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់បានកំណត់អំពីការរៀបចំរចនាសម្ព័ន្ធនៃរដ្ឋបាលឃុំ សង្កាត់ដែលតម្រូវឲ្យមានអង្គធ្វើសេចក្តីសម្រេចចិត្តជាក្រុមប្រឹក្សាឃុំ សង្កាត់ និងអង្គអនុវត្តសេចក្តីសម្រេចចិត្តរបស់ក្រុមប្រឹក្សា ឬហៅថាអង្គប្រតិបត្តិដែលរួមមានមេឃុំ ចៅសង្កាត់ ជំទប់ទី១ ចៅសង្កាត់រងទី១ ជំទប់ទី២ចៅសង្កាត់រងទី២ គណៈកម្មាធិការក្រុមប្រឹក្សា ស្មៀន និងថ្នាក់ដឹកនាំភូមិ។

ក្រុមប្រឹក្សាឃុំ សង្កាត់មានសមាជិកពី០៥ ទៅ ១១រូបផ្អែកតាមភូមិសាស្ត្រ និងចំនួនប្រជាពលរដ្ឋដែលកំពុងរស់នៅក្នុងឃុំ សង្កាត់នីមួយៗ។[៥] ចំនួនជាក់ស្តែងនៃសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវកំណត់ដោយអនុក្រឹត្យ។[៦] ក្រុមប្រឹក្សាឃុំ សង្កាត់មានអាណត្តិ៥ឆ្នាំហើយត្រូវផុតកំណត់នៅពេលដែលមានក្រុមប្រឹក្សាឃុំ សង្កាត់ថ្មីចូលកាន់តំណែង។ ក្នុងដំណាក់កាលអន្តរកាលក្រុមប្រឹក្សាឃុំ សង្កាត់ដែលផុតអាណត្តិមានភារកិច្ចត្រឹមតែសម្រួលកិច្ចការប្រចាំថ្ងៃប៉ុណ្ណោះ។

---

[៥] ច្បាប់ស្តីពីការគ្រប់គ្រងឃុំ សង្កាត់

[៦] ច្បាប់ស្តីពីការគ្រប់គ្រងឃុំ សង្កាត់

ក្រុមប្រឹក្សាឃុំ សង្កាត់នីមួយៗមានប្រធាន០១រូបដែលហៅថាប្រធានក្រុមប្រឹក្សាឃុំ សង្កាត់។ ប្រធានក្រុមប្រឹក្សាឃុំ សង្កាត់គឺជាមេឃុំ ចៅសង្កាត់។ ឃុំ សង្កាត់នីមួយៗមានមេឃុំ ចៅសង្កាត់ម្នាក់។ មេឃុំ ចៅសង្កាត់មានជំនួយការ០២រូប គឺជំទប់ទី១ ឬចៅសង្កាត់រងទី១ និងជំទប់ទី២ ឬចៅសង្កាត់រងទី២។

ជាមួយនេះ ឃុំ សង្កាត់ត្រូវមានបុគ្គលិកក្របខ័ណ្ឌរដ្ឋបាលនៃក្រសួងមហាផ្ទៃមួយរូបជា ស្មៀនឃុំ សង្កាត់។ ទន្ទឹមនេះដើម្បីលើកកម្ពស់ប្រសិទ្ធភាពនៃការគ្រប់គ្រងឃុំ សង្កាត់ ក្រុមប្រឹក្សាឃុំ សង្កាត់នីមួយៗ ត្រូវរៀបចំជ្រើសរើសឲ្យមានមេភូមិ និងជំនួយការភូមិសម្រាប់ភូមិនីមួយៗក្នុងឃុំ សង្កាត់របស់ខ្លួន។ ក្រុមប្រឹក្សាក៏អាចធ្វើការជ្រើសរើសបុគ្គលិកក្រៅក្របខ័ណ្ឌរដ្ឋដើម្បីជួយដល់កិច្ចការរបស់ខ្លួនផងដែរ។




**សម្គាល់:** ភូមិ ពុំមែនជាថ្នាក់រដ្ឋបាលនោះឡើយ។ ភូមិ គឺជាភ្នាក់ងាររបស់ឃុំ សង្កាត់ ដែលត្រូវបានបង្កើតឡើងក្នុងគោលដៅសម្រាប់បម្រើឲ្យការគ្រប់គ្រងប្រជាពលរដ្ឋ និងជាអ្នកអនុវត្តសេចក្ដីសម្រេចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងភូមិនីមួយ។[៧]

### ១.២.៣. តួនាទី មុខងារ និងអំណាចរបស់រដ្ឋបាលឃុំ សង្កាត់

មាត្រា៤១ នៃច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ចែងថារដ្ឋបាលឃុំសង្កាត់មានតួនាទីជំរុញ និង

[៧] សៀវភៅណែនាំស្ដីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ២០២២

គាំពារអភិបាលកិច្ចល្អ ដោយចាត់ចែងប្រើប្រាស់ធនធាននានាដែលមានប្រកបដោយចីរភាព សម្រាប់បំពេញសេចក្តីត្រូវការជាមូលដ្ឋានក្នុងឃុំ សង្កាត់របស់ខ្លួនបម្រើផលប្រយោជន៍រួមរបស់ប្រជាពលរដ្ឋ និងគោរពផលប្រយោជន៍ជាតិស្របតាមគោលនយោបាយទូទៅរបស់រដ្ឋ។

ផ្អែកតាមបទប្បញ្ញត្តិក្នុងច្បាប់ ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវ បានផ្ទេរឲ្យនូវតួនាទី មុខងារ និងអំណាចមួយចំនួន សម្រាប់បម្រើប្រជាពលរដ្ឋ និងការអភិវឌ្ឍនៅមូលដ្ឋាន របស់ខ្លួន។

ក្នុងការចាត់ចែងកិច្ចការនានាដូចមានចែងក្នុងមាត្រា៤២ នៃច្បាប់ ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ រដ្ឋបាលឃុំ សង្កាត់មានតួនាទីពីរប្រភេទគឺ៖

- តួនាទីបម្រើកិច្ចការមូលដ្ឋាន សម្រាប់បម្រើផលប្រយោជន៍ឃុំសង្កាត់ និងប្រជាពលរដ្ឋក្នុងឃុំសង្កាត់របស់ខ្លួន
- តួនាទីជាភ្នាក់ងារតំណាងរដ្ឋក្រោមការចាត់តាំង ឬការប្រគល់អំណាចរបស់អាជ្ញាធររដ្ឋ។

ដើម្បីអនុវត្តតួនាទីរបស់ខ្លួនរដ្ឋបាលឃុំ សង្កាត់មានអំណាចបញ្ញត្តិ និងអំណាចប្រតិបត្តិ (មាត្រា៤៨ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់) ដូចខាងក្រោម៖[៩]

- អំណាចបញ្ញត្តិត្រូវធ្វើឡើងតាមរយៈដីកាឃុំ សង្កាត់តាមការសម្រេចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ហើយត្រូវចុះហត្ថលេខាដោយមេឃុំ ចៅសង្កាត់សម្រាប់គ្រប់គ្រងកិច្ចការនានាក្នុងក្របខ័ណ្ឌតួនាទី មុខងារ និងអំណាចរបស់ខ្លួនដែលច្បាប់បានប្រគល់ឲ្យ។ ដីកាឃុំសង្កាត់មានប្រសិទ្ធភាពអនុវត្តតែនៅក្នុងវង្វង់ដែនដីរបស់ខ្លួនប៉ុណ្ណោះ។ ដីកាឃុំ សង្កាត់មិនត្រូវផ្ទុយនឹងសន្ធិសញ្ញា អនុសញ្ញាអន្តរជាតិដែលព្រះរាជាណាចក្រកម្ពុជាទទួលស្គាល់ស្មារតីរដ្ឋធម្មនុញ្ញ ច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស និងលិខិតបទដ្ឋានពាក់ព័ន្ធឡើយ។ បើដីកាណាមួយដែលផ្ទុយនឹងលិខិតបទដ្ឋានគតិយុត្តខាងលើនេះដីកានោះត្រូវបានចាត់ទុកជាមោឃៈ
- អំណាចប្រតិបត្តិមានន័យថារដ្ឋបាលឃុំ សង្កាត់មានសិទ្ធិអនុវត្តសេចក្តីសម្រេចរបស់ខ្លួននៅក្នុងក្របខ័ណ្ឌតួនាទី មុខងារ និងអំណាចរបស់ខ្លួនដែលច្បាប់បានប្រគល់ឲ្យ។ អំណាចប្រតិបត្តិនេះត្រូវបានធ្វើប្រតិភូកម្មឲ្យទៅមេឃុំ ចៅសង្កាត់ជាអ្នកអនុវត្តក្នុងនាមក្រុមប្រឹក្សា ឃុំ សង្កាត់របស់ខ្លួន។

**ព្រំដែននៃអំណាច**

ក្រុមប្រឹក្សាឃុំ សង្កាត់មានអំណាចបញ្ញត្តិ និងអំណាចប្រតិបត្តិ។ ទោះជាយ៉ាងនេះក្តីការបំពេញការងាររបស់ខ្លួនរដ្ឋបាលឃុំ សង្កាត់ត្រូវស្ថិតនៅក្នុងខ្សែបណ្តោយនៃអំណាចនីតិប្រតិបត្តិរបស់រដ្ឋ។ រដ្ឋបាលឃុំ សង្កាត់អាចធ្វើសកម្មភាពបានតែនៅក្នុងក្របខ័ណ្ឌអំណាច តួនាទី និងមុខងារដែលច្បាប់បាន ប្រគល់ឲ្យប៉ុណ្ណោះ និង

[៩] សៀវភៅណែនាំស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ២០២២

មិនអាចធ្វើសកម្មភាពណាមួយដែលផ្ទុយនឹងគោលការណ៍ និងបទប្បញ្ញត្តិដែល បានកំណត់នៅក្នុងរដ្ឋធម្មនុញ្ញ ច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស និងលិខិតបទដ្ឋាននានានោះឡើយ (មាត្រា៥ នៃច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលឃុំ-សង្កាត់)។

យោងមាត្រា៤៥ នៃច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់រដ្ឋបាលឃុំសង្កាត់គ្មានអំណាចសម្រេចលើវិស័យមួយចំនួនដូចខាងក្រោមៈ

- ព្រៃឈើ
- ប្រៃសណីយ៍ និងទូរគមនាគមន៍
- ការពារជាតិ
- សន្តិសុខជាតិ
- រូបិយវត្ថុ
- នយោបាយក្រៅប្រទេស
- គោលនយោបាយសារពើពន្ធ
- វិស័យផ្សេងទៀតដែលមានចែងក្នុងច្បាប់ និងលិខិតបទដ្ឋានពាក់ព័ន្ធ។[៩]

## ១.៣. កិច្ចប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់

ផ្អែកតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តិពាក់ព័ន្ធកិច្ចប្រជុំរបស់ក្រុមប្រឹក្សាឃុំ សង្កាត់មាន២ប្រភេទគឺ កិច្ចប្រជុំសាមញ្ញ និងកិច្ចប្រជុំវិសាមញ្ញ។

កិច្ចប្រជុំសាមញ្ញជាកិច្ចប្រជុំដែលក្រុមប្រឹក្សាត្រូវធ្វើតាមការកំណត់ជាក់លាក់តាមរយៈការរៀបចំប្រតិទិនកិច្ចប្រជុំក្រុមប្រឹក្សា។

កិច្ចប្រជុំវិសាមញ្ញជាកិច្ចប្រជុំដែលក្រុមប្រឹក្សាឃុំ សង្កាត់អាចរៀបចំឡើងនៅពេលណាក៏បានតាមការចាំបាច់។

គោលការណ៍សំខាន់ៗក្នុងការរៀបចំកិច្ចប្រជុំប្រឹក្សាត្រូវបានកំណត់ដូចខាងក្រោមៈ[១០]

- ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវធ្វើការប្រជុំសសាមញ្ញយ៉ាងតិចចំនួនមួយដងក្នុងមួយខែ
- កិច្ចប្រជុំរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ មិនត្រូវប្រារព្ធធ្វើឡើងមុន២៥ថ្ងៃ និងលើសពី៣៥ថ្ងៃបន្ទាប់ពីកិច្ចប្រជុំសាមញ្ញលើកមុនឡើយ

[៩] ច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់

[១០] សៀវភៅណែនាំស្ដីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ២០២២

- ក្នុងករណីចាំបាច់ ក្រុមប្រឹក្សាឃុំ សង្កាត់ អាចធ្វើការប្រជុំវិសាមញ្ញ ដើម្បីពិភាក្សាលើការងារដែលក្រុមប្រឹក្សាឃុំ សង្កាត់បានកំណត់ថាជាកិច្ចការពិសេស ឬកិច្ចការបន្ទាន់ចាំបាច់
- កិច្ចប្រជុំវិសាមញ្ញត្រូវប្រារព្ធឡើងក្នុងអំឡុងពេល០៣ថ្ងៃបន្ទាប់ពីប្រធានក្រុមប្រឹក្សាឃុំ សង្កាត់សម្រេចឲ្យមានការរៀបចំកិច្ចប្រជុំវិសាមញ្ញនេះ ឬបន្ទាប់ពីសមាជិកចំនួន១/៣ យ៉ាងតិចនៃសមាជិកក្រុមប្រឹក្សាទាំងមូលស្នើសុំឲ្យរៀបចំកិច្ចប្រជុំវិសាមញ្ញ។ ការសម្រេច ឬការស្នើសុំឲ្យមានកិច្ចប្រជុំវិសាមញ្ញត្រូវបញ្ជាក់ពីមូលហេតុសមស្រប
- រាល់កិច្ចប្រជុំរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវអញ្ជើញតំណាង០២រូបនៃគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារ និងប្រធានគណៈកម្មាធិការនានារបស់ក្រុមប្រឹក្សាឃុំ សង្កាត់ដើម្បីចូលរួមកិច្ចប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់។

រាល់កិច្ចប្រជុំរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវធ្វើជាសាធារណៈ និងមានលក្ខណៈប្រជាធិបតេយ្យ។ ជាមួយនេះក្រុមប្រឹក្សាឃុំ សង្កាត់អាចឲ្យមានកិច្ចប្រជុំជាសម្ងាត់បានដើម្បីពិភាក្សាលើបញ្ហាដូចជា៖

- ការដាក់វិន័យ ឬបញ្ឈប់សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់
- អំពើបញ្ហាអសន្តិសុខក្នុងឃុំ សង្កាត់
- អំពីការរៀបចំគម្រោងដើម្បីធ្វើលទ្ធកម្មអ្វីមួយ
- ការរៀបចំសំណុំរឿងដើម្បីតវ៉ា ឬការពារក្តីអ្វីមួយ
- ការដោះស្រាយបញ្ហាដែលពាក់ព័ន្ធនឹងកិត្តិយសបុគ្គល។ល។[១១]

ក្នុងកិច្ចប្រជុំសម្ងាត់មានតែក្រុមប្រឹក្សាឃុំ សង្កាត់ និងស្មៀនឃុំ សង្កាត់តែប៉ុណ្ណោះដែលមានសិទ្ធិចូលរួមក្នុងអង្គប្រជុំ។

[១១]សៀវភៅណែនាំស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ២០២២

ចំនួនក្រុមប្រឹក្សាឃុំ សង្កាត់លើសពីពាក់កណ្តាលនៃសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ទាំងមូលមានដូចខាងក្រោម៖

| ចំនួនសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ | ចំនួនសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ចូលរួមយ៉ាងតិច |
|---|---|
| ៥ រូប | ៣ រូប |
| ៧ រូប | ៤ រូប |
| ៩ រូប | ៥ រូប |
| ១១ រូប | ៦ រូប |

## ១.៤. កិច្ចការរដ្ឋបាលឃុំ សង្កាត់

### ១.៤.១. លិខិតបទដ្ឋានគតិយុត្ត

លិខិតបទដ្ឋានគតិយុត្តរបស់រដ្ឋបាលឃុំ សង្កាត់គឺជាលិខិតដែលកំណត់នូវវិធាន បទប្បញ្ញត្តិ បទបញ្ជា ឬគោលការណ៍នានាសម្រាប់ការគ្រប់គ្រងការតែងតាំងការបង្កើតឡើងនូវយន្តការនិងការណែនាំអនុវត្តកិច្ចការនានា។ លិខិតបទដ្ឋានគតិយុត្តរបស់រដ្ឋបាលឃុំ សង្កាត់រួមមានដីកា និងសេចក្តីសម្រេច។

#### ១.៤.១.១. ដីកា

ដីកាឃុំ សង្កាត់គឺជាលិខិតបទដ្ឋានគតិយុត្តដែលកំណត់នូវបទប្បញ្ញត្តិទាំងឡាយដែលរដ្ឋបាលឃុំ សង្កាត់បង្កើតឡើងសំដៅបម្រើផលប្រយោជន៍ប្រជាពលរដ្ឋទូទៅក្នុងឃុំ សង្កាត់ដែលស្មើភាពមិនរើសអើង និងសម្រាប់គ្រប់គ្រងកិច្ចការនានាក្នុងក្របខ័ណ្ឌតួនាទី មុខងារ និងអំណាចអនុវត្តក្នុងរង្វង់ដែនដីរបស់ខ្លួន។ ដីកាឃុំ សង្កាត់មិនត្រូវផ្ទុយនឹងច្បាប់ និងលិខិតបទដ្ឋាននានារបស់រដ្ឋឡើយ។

ដីកាឃុំ សង្កាត់ត្រូវចុះហត្ថលេខាដោយមេឃុំ សង្កាត់តាមការសម្រេចរបស់អង្គប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់ដែលមានចំនួនលើសពីពាក់កណ្តាលនៃសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ទាំងមូល។[១២]

**ឧទាហរណ៍៖**

- ដីកាស្តីពីការថែរក្សាបរិស្ថាន និងអនាម័យ
- ដីកាស្តីពីការរក្សាសណ្តាប់ធ្នាប់សាធារណៈ។

[១២] ការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់តាមបែបវិមជ្ឈការ

#### ១.៤.១.២. សេចក្ដីសម្រេច

សេចក្ដីសម្រេចឃុំ សង្កាត់គឺជាលិខិតបទដ្ឋានគតិយុត្តដែលបង្កើតឡើងដើម្បីអនុវត្តដីការបស់ខ្លួន ឬលិខិតបទដ្ឋាននានារបស់រដ្ឋ ឬចែងអំពីការបង្កើតការតែងតាំងការរៀបចំ ឬការគ្រប់គ្រងកិច្ចការនានាក្នុងក្របខណ្ឌតួនាទី មុខងារ និងអំណាចអនុវត្តក្នុងរង្វង់ដែនដីរបស់ខ្លួន។ សេចក្ដីសម្រេចមានលក្ខណៈប្រហាក់ប្រហែលនឹងដីកាឃុំ សង្កាត់ដែរប៉ុន្តែមានឋានានុក្រមទាបជាងដីកា និងខ្ពស់ជាងលិខិតរដ្ឋបាលសាមញ្ញធម្មតាផ្សេងៗទៀតក្នុងឃុំ សង្កាត់។ សេចក្ដីសម្រេចឃុំ សង្កាត់មិនត្រូវផ្ទុយនឹងច្បាប់ និងលិខិតបទដ្ឋាននានារបស់រដ្ឋ និងដីការបស់ខ្លួនឡើយ។

សេចក្ដីសម្រេចឃុំ សង្កាត់ត្រូវចុះហត្ថលេខារបស់មេឃុំ ចៅសង្កាត់តាមការសម្រេចរបស់អង្គប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់ដែលមានចំនួនលើសពីពាក់កណ្ដាលនៃសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ទាំងមូល។

ក្នុងករណីប្រធានសក្តិ និងបន្ទាន់បំផុតដែលមិនអាចកោះប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់បាន មេឃុំ ចៅសង្កាត់អាចចេញសេចក្ដីសម្រេចដើម្បីដោះស្រាយស្ថានភាពបន្ទាន់នោះ។ សេចក្ដីសម្រេចនេះនឹងត្រូវដាក់ជូនកិច្ចប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់នៅក្នុងកិច្ចបន្ទាប់ដើម្បីពិនិត្យឡើងវិញអំពីភាពត្រឹមត្រូវតាមច្បាប់។[១៣]

**ឧទាហរណ៍៖**

- សេចក្ដីសម្រេចស្ដីពីការបង្កើតគណៈកម្មាធិការកសាងផែនការ និងថវិកា
- សេចក្ដីសម្រេចស្ដីពីការបង្កើតគណៈកម្មការលទ្ធកម្ម
- សេចក្ដីសម្រេចស្ដីពីការបង្កើតគណៈកម្មការគ្រប់គ្រងគម្រោង។

### ១.៤.២. លិខិតរដ្ឋបាល

លិខិតរដ្ឋបាល គឺជាលិខិតដែលរៀបចំតាក់តែងឡើងជាលាយលក្ខណ៍អក្សរសម្រាប់ជាមធ្យោបាយទំនាក់ទំនងផ្លូវការរបស់រដ្ឋបាលឃុំ សង្កាត់ជាមួយស្ថាប័ន អង្គភាព និងបុគ្គលនានាក្នុងគោលបំណងជូនព័ត៌មានណែនាំ អញ្ជើញរាយការណ៍ផ្សព្វផ្សាយឆ្លើយតប ឬចាត់តាំងបុគ្គលណាមួយឲ្យទៅបំពេញបេសកកម្ម។[១៤]

#### ១.៤.២.១. ប្រភេទលិខិតរដ្ឋបាល

លិខិតរដ្ឋបាលឃុំ សង្កាត់ដែលប្រើប្រាស់ជាផ្លូវការរួមមាន៖

- លិខិតស្នើគឺជាលិខិតដែលឃុំ សង្កាត់រៀបចំឡើងដើម្បីបង្ហាញពីគោលបំណង និងមូលហេតុនៃតម្រូវការជាក់លាក់ណាមួយរបស់ខ្លួនថ្លែងទៅកាន់រូបវន្តបុគ្គល នីតិបុគ្គលសាធារណៈឯកជន ក្រសួង ស្ថាប័ន អង្គការ ឬសង្គមស៊ីវិលដែលមានសិទ្ធិអំណាចសម្រេច ឬដោះស្រាយចំពោះការស្នើសុំនោះ។

[១៣] ការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់តាមបែបវិមជ្ឈការ

[១៤] សៀវភៅណែនាំស្ដីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ២០២២

- សេចក្តីជូនដំណឹង ឬលិខិតជូនដំណឹង គឺជាលិខិតដែលឃុំ សង្កាត់រៀបចំឡើងដើម្បីធ្វើការទំនាក់ទំនងជាមួយបុគ្គលក្រសួង ស្ថាប័ន អង្គការសង្គមស៊ីវិលមានខ្លឹមសារជាការឆ្លើយបំភ្លឺចំពោះបញ្ហា ឬជាការឆ្លើយតបចំពោះសំណើ ឬជាការជូនដំណឹងឲ្យសាធារណជនបានដឹងនូវព័ត៌មានទាំងឡាយដែលឃុំ សង្កាត់ត្រូវការផ្សព្វផ្សាយ។
- លិខិតអញ្ជើញគឺជាលិខិតដែលឃុំ សង្កាត់រៀបចំឡើងដើម្បីធ្វើការអញ្ជើញបុគ្គលឬតំណាងក្រសួង ស្ថាប័នអង្គការសង្គមស៊ីវិលឲ្យចូលរួមក្នុងសកម្មភាពរបស់ឃុំ សង្កាត់ចំពោះកិច្ចការដែលពាក់ព័ន្ធទៅនិងបុគ្គល ឬអង្គភាពទាំងនោះដោយមានបញ្ជាក់ឈ្មោះ និងឋានៈ (អ្នកដែលត្រូវអញ្ជើញ) ទីកន្លែងប្រជុំ ឬប្រារព្ធពិធីកាលបរិច្ឆេទកម្មវិធី ឬរបៀបវារៈប្រជុំ( និងអាចមានឯកសារដែលពាក់ព័ន្ធនឹងការប្រជុំភ្ជាប់ជាមួយ)។
- លិខិតបញ្ជាបេសកកម្មគឺជាលិខិតដែលឃុំ សង្កាត់រៀបចំឡើងដើម្បីចាត់តាំងមន្ត្រីបុគ្គលិកឃុំ សង្កាត់ឲ្យចូលរួមក្នុងសកម្មភាពនានានៅក្រៅឃុំ សង្កាត់។ លិខិតនេះមានភ្ជាប់ជាមួយនូវទិដ្ឋាការធ្វើដំណើរ។ ទិដ្ឋាការធ្វើដំណើរគឺជាលិខិតរដ្ឋបាលមួយប្រភេទសម្រាប់ឲ្យអ្នកដែលមានភារកិច្ចទៅបំពេញបេសកកម្មយកទៅចុះទិដ្ឋាការនូវទីកន្លែងកាលបរិច្ឆេទមធ្យោបាយធ្វើដំណើរ និងហត្ថលេខារបស់អង្គភាពមានសមត្ថកិច្ចដែលបានអនុញ្ញាត និងអង្គភាពដែលបានទទួលដឹងអំពីការចេញដំណើរ និងការមកដល់ពីកន្លែងមួយទៅកន្លែងមួយទៀត។ នៅពេលត្រឡប់មកវិញត្រូវធ្វើរបាយការណ៍ ឬរាយការណ៍ជូនមេឃុំ ចៅសង្កាត់ ឬក្រុមប្រឹក្សាឃុំ សង្កាត់ឲ្យបានជ្រាបអំពីលទ្ធផល ឬបញ្ហាសំខាន់ៗដែលខ្លួនបានទៅចូលរួម។
- របាយការណ៍ គឺជាសេចក្តីរាយការណ៍អំពីសកម្មភាពដំណើរការ និងលទ្ធផលការងាររបស់ឃុំ សង្កាត់ ឬបុគ្គលិកណាម្នាក់ ឬក្រុមដែលរដ្ឋបាលឃុំ សង្កាត់បានបំពេញ ឬឃុំ សង្កាត់បានចាត់តាំងឲ្យទៅបំពេញដើម្បីរាយការណ៍ជូនថ្នាក់ដឹកនាំ និងអង្គភាពពាក់ព័ន្ធ។ ទម្រង់របាយការណ៍ប្រចាំខែ និងប្រចាំឆ្នាំរបស់រដ្ឋបាលឃុំ សង្កាត់ត្រូវអនុវត្តតាមសេចក្តីណែនាំលេខ០៣៥ស.ណ ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ របស់ក្រសួងមហាផ្ទៃស្តីពីការរៀបចំរបាយការណ៍របស់រដ្ឋបាលថ្នាក់ក្រោមជាតិ។ ក្រៅពីទម្រង់របាយការណ៍ប្រចាំខែ និងទម្រង់របាយកាណ៍ប្រចាំឆ្នាំខាងលើនេះឃុំ សង្កាត់អាចបង្កើត និងប្រើប្រាស់ទម្រង់របាយការណ៍ផ្សេងទៀតសម្រាប់ប្រើប្រាស់នៅក្នុងឃុំ សង្កាត់របស់ខ្លួន។
- កំណត់ហេតុ គឺជាការកត់ត្រាស្រង់យកមតិយោបល់សេចក្តីសម្រេច និងការឯកភាពលើសកម្មភាពដែលត្រូវអនុវត្តពីគ្រប់សមាជិកអង្គប្រជុំ និងការសម្រេចរបស់អង្គប្រជុំ ឬជាការកត់ត្រារាល់ហេតុការណ៍ណាមួយដែលបានកើតឡើងជាក់ស្តែងដើម្បីរក្សាទុកជាសក្ខីភាពនៅពេលដែលមានតម្រូវការ

- លិខិតផ្ទេរសិទ្ធិ គឺជាលិខិតរបស់មេឃុំ ចៅសង្កាត់ប្រកាសជាលាយលក្ខណ៍អក្សរប្រគល់សិទ្ធិឲ្យទៅជំទប់ចៅសង្កាត់រងតាមឋានានុក្រមដើម្បីធ្វើការជាមួយមេឃុំ ចៅសង្កាត់ស្តីទីក្នុងអំឡុងពេលដែលមេឃុំ ចៅសង្កាត់អវត្តមាន។
- ដីការអម គឺជាឯកសាររដ្ឋបាលដែលឃុំ សង្កាត់រៀបចំឡើងផ្ញើអមភ្ជាប់ជាមួយសំណុំលិខិតដែលត្រូវធ្វើចេញទៅឲ្យអង្គភាព ក្រសួង ស្ថាប័នណាមួយដោយមានកត់ត្រាឈ្មោះ និងចំនួនលិខិត (ឯកសារ) លើដីការអមនោះ។ ឃុំ សង្កាត់ប្រើដីការអមដើម្បីជៀសវាងការបាត់បង់ឯកសារដែរដ្ឋបាលឃុំ សង្កាត់ផ្ញើមក។[១៥]

**១.៤.២.២. ការងាររៀប**

ស្មៀនឃុំ សង្កាត់ជាអ្នកធានានិរន្តរភាពកិច្ចការរដ្ឋបាលក្នុងឃុំ សង្កាត់។ ហេតុនេះរាល់លិខិតរដ្ឋបាលទាំងអស់ពាក់ព័ន្ធនឹងឃុំ សង្កាត់ចាំបាច់ត្រូវចូលនិងចេញតាមរយៈស្មៀនលើកលែងតែមានការកំណត់ដោយឡែក។

ពាក់ព័ន្ធនឹងការងាររៀបនេះមានការងារសំខាន់ៗមួយចំនួនខាងក្រោមៈ

- ចរាចរលិខិតចូល និងលិខិតចេញ
- បោះត្រា ចុះលេខ និងកាលបរិច្ឆេទលិខិតចេញ និងលិខិតចូល
- កត់ត្រាចូលសៀវភៅលិខិតចូល និងលិខិតចេញ
- រក្សាទុកលិខិតចូល និងលិខិតចេញ
- រក្សាទុក និងគ្រប់គ្រងត្រា សៀវភៅលិខិតចូល និងលិខិតចេញ។[១៦]

**១.៤.២.៣. ការតាក់តែងលិខិត**

- **ការរៀបចំសេចក្តីព្រាងលិខិតៈ** សំដៅដល់បុគ្គលិកទទួលបន្ទុកត្រូវផ្តួចផ្តើមរៀបចំសេចក្តីព្រាងលិខិតទៅតាមទម្រង់ដែលបានកំណត់ដោយបរិយាយខ្លឹមសារលិខិតឲ្យបានច្បាប់លាស់ និងមានអត្ថន័យគ្រប់គ្រាន់។
- **ការត្រួតពិនិត្យដោយស្មៀនៈ** សំដៅដល់បុគ្គលិកទទួលបន្ទុកត្រូវដាក់ជូនស្មៀននូវសេចក្តីព្រាងលិខិតរបស់ខ្លួនដើម្បីត្រួតពិនិត្យ។ ស្មៀន គឺជាអ្នកទទួលខុសត្រូវត្រួតពិនិត្យនូវរាល់លិខិតទាំងអស់ដើម្បីធានាភាពត្រឹមត្រូវនូវទម្រង់ខ្លឹមសារនីត្យានុកូលភាព អក្ខរាវិរុទ្ធ និងភាពមានរបៀបរៀបរយនៃលិខិតមុននឹងដាក់ជូនថ្នាក់ដឹកនាំពិនិត្យ និងសម្រេច
- **ការចុះហត្ថលេខាសង្ខេបៈ** មុនដាក់ជូនហត្ថលេខីចុះហត្ថលេខា លិខិតត្រូវចុះហត្ថលេខាសង្ខេបដោយហត្ថលេខីសង្ខេបដែលមានភារកិច្ចតាមលំដាប់លំដោយ

[១៥] សេចក្តីណែនាំស្តីពីកិច្ចការរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

[១៦] សៀវភៅណែនាំស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ២០២២

- **ការចុះហត្ថលេខា៖** បន្ទាប់ពីបានចុះហត្ថលេខាសង្ខេបរួចត្រូវបញ្ជូនលិខិតទៅហត្ថលេខីដែលត្រូវចុះហត្ថលេខាលើលិខិតនោះ។

**១.៤.២.៤. ការគ្រប់គ្រងឯកសារ**

ការគ្រប់គ្រងឯកសារ គឺជាការរៀបចំទុកដាក់និងថែរក្សាឯកសារទាំងឡាយតាមប្រព័ន្ធមួយមានសណ្តាប់ធ្នាប់ និងសុវត្ថិភាព។[១៧]

យោងតាមអនុក្រឹត្យលេខ២២ អនក្រ.បក ស្តីពីការធ្វើវិមជ្ឈការអំណាចតួនាទី និងភារកិច្ចទៅឲ្យក្រុមប្រឹក្សាឃុំ សង្កាត់ត្រង់មាត្រា៩ ចែងថា៖

- ឃុំ សង្កាត់ គឺជាម្ចាស់លើរាល់លិខិតនិងឯកសារដែលរៀបចំឡើងដោយក្រុមប្រឹក្សាឃុំ សង្កាត់ ឬក្នុងនាមក្រុមប្រឹក្សាឃុំ សង្កាត់ និងជាម្ចាស់កម្មសិទ្ធិលើតែមប្រិ៍ត្រាឃុំ សង្កាត់ព្រមទាំងឧបករណ៍ផ្សេងៗទៀតទាំងអស់របស់ឃុំ សង្កាត់។
- ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវធានាទុកដាក់ឯកសារ លិខិតស្នាម តែមប្រិ៍ត្រាឃុំ សង្កាត់ព្រមទាំងឧបករណ៍ផ្សេងៗទៀតទាំងអស់របស់ឃុំ សង្កាត់ និងគង់វង្ស។[១៨]

**១.៤.២.៥. ការគ្រប់គ្រងសម្ភារបរិក្ខារ**

សម្ភារបរិក្ខារបស់ឃុំ សង្កាត់គឺជាសម្ភារបរិក្ខារទាំងឡាយណាដែលឃុំ សង្កាត់មានពីមុនមកបានទិញ និងបានទទួលពីម្ចាស់អំណោយនានា ដូចជា តុ កៅអី កុំព្យូទ័រ......។

ស្មៀន គឺជាអ្នកទទួលខុសត្រូវក្នុងការចុះបញ្ជីនូវគ្រប់សម្ភារបរិក្ខារទាំងអស់របស់ឃុំ សង្កាត់។ គ្រប់សម្ភារបរិក្ខារបស់ឃុំ សង្កាត់ត្រូវចុះបញ្ជីឲ្យបានត្រឹមត្រូវ និងត្រូវរក្សាទុកឲ្យបានល្អប្រកបដោយសុវត្ថិភាព និងធ្វើបច្ចុប្បន្នភាពជាប្រចាំ។ គ្រប់សម្ភារបរិក្ខារបស់ឃុំ សង្កាត់ដែលកាត់ចេញពីបញ្ជីត្រូវធ្វើឡើងស្របតាមនីតិវិធី និងត្រូវសម្រេចដោយអង្គប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់។

## ១.៥. ផែនការអភិវឌ្ឍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ សង្កាត់

មាត្រា៦០ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់បានតម្រូវឲ្យក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវរៀបចំផែនការអភិវឌ្ឍឃុំ សង្កាត់ក្នុងគោលបំណងកំណត់ទស្សនវិស័យ និងកម្មវិធីនានាសម្រាប់កិច្ចអភិវឌ្ឍន៍នៅក្នុងឃុំ សង្កាត់របស់ខ្លួន។ ផែនការអភិវឌ្ឍឃុំ សង្កាត់មានរយៈពេល៥ឆ្នាំ និងត្រូវចាត់ចែងអនុវត្តតាមរយៈការរៀបចំកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ សង្កាត់ដែលត្រូវធ្វើបច្ចុប្បន្នភាពជារៀងរាល់ឆ្នាំ។ ដំណើរការនៃការរៀបចំផែនការ

[១៧] សៀវភៅណែនាំស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ២០២២

[១៨] ការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់តាមបែបវិម្សការ

អភិវឌ្ឍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលរបស់រដ្ឋបាលឃុំ សង្កាត់ត្រូវធ្វើឡើងទៅតាមបរិបទ និងនីតិវិធីដូចមានចែងកំណត់នៅក្នុងច្បាប់ និងលិខិតបទដ្ឋានជាធរមានដែលមានជាអាទិ៍ដូចជាៈ

- ច្បាប់ស្តីពីការគ្រប់គ្រងឃុំ សង្កាត់
- ប្រកាសអន្តរក្រសួងលេខ២៤២៣ប្រក ចុះថ្ងៃទី០៣ ខែកក្កដា ឆ្នាំ២០០៧ស្តីពីការកសាងផែនការអភិវឌ្ឍឃុំ សង្កាត់ និងកម្មវិធីវិនិយោគឃុំ សង្កាត់
- សេចក្តីណែនាំស្តីពីការកសាងផែនការអភិវឌ្ឍឃុំ សង្កាត់ និងកម្មវិធីវិនិយោគឃុំ សង្កាត់ឆ្នាំ២០១៧
- ប្រកាសអន្តរក្រសួងលេខ ០១៤៩ ផកប្រ.ក ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០២០ ស្តីពីការដាក់ឲ្យប្រើប្រាស់សេចក្តីបំពេញបន្ថែមលើសេចក្តីណែនាំបច្ចេកទេសស្តីពីការរៀបចំ និងការកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់
- សៀវភៅណែនាំស្តីពីការអនុវត្តគម្រោងមូលនិធិឃុំ សង្កាត់ឆ្នាំ២០០៩
- ព្រមទាំងលិខិតបទដ្ឋាន និងឯកសារពាក់ពន្ធ័ដទៃទៀត។

### ១.៥.១. សនិទានភាព

ផែនការអភិវឌ្ឍឃុំ សង្កាត់គឺជាមធ្យោបាយយ៉ាងសំខាន់របស់រដ្ឋបាលឃុំ សង្កាត់ក្នុងការកំណត់អំពីបញ្ហាប្រឈម និងតម្រូវការជាអតិភាពរបស់មូលដ្ឋានក៏ដូចជាយុទ្ធសាស្ត្រនានាដើម្បីដោះស្រាយបញ្ហាប្រឈមទាំងនោះ សំដៅឆ្លើយតបទៅនឹងតម្រូវការជាអទិភាពរបស់ប្រជាពលរដ្ឋប្រកបដោយប្រសិទ្ធភាព និងស័ក្តិសិទ្ធភាព។

ប្រកាសអន្តរក្រសួងលេខ២៤៤៣ ប្រក ចុះថ្ងៃទី០៣ ខែកក្កដា ឆ្នាំ២០០៧ ស្តីពីការកសាងផែនការអភិវឌ្ឍឃុំ សង្កាត់ និងកម្មវិធីវិនិយោគឃុំ សង្កាត់កំណត់ថាផែនការអភិវឌ្ឍឃុំ សង្កាត់ត្រូវមានសុពលភាពរយៈពេល០៥ (ប្រាំ)ឆ្នាំហើយត្រូវត្រួតពិនិត្យឡើងវិញជារៀងរាល់ឆ្នាំតាមរយៈការរៀបចំកម្មវិធីវិនិយោគ និងថវិការប្រចាំឆ្នាំរបស់រដ្ឋបាលឃុំ សង្កាត់។ ក្រុមប្រឹក្សាឃុំ សង្កាត់នីមួយៗត្រូវរៀបចំកសាងផែនការអភិវឌ្ឍឃុំ សង្កាត់របស់ខ្លួនដែលឆ្លុះបញ្ចាំងអំពីផែនការអភិវឌ្ឍរយៈពេលប្រាំឆ្នាំសម្រាប់អាណត្តិរបស់ក្រុមប្រឹក្សា និងកម្មវិធីអភិវឌ្ឍន៍មូលដ្ឋានរយៈពេលប្រាំឆ្នាំ។ ផែនការអភិវឌ្ឍរយៈពេលប្រាំឆ្នាំសម្រាប់អាណត្តិរបស់ក្រុមប្រឹក្សា គឺជាផែនការដែលមានចរឹតជាទស្សនៈអភិវឌ្ឍន៍រួមរបស់រដ្ឋបាលឃុំ សង្កាត់។ កម្មវិធីអភិវឌ្ឍន៍មូលដ្ឋានរយៈពេលប្រាំឆ្នាំគឺជារបៀបវារៈ ឬកម្មវិធីជាក់ស្តែងដែលរដ្ឋបាលឃុំ សង្កាត់នីមួយៗចង់សម្រេចបានក្នុងអាណត្តិរបស់ខ្លួនសម្រាប់បង្ហាញពីគណនេយ្យភាពរបស់ខ្លួនចំពោះប្រជាពលរដ្ឋ និងចំពោះរាជរដ្ឋាភិបាល។ កម្មវិធីអភិវឌ្ឍន៍មូលដ្ឋានមានសមាសភាពចំនួនបីគឺក្របខណ្ឌវិនិយោគក្របខ័ណ្ឌផ្តល់សេវាកម្ម និងការដាក់ចេញលិខិតបទដ្ឋានគតិយុត្តនានា។

### ១.៥.២. តួអង្គសំខាន់ៗ

ក្នុងការកសាផែនការអភិវឌ្ឍឃុំ សង្កាត់ត្រូវមានតួអង្គសំខាន់ៗចំនួនបីដែលត្រូវចូលរួម និងទទួលខុសត្រូវផ្ទាល់លើការរៀបចំផែនការអភិវឌ្ឍឃុំ សង្កាត់៖[១៩]

- **ក្រុមប្រឹក្សាឃុំ សង្កាត់៖** ពិនិត្យ និងអនុម័តផែនការអភិវឌ្ឍឃុំ សង្កាត់ដោយធានាឲ្យមានភាពគ្រប់ជ្រុងជ្រោយ និងឆ្លើយតបនឹងសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋគ្រប់ក្រុមគោលដៅព្រមទាំងពិនិត្យ និងអនុម័តលើរាល់ការធ្វើវិសោធនកម្ម និងតាមដានវាយតម្លៃអំពីសមិទ្ធផលដែលសម្រេចបាន
- **មេឃុំ ចៅសង្កាត់៖** ដឹកនាំការប្រមូលទិន្នន័យភូមិ ឃុំ សង្កាត់ ដឹកនាំការងារកសាងផែនការអភិវឌ្ឍឃុំ សង្កាត់ និងដាក់សេចក្តីព្រាងផែនការអភិវឌ្ឍឃុំ សង្កាត់ជូនទៅក្រុមប្រឹក្សាឃុំ សង្កាត់ដើម្បីពិនិត្យ និងអនុម័ត។
- **គណៈកម្មាធិការកសាងផែនការ និងថវិកាឃុំ សង្កាត់(គ.ផ.ថ)៖** ជួយមេឃុំ ចៅសង្កាត់ក្នុងការរៀបចំ និងកសាងផែនការអភិវឌ្ឍឃុំ សង្កាត់ដោយអនុវត្តតាមបែបបទនីតិវិធីដូចមានកំណត់ក្នុងសេចក្តីណែនាំបច្ចេកទេសស្តីពីការរៀបចំ និងការកសាងផែនការអភិវឌ្ឍឃុំ សង្កាត់។

មួយគ្នានេះដើម្បីធានាឲ្យផែនការអភិវឌ្ឍឃុំ សង្កាត់មានគុណភាពចាំបាច់ត្រូវមានការចូលរួមគាំទ្រពីយន្តការសំខាន់ៗដូចខាងក្រោម៖

- **គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ (គ.ក.ន.ក)៖** ជួយក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងការប្រមូលវិភាគព័ត៌មានទិន្នន័យពាក់ព័ន្ធនឹងបញ្ហាតម្រូវការរបស់នារីនិងកុមារដើម្បីដាក់បញ្ចូលក្នុងផែនការអភិវឌ្ឍឃុំ សង្កាត់ និងចូលរួមផ្តល់ព័ត៌មាន និងការពារខ្លឹមសារក្នុងដែនសមត្ថកិច្ចរបស់ខ្លួនក្នុងដែនសមត្ថកិច្ចរបស់ខ្លួនក្នុងដំណើរការកសាងផែនការអភិវឌ្ឍឃុំ សង្កាត់ជាដើម
- **មន្ទីរផែនការរាជធានី ខេត្ត៖** គាំទ្របច្ចេកទេសកសាងផែនការអភិវឌ្ឍឃុំ សង្កាត់សហការជាមួយរដ្ឋបាលខេត្តក្នុងការបណ្តុះបណ្តាលអំពីបច្ចេកទេសកសាងផែនការអភិវឌ្ឍឃុំ សង្កាត់ និងការពាក់ព័ន្ធ និងផ្តល់ការគាំទ្របច្ចេកទេសពាក់ព័ន្ធការកសាងផែនការអភិវឌ្ឍឃុំ សង្កាត់ និងការតាមដានការវាយតម្លៃលទ្ធផលនៃការអនុវត្តផែនការអភិវឌ្ឍឃុំ សង្កាត់ដល់ក្រុមប្រឹក្សាឃុំ សង្កាត់ និងអ្នកពាក់ព័ន្ធ
- **ទីចាត់ការផែនការ និងវិនិយោគរាជធានី ខេត្ត៖** ផ្តល់ការបណ្តុះបណ្តាលដល់សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ គ.ផ.ថ និងអ្នកពាក់ព័ន្ធ អំពីនីតិវិធីកសាងផែនការអភិវឌ្ឍឃុំ សង្កាត់ព្រមទាំងជំរុញ និងគាំទ្រ

[១៩] សៀវភៅណែនាំស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ២០២២

ការប្រមូលនិងរក្សាសៀវភៅផែនការអភិវឌ្ឍឃុំ សង្កាត់ទុកជាឯកសារ និងជួយក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងការរៀបចំអនុវត្ត និងតាមដានវាយតម្លៃផែនការអភិវឌ្ឍឃុំ សង្កាត់

- **ការិយាល័យផែនការនិងគាំទ្រឃុំ សង្កាត់(ក្រុង ស្រុក) ឬការិយាល័យផែណការ និងហិរញ្ញវត្ថុ(ខណ្ឌ)៖** សហការ និងជួយក្រុមប្រឹក្សាក្នុងការវិភាគវាយតម្លៃ និងរៀបចំកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ សង្កាត់ សម្របសម្រួល និងប្រមូលឯកសារបញ្ជូនទៅអង្គភាពពាក់ព័ន្ធជួយនឹងគាំទ្រក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងការរៀបចំកសាងអនុវត្ត និងពិនិត្យនិងវាយតម្លៃកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ សង្កាត់
- **មន្ទីរជំនាញ និងអង្គភាពពាក់ព័ន្ធថ្នាក់រាជធានី ខេត្ត៖** ផ្តល់ជំនួយបច្ចេកទេសដែលពាក់ព័ន្ធនឹងជំនាញរបស់ខ្លួនដល់ការរៀបចំ និងការកសាងផែនការអភិវឌ្ឍឃុំ សង្កាត់ដូចជាយេនឌ័រការប្រែប្រួលអាកាសធាតុផ្តល់ការគាំទ្រគម្រោងសកម្មភាពវិនិយោគនានារបស់ឃុំ សង្កាត់នៅក្នុងសិក្ខាសាលាសមាហរណកម្មកម្មវិធីវិនិយោគនៅថ្នាក់ស្រុកនិងជួយរដ្ឋបាលរដ្ឋបាលឃុំ សង្កាត់ក្នុងការរៀបចំ និងអនុវត្តគម្រោង និងសកម្មភាពនានារបស់ឃុំ សង្កាត់
- **អង្គការសង្គមស៊ីវិល៖** តំណាងឲ្យផលប្រយោជន៍របស់សមាគមន៍មូលដ្ឋាន និងអ្នកពាក់ព័ន្ធណាមួយជាក់លាក់ (ស្ត្រី កុមារ យុវជន ។ល។) ព្រមទាំងចូលរួមផ្តល់ចំណេះដឹង និងគំនិតផ្សេងៗក្នុងការរៀបចំកម្មវិធីវិនិយោគ
- បីឆ្នាំរំកិលឃុំ សង្កាត់ និងចូលរួមក្នុងការពិភាក្សានិងពិគ្រោះយោបល់នានាដែលពាក់ព័ន្ធនឹងដំណើរការនៃការកសារកម្មវិធីវិនយោគឃុំ សង្កាត់
- **ប្រជាពលរដ្ឋ៖** ចូលរួមក្នុងកិច្ចប្រជុំពិគ្រោះយោបល់ដើម្បីកំណត់បញ្ហា និងតម្រូវការអាទិភាពនានាក្នុងសហគមន៍ និងមូលដ្ឋានរបស់ខ្លួនទៅតាមស្ថានភាពជាក់ស្តែងរបស់សាមីខ្លួនម្នាក់ៗ។

### ១.៥.៣. គោលការណ៍

ការរៀបចំ និងកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ សង្កាត់ត្រូវផ្អែកលើគោលការណសំខាន់ៗដូចខាងក្រោម៖[២០]

- ការចែករំលែកព័ត៌មាន
- តម្លាភាព
- សង្គតិភាព និងសុខដុមនីយកម្ម
- ការចូលរួមពិគ្រោះយោបល់ជាទូទៅ
- ការឆ្លើយតបនឹងតម្រូវការ

[២០] សេចក្តីណែនាំបច្ចេកទេសស្តីពី ការរៀបចំ និងកសាងផែនការអភិវឌ្ឍឃុំ សង្កាត់

- គណនេយ្យភាពតាមបែបប្រជាធិបតេយ្យ
- ប្រសិទ្ធភាព និងសុក្រឹតភាពសេដ្ឋកិច្ច និងសង្គម
- ការធានាចីរភាពធនធានធម្មជាតិ និងបរិស្ថាន
- ការធានាសមធម៌។

## ១.៦. ការគ្រប់គ្រងហិរញ្ញវត្ថុ និងលទ្ធកម្ម

មាត្រា៧៣ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់បានកំណត់ឲ្យរដ្ឋបាលឃុំ សង្កាត់មានហិរញ្ញវត្ថុ ថវិកា និងទ្រព្យសម្បត្តិផ្ទាល់ព្រមទាំងត្រូវរៀបចំនិងអនុម័តថវិកាប្រចាំឆ្នាំរបស់រដ្ឋបាលឃុំ សង្កាត់ផងដែរ។ [២១]

ជាមួយនេះនៅក្នុងការអនុវត្តថវិការដ្ឋបាលឃុំ សង្កាត់ក៏ត្រូវធ្វើលទ្ធកម្មលើទំនិញ និងសេវាកម្មមួយចំនួនតាមច្បាប់កំណត់។

### ១.៦.១. ប្រភពចំណូលរបស់ឃុំ សង្កាត់

ប្រភពចំណូលរបស់ឃុំ សង្កាត់សំខាន់ៗមាន០៣ គឺៈ[២២]

- ចំណូលផ្ទាល់
- ចំណូលពីថ្នាក់ជាតិ និង
- ចំណូលពីការអនុវត្តមុខងារជាភ្នាក់ងារ។

#### ១.៦.១.១. ចំណូលផ្ទាល់

ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់បានផ្តល់សិទ្ធិឲ្យឃុំ សង្កាត់ក្នុងការប្រមូលចំណូលផ្ទាល់ ដែលបានមកពីចំណូលសារពើពន្ធ និងចំណូលមិនមែនសារពើពន្ធ និងកម្រៃសេវាផ្សេងៗ។[២៣] ប្រភេទកម្រិត និងរបៀបនៃការប្រមូលចំណូលផ្ទាល់នេះត្រូវកំណត់ក្នុងច្បាប់ដោយឡែក។ យ៉ាងណាមិញបច្ចុប្បន្ននេះឃុំ សង្កាត់មិនអាចអនុវត្តការប្រមូលចំណូលផ្ទាល់នេះបានឡើយដោយហេតុថាមិនទាន់មានច្បាប់ស្តីពីការប្រមូលចំណូលនេះ។

#### ១.៦.១.២. ចំណូលពីថ្នាក់ជាតិ

បច្ចុប្បន្នរដ្ឋបាលឃុំ សង្កាត់ទទួលបានចំណូលពីថ្នាក់ជាតិតាមរយៈមូលនិធិឃុំ សង្កាត់ និងថវិកាបន្ថែមពីថ្នាក់ជាតិសម្រាប់ចំណាយអភិវឌ្ឍន៍មូលដ្ឋាន។

---

[២១] ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ត្រង់មាត្រា៧៣

[២២] សៀវភៅណែនាំស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ២០២២

[២៣] ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់

### ១.៦.១.៣. មូលនិធិឃុំ សង្កាត់

មូលនិធិឃុំ សង្កាត់គឺជាចំណូលដ៏សំខាន់របស់រដ្ឋបាលឃុំ សង្កាត់ដែលទទួលបានមកពីការផ្ទេរពីថវិកាជាតិ។ មូលនិធិឃុំ សង្កាត់ត្រូវបានកំណត់ជាភាគរយនៃចំណូលចរន្តថវិការដ្ឋតាមរយៈអនុក្រឹត្យរបស់រាជរដ្ឋាភិបាលដែលបានដាក់ចេញជារៀងរាល់យ៉ាងតិច០៣ឆ្នាំម្តង។ ក្នុងនោះអនុក្រឹត្យលេខ ៥១អនក្រ.បក ចុះថ្ងៃទី១១ ខែមេសា ឆ្នាំ២០១៨ ស្តីពីការផ្ទេរធនធានពីថវិការដ្ឋជូនមូលនិធិឃុំ សង្កាត់ សម្រាប់ចិរវេលា០៥ឆ្នាំ ពីឆ្នាំ២០១៩ ដល់ឆ្នាំ ២០២៣ បានកំណត់អំពីការផ្ទេរថវិការដ្ឋជូនមូលនិធិឃុំ សង្កាត់ដោយកំណត់ជាភាគរយនៃចំណូលថវិការដ្ឋដូចខាងក្រោមៈ[២៤]

- ឆ្នាំថវិកា២០១៩ ចំនួន ៣% នៃចំណូលចរន្តថវិកាជាតិ ដែលអនុម័តឆ្នាំ២០១៨
- ឆ្នាំថវិកា២០២០ ចំនួន ៣,១% នៃចំណូលចរន្តថវិកាជាតិ ដែលអនុម័តឆ្នាំ២០១៩
- ឆ្នាំថវិកា២០២១ ចំនួន ៣,២% នៃចំណូលចរន្តថវិកាជាតិ ដែលអនុម័តឆ្នាំ២០២០
- ឆ្នាំថវិកា២០២២ ចំនួន ៣,៣% នៃចំណូលចរន្តថវិកាជាតិ ដែលអនុម័តឆ្នាំ២០២១
- ឆ្នាំថវិកា២០២៣ ចំនួន ៣,៤% នៃចំណូលចរន្តថវិកាជាតិ ដែលអនុម័តឆ្នាំ២០២២។

ជាក់ស្តែងសម្រាប់ឆ្នាំ២០២២នេះ មូលនិធិឃុំ សង្កាត់ទទួលបាន ៣,៣% នៃចំណូលចរន្តថវិកា រដ្ឋអនុម័តឆ្នាំ ២០២១ ដែលមានទំហំទឹកប្រាក់ប្រមាណ ១៦០,៥៦៧,១៦១ដុល្លារអាមេរិក (៦៥០,២៩៧លានរៀល)។

មូលនិធិឃុំ សង្កាត់ត្រូវបានបែងចែងទៅរដ្ឋបាលឃុំ សង្កាត់នីមួយៗផ្អែកទៅលើចំណែកស្មើគ្នាចំនួនសមាជិកក្រុមប្រឹក្សា ចំនួនប្រជាពលរដ្ឋ និងសន្ទស្សន៍ភាពក្រីក្រទៅរូបមន្ត និងសន្ទស្សន៍ដូចខាងក្រោមៈ

**ចំណាយសម្រាប់ប្រតិបត្តិការរដ្ឋបាល**

- ចំនួន៣៥% ជាចំណែកស្មើគ្នា ត្រូវបានបែងចែកក្នុងចំនួនស្មើៗគ្នាសម្រាប់គ្រប់រដ្ឋបាលឃុំសង្កាត់
- ចំនួន៦៥% ត្រូវបានបែងចែកទៅតាមសមាមាត្រនៃចំនួនសមាជិកក្រុមប្រឹក្សារបស់រដ្ឋបាល ឃុំ សង្កាត់នីមួយៗ

**ចំណាយសម្រាប់អភិវឌ្ឍន៍មូលដ្ឋាន**

- ចំនួន៣០% ជាចំណែកស្មើគ្នាត្រូវបានបែងចែកក្នុងចំនួនស្មើៗគ្នាសម្រាប់គ្រប់ឃុំ សង្កាត់នីមួយៗ
- ចំនួន៣០% ត្រូវបានបែងចែកទៅតាមសមាមាត្រនៃចំនួនប្រជាពលរដ្ឋរបស់រដ្ឋបាលឃុំ សង្កាត់នីមួយៗ ដោយផ្អែកតាមទិន្នន័យផ្លូវការរបស់ក្រសួងផែនការ

[២៤] សៀវភៅណែនាំស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ២០២២

- ចំនួន៣០% ត្រូវបានបែងចែកទៅតាមសមាមាត្រនៃសន្ទស្សន៍ភាពក្រីក្រដោយផ្អែកតាមទិន្នន័យផ្លូវការរបស់ក្រសួងផែនការ
- ចំនួន១០% ត្រូវបានបែងចែកទៅតាមសមាមាត្រនៃចំនួនភូមិរបស់រដ្ឋបាលឃុំ សង្កាត់នីមួយៗដោយផ្អែកតាមទិន្នន័យផ្លូវការរបស់ក្រសួងមហាផ្ទៃ។

ជាគោលការណ៍ការប្រើប្រាស់ធនធានមូលនិធិឃុំ សង្កាត់សរុបប្រចាំឆ្នាំនីមួយៗត្រូវបានកំណត់ទៅតាមលំដាប់លំដោយនៃអាទិភាពចំណាយដូចខាងក្រោម៖

- ចំណាយសរុបសម្រាប់ប្រាក់ឧបត្ថម្ភរបស់សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ និងមន្ត្រីភូមិចំណាយសរុបសម្រាប់ប្រតិបត្តិការរដ្ឋបាលដែលមិនឲ្យលើសពី១៧%នៃធនធានមូលនិធិឃុំ សង្កាត់សរុបដកនឹងចំណាយសរុបសម្រាប់ប្រាប់ឧបត្ថម្ភរបស់សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ និងមន្ត្រីភូមិ
- ចំណាយសម្រាប់អភិវឌ្ឍន៍មូលដ្ឋានស្មើនឹងធនធានមូលនិធិឃុំ សង្កាត់សរុបដកនឹងចំណាយសរុបសម្រាប់ឧបត្ថម្ភរបស់សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ មន្ត្រីភូមិ និងចំណាយ សរុបសម្រាប់ប្រតិបត្តិការរដ្ឋបាល។

#### ១.៦.១.៤. ធនធានបន្ថែមពីថវិការដ្ឋសម្រាប់ចំណាយអភិវឌ្ឍន៍មូលដ្ឋាន

ក្រៅពីចំណូលទទួលបានពីថ្នាក់ជាតិតាមរយៈមូលនិធិឃុំ សង្កាត់ដើម្បីជំរុញការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋានរាជរដ្ឋាភិបាលក៏បានផ្តល់ធនធានបន្ថែមពីថវិការដ្ឋជូនរដ្ឋបាលឃុំ សង្កាត់សម្រាប់ចំណាយអភិវឌ្ឍន៍មូលដ្ឋាន (លើកលែងតែសង្កាត់ក្នុងរាជធានីភ្នំពេញ)។ ផ្អែកតាមអនុក្រឹត្យ លេខ១២១ អនក្រ.បក ចុះថ្ងៃ២១ ខែសីហា ឆ្នាំ២០១៩ ស្តីពីការផ្ទេរធនធានបន្ថែមពីថវិការដ្ឋជូនរដ្ឋបាលឃុំ សង្កាត់ សម្រាប់ចំណាយអភិវឌ្ឍន៍មូលដ្ឋានទំហំធនធានបន្ថែមដែលត្រូវផ្តល់ជូនរដ្ឋបាលឃុំ សង្កាត់សម្រាប់ចិរវេលា០៤ឆ្នាំចាប់ពីឆ្នាំ២០២០ ដល់ឆ្នាំ២០២៣ ត្រូវបានកំណត់ ដូចខាងក្រោម៖[២៥]

- ឆ្នាំថវិកា២០២០ ចំនួន ១% នៃចំណូលចរន្តថវិកាជាតិ ដែលអនុម័តឆ្នាំ២០១៩
- ឆ្នាំថវិកា២០២១ ចំនួន ១% នៃចំណូលចរន្តថវិកាជាតិ ដែលអនុម័តឆ្នាំ២០២០
- ឆ្នាំថវិកា២០២២ ចំនួន ១% នៃចំណូលចរន្តថវិកាជាតិ ដែលអនុម័តឆ្នាំ២០២១
- ឆ្នាំថវិកា២០២៣ ចំនួន ១% នៃចំណូលចរន្តថវិកាជាតិ ដែលអនុម័តឆ្នាំ២០២២។

ជាក់ស្តែង សម្រាប់ឆ្នាំ២០២២នេះ ធនធានបន្ថែម ១% នៃចំណូលចរន្តថវិកាជាតិអនុម័តឆ្នាំ២០២១ ដែលមានទំហំទឹកប្រាក់ប្រមាណ ៤,៧០៦,០០០ដុល្លារអាមេរិក (១៩៧,០៥៩លានរៀល)

[២៥] អនុក្រឹត្យស្តីពី ការផ្ទេរធនធានបន្ថែមពីថវិការដ្ឋជូនរដ្ឋបាលឃុំ សង្កាត់សម្រាប់ចំណាយអភិវឌ្ឍន៍មូលដ្ឋាន

ធនធានបន្ថែមនេះត្រូវបានបែងចែកដល់ឃុំ សង្កាត់នីមួយៗតាមការគណនាដោយផ្អែកលើរូបមន្ត និងសន្ទស្សន៍ដូចខាងក្រោម៖

- ចំនួន៣០% ជាចំណែកស្មើគ្នា ត្រូវបានបែងចែកក្នុងចំនួនស្មើៗគ្នាសម្រាប់គ្រប់ឃុំ សង្កាត់ នីមួយៗ
- ចំនួន៣០% ត្រូវបានបែងចែកទៅតាមសមាមាត្រនៃចំនួនប្រជាពលរដ្ឋរបស់រដ្ឋបាលឃុំ សង្កាត់នីមួយៗ ដោយផ្អែកតាមទិន្នន័យផ្លូវការរបស់ក្រសួងផែនការ
- ចំនួន៣០% ត្រូវបានបែងចែកទៅតាមសមាមាត្រនៃសន្ទស្សន៍ភាពក្រីក្រដោយផ្អែកតាមទិន្នន័យផ្លូវការរបស់ក្រសួងផែនការ
- ចំនួន១០% ត្រូវបានបែងចែកទៅតាមសមាមាត្រនៃចំនួនភូមិរបស់រដ្ឋបាលឃុំ សង្កាត់នីមួយៗដោយផ្អែកតាមទិន្នន័យផ្លូវការរបស់ក្រសួងមហាផ្ទៃ។

### ១.៦.២. ចំណូលពីការអនុវត្តមុខងារជាភ្នាក់ងារ

ចំណូលក្នុងការអនុវត្តមុខងារជាភ្នាក់ងារគឺជាចំណូលដែលបានមកពីការបំពេញភារកិច្ចដោយឃុំ សង្កាត់ជំនួសមុខឲ្យក្រសួង ស្ថាប័ន ឬអង្គភាពនានារបស់រដ្ឋទៅតាមការព្រមព្រៀងគ្នា។

ក្រៅពីចំណូលសំខាន់ៗទាំងបីខាងលើឃុំ សង្កាត់មានចំណូលផ្សេងៗទៀតដូចជា៖

- ចំណូលទទួលបានពីការចូលរួមចំណែករបស់ប្រជាពលរដ្ឋមូលដ្ឋាន
- ចំណូលទទួលបានពីអង្គការមិនមែនរដ្ឋាភិបាល និងកម្មវិធីនានា។

### ១.៦.៣. ប្រព័ន្ធទូទាត់ និងគណនេយ្យឃុំ សង្កាត់

ក្នុងដំណើរការនៃការគ្រប់គ្រងថវិការដ្ឋបាលឃុំ សង្កាត់មានប្រព័ន្ធទូទាត់ និងប្រព័ន្ធគណនេយ្យ ដូចខាងក្រោម៖

#### ១.៦.៣.១. គោលការណ៍ទូទៅ

គោលការណ៍ទូទៅរួមមានដូចខាងក្រោម៖

- ឃុំ សង្កាត់ត្រូវបើកគណនីប្រាក់បញ្ញើនៅរតនាគាររាជធានី ខេត្ត
- មេឃុំ ចៅសង្កាត់ជាអាណាប័ក និងមានសិទ្ធិពេញលេញលើការប្រមូល ឬការទទួលចំណូលការអនុវត្តចំណាយ និងការចេញអាណត្តិបើកប្រាក់ផ្អែកលើថវិកាដែលបានអនុម័ត
- មេឃុំ ចៅសង្កាត់អាចផ្ទេរសិទ្ធិក្នុងការសម្រេចលើថវិកាឲ្យជំទប់ ចៅសង្កាត់រងរដ្ឋបាលឃុំ សង្កាត់។ ការផ្ទេរសិទ្ធិជាអាណាប័កនេះត្រូវធ្វើសកម្មភាពដោយស្ថិតនៅក្រោមការទទួលខុសត្រូវ និងត្រួតពិនិត្យរបស់មេឃុំ ចៅសង្កាត់
- មេឃុំ ចៅសង្កាត់ និងអ្នកទទួលសិទ្ធិត្រូវតែតម្កល់គំរូហត្ថលេខាជាផ្លូវការនៅរតនាគារ រាជធានី ខេត្ត

- មេឃុំ ចៅសង្កាត់ និងអ្នកទទួលសិទ្ធិព្រមទាំងបុគ្គលិករដ្ឋបាលឃុំ សង្កាត់ជាទូទៅមិនត្រូវបានអនុញ្ញាតឲ្យកាន់កាប់មូលនិធិ ឬធ្វើការទូទាត់ចំណាយលើកលែងតែក្នុងករណីទូទាត់រជ្ជទេយ្យបុរេប្រទាន
- ចំណូលដែលប្រមូលបានដោយភ្នាក់ងារប្រមូលចំណូលសិទ្ធិបញ្ចាចំណាយ និងការទូទាត់មិនត្រូវប្រគល់ឲ្យមនុស្សតែម្នាក់បានឡើយរតនាគាររាជធានី ខេត្តបំពេញមុខងារជាគណនេយ្យករឃុំ សង្កាត់។

**១.៦.៣.២. ប្រព័ន្ធទូទាត់**

ប្រព័ន្ធទូទាត់មានដូចខាងក្រោម៖

- ការទូទាត់ផ្ទាល់ជាការទូទាត់តាមរយៈរតនាគាររាជធានី ខេត្ត
- ការទូទាត់តាមរយៈរជ្ជទេយ្យបុរេប្រទានសំដៅដល់ការទូទាត់ដែលមានចំនួនទឹកប្រាក់សម្រាប់មួយគោលការណ៍ចំណាយ ឬមួយប័ណ្ណចំណាយនៃរជ្ជទេយ្យបុរេប្រទានដែលមានទំហំទឹកប្រាក់យ៉ាងច្រើនបំផុតត្រឹម ៥០០,០០០រៀល (ប្រាំរយពាន់រៀល)។

## ១.៦.៤. ប្រព័ន្ធគណនេយ្យ

គណនេយ្យឃុំ សង្កាត់រួមមានគណនេយ្យហិរញ្ញវត្ថុ និងគណនេយ្យថវិកា៖

- គណនេយ្យហិរញ្ញវត្ថុគឺគណនេយ្យករនៅតាមរតនាគាររាជធានី ខេត្តមានភារកិច្ចអនុវត្តគណនេយ្យហិរញ្ញវត្ថុ។ គណនេយ្យហិរញ្ញវត្ថុ គឺជាប្រព័ន្ធផ្អែកលើមូលដ្ឋានសាច់ប្រាក់ដែលក្នុងនោះ៖
- ចំណូលត្រូវកត់ត្រាទៅក្នុងបញ្ជីគណនេយ្យនៅពេលទទួលបានសាច់ប្រាក់
- ចំណាយត្រូវកត់ត្រាទៅក្នុងប្រព័ន្ធគណនេយ្យនៅពេលទូទាត់
- គណនេយ្យថវិកាគឺមេឃុំ ចៅសង្កាត់មានភារកិច្ចទទួលខុសត្រូវក្នុងការអនុវត្តគណនេយ្យថវិកា។ គណនេយ្យថវិកាគឺជាការតាមដាន និងរាយការណ៍អំពី ៖
    - ការអនុវត្តចំណាយថវិកាដែលបានអនុម័ត
    - ការប្រមូលចំណូលថវិកាដែលបានអនុម័ត។

## ១.៦.៥. ថវិកាឃុំ សង្កាត់

ថវិកាឃុំ សង្កាត់គឺជាលិខិតគតិយុត្តដែលគ្រោង និងអនុញ្ញាតចំណូល និងចំណាយផ្អែកលើមូលដ្ឋានឆ្នាំ។ ឆ្នាំថវិការបស់ឃុំ សង្កាត់គិតចាប់ពីថ្ងៃទី ០១ ខែ មករា និងបញ្ចប់នៅថ្ងៃទី ៣១ខែធ្នូ។[២៦] ក្នុងនោះគោលការណ៍សំខាន់ៗនៃការរៀបចំគម្រោងថវិកា និងបែបបទនីតិវិធីនៃការរៀបចំ និងអនុម័តថវិកាត្រូវបានកំណត់ដូចខាងក្រោម៖

[២៦] មាត្រា៣ នៃអនុក្រឹត្យស្តីពីប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុឃុំ សង្កាត់

**១.៦.៥.១. គោលការណ៍ថវិកាសំខាន់ៗនៃការរៀបចំគម្រោងថវិកាឃុំ សង្កាត់**

- គម្រោងថវិកាឃុំ សង្កាត់ត្រូវរៀបចំនិងអនុម័តប្រចាំឆ្នាំថវិកា ចាប់ផ្តើមពីថ្ងៃទី០១ ខែមករា និងបញ្ចប់នៅថ្ងៃទី៣១ ខែធ្នូ
- ថវិកាត្រូវតែតុល្យភាពដែលមានន័យថាផែនការចំណាយសរុបត្រូវតែរ៉ាប់រងពេញលេញដោយផែនការចំណូលសរុប
- ថវិកាឃុំ សង្កាត់ត្រូវឆ្លុះបញ្ចាំងចំណាយជាអាទិភាពរបស់ផែនការអភិវឌ្ឍឃុំ សង្កាត់។

**១.៦.៥.២. ការរៀបចំ និងការអនុម័តគម្រោងថវិកា**

ជាគោលការណ៍រដ្ឋបាលឃុំ សង្កាត់ពុំតម្រូវឲ្យរៀបចំផែនការយុទ្ធសាស្ត្រថវិកាទេ ប៉ុន្តែការរៀបចំ គម្រោងថវិកាប្រចាំឆ្នាំរបស់រដ្ឋបាលទាំងនេះគឺផ្អែកលើផែនការអភិវឌ្ឍ និងកម្មវិធីវិនិយោគ០៣ឆ្នាំរំកិលរបស់រដ្ឋបាលឃុំ សង្កាត់នីមួយៗ។

ការរៀបចំគម្រោងថវិការបស់រដ្ឋបាលឃុំ សង្កាត់ត្រូវរៀបចំឡើងក្រោមការទទួលខុសត្រូវរបស់មេឃុំ ចៅសង្កាត់ និងដោយមានជំនួយការពីគណៈកម្មាធិការកសាងផែនការ និងថវិកាឃុំ សង្កាត់ (គ.ជ.ថ) ហើយត្រូវបញ្ជូនទៅក្រុមប្រឹក្សាឃុំ សង្កាត់ ពិនិត្យ និងអនុម័ត។ ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវអនុម័តគម្រោងថវិកានាកិច្ចប្រជុំជាសាធារណៈឲ្យបានមុនថ្ងៃទី៣១ ខែតុលា តាមផ្នែកនឹងតាមប្រភេទនីមួយៗបន្ទាប់មកបញ្ជូនទៅរាជធានីខេត្តឲ្យបានមុនថ្ងៃទី០៥ ខែវិច្ឆិកាដើម្បីបញ្ជាក់ទទួលស្គាល់។ ហើយអភិបាលរាជធានី ខេត្តត្រូវត្រួតពិនិត្យអនុលោមភាព និងបញ្ជាក់ទទួលស្គាល់លើគម្រោងថវិកាឲ្យបានមុនថ្ងៃទី៣០ ខែវិច្ឆិកា។

ការរៀបចំគម្រោងថវិកានេះត្រូវរៀបចំឡើងដោយឈរលើមូលដ្ឋានកំណើនប្រចាំឆ្នាំដោយផ្អែកលើចំណូលថវិកាដែលបានពីការផ្ទេរពីថ្នាក់ជាតិចំណូលផ្ទាល់របស់រដ្ឋបាលនីមួយៗតម្រូវការអភិវឌ្ឍជាអាទិភាពគោលនយោបាយតម្លើងប្រាក់បៀវត្ស និងប្រាក់ឧបត្ថម្ភរបស់រាជរដ្ឋាភិបាលក៏ដូចកំណើនបុគ្គលិកមន្ត្រីរាជការ។ រដ្ឋបាលឃុំ សង្កាត់ត្រូវធ្វើរបាយការណ៍បូកសរុបអនុវត្តចំណូលចំណាយថវិការបស់ខ្លួនជាប្រចាំខែ ត្រីមាស ឆមាស និងដំណាច់ឆ្នាំទៅអភិបាលខេត្ត និងមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

ប្រសិនបើគម្រោងថវិកាត្រូវបានបំពេញតាមលក្ខខណ្ឌនៃការត្រួតពិនិត្យ និងអនុលោមភាពនោះអភិបាលរាជធានីខេត្តត្រូវបញ្ជាក់ការទទួលស្គាល់លើគម្រោងថវិកាដោយចេញសេចក្តីជូនដំណឹងជាលាយល័ក្ខអក្សរជូនមេឃុំ ចៅសង្កាត់។ សេចក្តីជូនដំណឹងត្រូវភ្ជាប់មកជាមួយឯកសារថវិកាដែលមានហត្ថលេខាសង្ខេបរបស់អភិបាលរាជធានីខេត្ត និងបោះត្រាលើទំព័រនីមួយៗ។ អភិបាលរាជធានីខេត្តត្រូវចម្លងជូនសេចក្តីជូនដំណឹងព្រមទាំងថវិកាដែលបានបញ្ជាក់ទទួលស្គាល់ទៅមន្ទីរ សេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងរតនាគាររាជធានីខេត្ត។

### ១.៦.៦. ការអនុវត្តថវិកាឃុំ សង្កាត់

ការអនុវត្តថវិកាឃុំ សង្កាត់រួមមានការងារដូចខាងក្រោម៖

- **ការកែតម្រូវថវិកា៖** ថវិកាឃុំ សង្កាត់អាចនឹងកែតម្រូវក្នុងឆ្នាំថវិកាដោយសារមានការផ្លាស់ប្តូរសភាពការណ៍សេដ្ឋកិច្ច និងហិរញ្ញវត្ថុដែលជះឥទ្ធិពលដល់ការព្យាករណ៍ដំបូងនៃចំណូល និងចំណាយដោយសេចក្តីព្រាងថវិកាកែតម្រូវត្រូវរៀបចំអនុម័តឲ្យស្របតាមនីតិវិធីចំណាយរបស់ថវិកាដំបូង។ ក្នុងនោះជំហានសំខាន់ៗមានដូចខាងក្រោម៖
  - មេឃុំ ចៅសង្កាត់រៀបចំ និងស្នើឡើងថវិកាកែតម្រូវដល់រដ្ឋបាលឃុំ សង្កាត់
  - ក្រុមប្រឹក្សាឃុំ សង្កាត់ពិភាក្សា និងអនុម័តថវិកាកែតម្រូវ
  - អភិបាលរាជធានី ខេត្តត្រួតពិនិត្យឡើងវិញ និងបញ្ជាក់ទទួលស្គាល់ថវិកាកែតម្រូវ។ យ៉ាងណាមិញ ប្រសិនបើគោលបំណងនៃការកែតម្រូវគ្រាន់តែជាការវិភាជន៍ ធនធានឡើងវិញក្នុងប្រភេទតែមួយ ឬក៏មិនមានផ្លាស់ប្តូរប្រភេទនៃគម្រោងវិនិយោគទេនោះ គឺពុំចាំបាច់សុំការបញ្ជាក់ទទួលស្គាល់ឡើងវិញពីអភិបាលរាជធានីខេត្តទេប៉ុន្តែត្រូវជំនួសវិញដោយការជូនដំណឹងជាលាយលក្ខណ៍អក្សរឲ្យបាន ០៥ថ្ងៃការងារបន្ទាប់ពីការពិភាក្សានិងអនុម័តរបស់ក្រុមប្រឹក្សា។
- **ការកំណត់តម្លៃ និងប្រមូលចំណូល ៖** ចំណូលផ្ទាល់របស់ឃុំ សង្កាត់ត្រូវកំណត់ និងប្រមូលតាមបទប្បញ្ញត្តិច្បាប់ដោយឡែក។ ដូចបានបញ្ជាក់ខាងលើបច្ចុប្បន្ននេះឃុំ សង្កាត់មិនអាចអនុវត្តការប្រមូលចំណូលផ្ទាល់បានឡើយដោយហេតុថាមិនទាន់មានច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធការប្រមូលចំណូល
- **ខួបនៃការចំណាយ៖** ឃុំ សង្កាត់ត្រូវអនុវត្តតាមដំណាក់កាលដូចខាងក្រោម៖
  - ការសន្យាចំណាយ
  - ការជម្រះបញ្ជី
  - ការចេញអាណត្តិបើកប្រាក់ និង
  - ការទូទាត់។

សម្រាប់ការពន្យល់លម្អិតសូមមើលអនុក្រឹត្យលេខ២៦ អនក្រ.បក ចុះថ្ងៃទី០២ ខែមេសា ឆ្នាំ២០០២ ស្តីពីប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុឃុំ សង្កាត់។

- របាយការណ៍អំពីលទ្ធផលនៃការអនុវត្តថវិកា៖ ឃុំ សង្កាត់ត្រូវធ្វើរបាយការណ៍ស្តីពីការអនុវត្តថវិកាតាមប្រតិទិន និងនីតិវិធីដែលបានបញ្ជាក់ក្នុងប្រកាសណែនាំស្តីពីប្រព័ន្ធទូទាត់ និងគណនេយ្យរបស់ឃុំ សង្កាត់

- ការបិទបញ្ជីថវិកាឃុំ សង្កាត់ ៖ នៅដំណាច់ឆ្នាំថវិកាឃុំ សង្កាត់ត្រូវបិទបញ្ជីថវិកាតាមនីតិវិធីដូចខាងក្រោម៖
  - គណនេយ្យករឃុំ សង្កាត់ត្រូវរៀបចំសេចក្តីព្រាងរបាយការណ៍បិទបញ្ជីគណនេយ្យ
  - គណនេយ្យករត្រូវដាក់សេចក្តីព្រាយរបាយការណ៍បិទបញ្ជីគណនេយ្យដល់មេឃុំ ចៅសង្កាត់ដើម្បីផ្ទៀងផ្ទាត់ជាមួយរបាយការណ៍អនុវត្តថវិការបស់រដ្ឋបាលឃុំ សង្កាត់
  - មេឃុំ ចៅសង្កាត់ត្រូវបញ្ជូនសេចក្តីព្រាងរបាយការណ៍បិទបញ្ជីគណនេយ្យទៅក្រុមប្រឹក្សាឃុំ សង្កាត់ដើម្បីពិនិត្យ និងអនុម័តក្នុងខែមីនា នៃឆ្នាំបន្ទាប់។ បន្ទាប់ពីការពិភាក្សាក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវបោះឆ្នោតអនុម័តលើសេចក្តីសម្រេចបិទបញ្ជី ថវិកា
  - មេឃុំ ចៅសង្កាត់ត្រូវបញ្ជូនសេចក្តីសម្រេចស្តីពីការបិទបញ្ជីថវិកាដល់អភិបាលរាជធានីខេត្តដើម្បីបញ្ជាក់ទទួលស្គាល់ឲ្យបានមុនមួយសប្តាហ៍បន្ទាប់ពីការប្រជុំពិភាក្សារបស់ក្រុមប្រឹក្សាឃុំ សង្កាត់
  - អភិបាលរាជធានី ខេត្តពិនិត្យ និងបញ្ជាក់ទទួលស្គាល់លើសេចក្តីសម្រេចស្តីពីការបិទបញ្ជីថវិកា។

### ១.៦.៧. របាយការណ៍ហិរញ្ញវត្ថុឃុំ សង្កាត់

របាយការណ៍ហិរញ្ញវត្ថុធ្វើឡើងក្នុងគោលបំណងដូចខាងក្រោម៖

- តាមដានប្រតិបត្តិការចំណូល និងចំណាយរបស់ឃុំ សង្កាត់ដោយប្រៀបធៀបជាមួយការព្យាករណ៍ថវិកា
- វាយតម្លៃស្ថានភាពហិរញ្ញវត្ថុរបស់ឃុំ សង្កាត់ដោយផ្តល់ព័ត៌មានអំពីប្រភព និងការប្រើប្រាស់ធនធានហិរញ្ញវត្ថុ
- បង្កលក្ខណៈដល់មេឃុំ ចៅសង្កាត់ក្នុងការទទួលខុសត្រូវចំពោះក្រុមប្រឹក្សាឃុំ សង្កាត់ដែលទទួលខុសត្រូវចំពោះប្រជាពលរដ្ឋ និងអាជ្ញាធរថ្នាក់លើ
- ឆ្លុះបញ្ចាំងឲ្យឃើញថាកិច្ចប្រតិបត្តិការឆ្លើយតបបានទៅនឹងថវិកាដែលបានអនុម័តនិងបទប្បញ្ញត្តិគតិយុត្តិផ្សេងទៀត។[២៧]

របាយការណ៍ហិរញ្ញវត្ថុឃុំ សង្កាត់មាន០៣ប្រភេទ ៖

១. របាយការណ៍ស្តីពីការអនុវត្តថវិកាប្រចាំខែដែលរបាយការណ៍នេះមានទម្រង់ជារបាយការណ៍ចំណូលចំណាយផ្អែកតាមមាតិកាថវិកា។ របាយការណ៍នេះត្រូវប្រៀបធៀបការអនុវត្តជាក់ស្តែងទៅនឹងការព្យាករណ៍ថវិកា និងបង្ហាញអំពីស្ថានភាពរតនៈវត្ថុរបស់ឃុំ សង្កាត់

២. របាយការណ៍ស្តីពីចំណូលចំណាយថវិកាប្រចាំឆមាស មានទម្រង់ដូចគ្នានឹងរបាយការណ៍ ប្រចាំខែ

[២៧] មាត្រា៣ នៃអនុក្រឹត្យស្តីពីប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុឃុំ សង្កាត់

៣. របាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ រួមមាន៖

- របាយការស្តីពីចំណូល ចំណាយប្រចាំឆ្នាំ
- ការផ្ទៀងផ្ទាត់គណនីប្រាក់បញ្ញើរបស់ឃុំ សង្កាត់នៅរតនាគារ
- របាយការណ៍ស្តីពីអចលនវត្ថុ។

របាយការណ៍ហិរញ្ញវត្ថុត្រូវរៀបចំឡើងដោយគណនេយ្យកររបស់ឃុំ សង្កាត់ និងត្រូវផ្ទៀងផ្ទាត់ជាមួយនឹងរបាយការណ៍គណនេយ្យថវិកាដែលគ្រប់គ្រងដោយរដ្ឋបាលឃុំ សង្កាត់ស្របទៅតាមប្រតិទិនដូចខាងក្រោម៖

- របាយការណ៍ប្រចាំខែត្រូវរៀបឲ្យបានមុនថ្ងៃទី១៥ នៃខែបន្ទាប់
- សាលាជាតិរដ្ឋបាលមូលដ្ឋាន (NASLA)
- របាយការណ៍ឆមាសត្រូវរៀបឲ្យបានមុនថ្ងៃទី២១ ខែកក្កដា
- របាយការណ៍ប្រចាំឆ្នាំត្រូវរៀបឲ្យបានមុនថ្ងៃទី៣១ ខែមករា នៃឆ្នាំបន្ទាប់
- មេឃុំ ចៅសង្កាត់ត្រូវពិនិត្យ និងឯកភាពទៅលើរបាយការណ៍ហិរញ្ញវត្ថុដែលបានរៀបចំដោយគណនេយ្យករ និងត្រូវផ្ញើជូនទៅក្រុមប្រឹក្សាឃុំ សង្កាត់ដើម្បីពិភាក្សា និងអនុម័តទាន់ពេលវេលាដោយភ្ជាប់នូវរបាយការណ៍លម្អិតអំពីសកម្មភាព។
- ក្រោយពីក្រុមប្រឹក្សាឃុំ សង្កាត់បានអនុម័តរួចមេឃុំ ចៅសង្កាត់ត្រូវ៖
  - ផ្ញើរបាយការណ៍ជូនអភិបាលរាជធានី ខេត្ត និងមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
  - ផ្សព្វផ្សាយជាសាធារណៈ។

### ១.៦.៨. ទ្រព្យសម្បត្តិឃុំ សង្កាត់

ទ្រព្យសម្បត្តិរបស់ឃុំ សង្កាត់រួមមានទ្រព្យសម្បត្តិដែលរាជរដ្ឋាភិបាលផ្ទេរឲ្យទ្រព្យសម្បត្តិដែលឃុំ សង្កាត់រកបានដោយខ្លួនឯង និងទ្រព្យសម្បត្តិដែលបានមកពីអំណោយផ្សេងៗ[២៨] រដ្ឋផ្ទេរ និងប្រគល់ឲ្យរដ្ឋបាលឃុំ សង្កាត់នូវសិទ្ធិកាន់កាប់ និងប្រើប្រាស់ទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងទ្រព្យសម្បត្តិឯកជនរបស់រដ្ឋមួយចំនួនដែលជាអចលនវត្ថុហើយស្ថិតនៅក្នុងដែនសមត្ថកិច្ចរបសស់ក្រុមប្រឹក្សា នីមួយៗទៅតាមការកំណត់របស់រដ្ឋ។

ឃុំ សង្កាត់ត្រូវរក្សាការកត់ត្រាដោយឡែកនូវប្រភេទទ្រព្យសម្បត្តិតាមប្រភេទនីមួយៗនូវព័ត៌មានដូចជាលេខរៀង ឬលេខកូដយថាប្រភេទកាលបរិច្ឆេទផ្ទេរសិទ្ធិឲ្យកាន់កាប់បរិមាណ និងតម្លៃទីតាំងដែលទ្រព្យសម្បត្តិនោះទុកដាក់ ឬប្រើប្រាស់ទៅក្នុងបញ្ជីទ្រព្យសម្បត្តិឲ្យបានត្រឹមត្រូវ។

[២៨] មាត្រា៤៩ នៃអនុក្រឹត្យស្តីពីប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុឃុំ សង្កាត់

### ១.៦.៩. កិច្ចលទ្ធកម្មឃុំ សង្កាត់

លទ្ធកម្មសំដៅដល់ការទិញ ឬការរកបាននូវទំនិញសំណង់ សេវាកម្ម ឬសេវាទីប្រឹក្សាតាមរយៈវិធីសាស្ត្រដែលមានចែងក្នុងច្បាប់ស្តីពីលទ្ធកម្មសាធារណៈ។[២៩]

កិច្ចលទ្ធកម្មគឺជាដំណើរការលទ្ធកម្មចាប់ពីពេលរៀបចំឯកសារដេញថ្លៃរហូតដល់ពេលទទួលបានទំនិញសំណង់ សេវាកម្ម ឬសេវាទីប្រឹក្សា។

#### ១.៦.៩.១. គោលការណ៍សំខាន់ៗនៃកិច្ចលទ្ធកម្ម

- លទ្ធកម្មសំណង់ លទ្ធកម្មសេវាកម្ម និងលទ្ធកម្មទំនិញត្រូវអនុវត្តក្នុងលក្ខណៈមួយដែលមាន
- តម្លាភាពប្រសិទ្ធភាព និងសន្សំសំចៃបំផុតតាមដែលអាចធ្វើទៅបានដោយធានាគុណភាព
- អ្នកទទួលការអ្នកផ្គត់សេវាកម្ម និងអ្នកផ្គត់ផ្គង់ត្រូវបានផ្តល់ឱកាសស្មើៗគ្នាដើម្បីចូលរួមនៅក្នុងដំណើរការដេញថ្លៃក្រោមលក្ខខណ្ឌយុត្តិធម៌ និងស្មើភាព
- លទ្ធផលនៃការដេញថ្លៃត្រូវផ្សព្វផ្សាយជាសាធារណៈ

#### ១.៦.៩.២. សមាសភាពគណៈកម្មការលទ្ធកម្ម

គណៈកម្មការលទ្ធកម្មត្រូវមានសមាសភាពដូចខាងក្រោម៖

- មេឃុំ ចៅសង្កាត់ ជាប្រធាន
- សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់០២រូប ជាសមាជិក
- ស្មៀនឃុំ សង្កាត់ លេខាធិកា

ប្រធានគណៈកម្មការលទ្ធកម្មអាចអញ្ជើញបុគ្គលមួយចំនួនចូលរួមជាអ្នកជំនួយការឬជាអ្នកសង្កេតការណ៍។ ក្នុងការប្រជុំពិភាក្សាការងាររបស់គណៈកម្មការលទ្ធកម្ម អ្នកជំនួយការ លេខាធិការ និងអ្នកសង្កេតការណ៍ពុំមានសិទ្ធិសម្រេចទេ។ គណៈកម្មការលទ្ធកម្មត្រូវធ្វើសេចក្តីសម្រេចដោយសម្លេងភាគច្រើន។[៣០]

- **វិធីសាស្ត្រលទ្ធកម្ម**
  - ការដេញថ្លៃដោយប្រកួតប្រជែងជាចំហ (ជាសាធារណៈ)
  - ការស្ទង់តម្លៃក្នុងស្រុក
  - ការទិញផ្ទាល់ ឬការចុះកិច្ចសន្យាផ្ទាល់ (ការចរចាតម្លៃផ្ទាល់)។

---

[២៩] ច្បាប់ស្តីពីលទ្ធកម្មសាធារណៈ

[៣០] អនុក្រឹត្យស្តីពីប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុឃុំ សង្កាត់ មាត្រា៤៧

### ១.៦.៩.៣. សវនកម្មគណនី និងសវនកម្មប្រតិបត្តិការរបស់ឃុំ សង្កាត់

សវនកម្មគឺសំដៅដល់ការធានាភាពជាក់លាក់ត្រឹមត្រូវនៃព័ត៌មានហិរញ្ញវត្ថុវាយតម្លៃនៃការអនុវត្តថវិការបស់ឃុំ សង្កាត់ប្រព័ន្ធគ្រប់គ្រង និងនីតិវិធី។ ហើយរបាយការណ៍សវនកម្មដែលមានរួមបញ្ចូលនូវមតិយោបល់របស់ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវផ្សព្វផ្សាយជាសាធារណៈ។

គណនី នឹងប្រតិបត្តិការរបស់ឃុំសង្កាត់អាចត្រូវធ្វើសវនកម្មដោយស្ថាប័នជាតិ ឬដោយសវនកម្មឯករាជ្យមិនមែនរដ្ឋាភិបាលតាមសំណូមពររបស់ម្ចាស់ជំនួយក្រៅប្រទេសដែលផ្តល់ហិរញ្ញប្បទានដល់ ឃុំ សង្កាត់។

មេឃុំ ចៅសង្កាត់ត្រូវធានាថាយន្តការត្រួតពិនិត្យផ្ទៃក្នុងដែលមានក្នុងប្រព័ន្ធគ្រប់គ្រងត្រូវបានអនុវត្តដើម្បីសម្រេចឲ្យបានតាមគោលដៅដូចខាងក្រោម៖

- ធនធានត្រូវបានប្រើប្រាស់ស្របតាមថវិកាដែលបានអនុម័តព្រមទាំងស្របតាមច្បាប់ និងបទបញ្ញាជាធរមាន
- ធនធានត្រូវបានទុកដាក់ហ្មត់ចត់មិនបាត់បង់ និងមិនប្រើប្រាស់ខុសគោលការណ៍
- ទិន្នន័យហិរញ្ញវត្ថុពិតប្រាកដត្រូវបានរៀបចំ និងលាតត្រដាងក្នុងរបាយការណ៍។[៣១]

## ១.៧. ការផ្តល់សេវាសាធារណៈ

សេវាសាធារណៈសំដៅដល់រាល់សកម្មភាពទាំងឡាយដែលធ្វើឡើងដោយស្ថាប័នមានសមត្ថកិច្ច និងស្ថាប័នទទួលសមត្ថកិច្ចក្នុងគោលដៅបម្រើផលប្រយោជន៍រួម ឬផលប្រយោជន៍សាធារណៈ។ ក្នុងនោះស្ថាប័នមានសមត្ថកិច្ចសំដៅដល់ស្ថាប័នរដ្ឋ ឬភ្នាក់ងាររដ្ឋឬអាជ្ញាធរគ្រប់លំដាប់ថ្នាក់ទាំងអស់របស់រដ្ឋដែលបំពេញការងារតាមដែនសមត្ថកិច្ចរបស់ខ្លួន។ ដោយឡែកស្ថាប័នទទួលសមត្ថកិច្ចសំដៅដល់ផ្នែកឯកជន និងសង្គមស៊ីវិលដែលទទួលបានសិទ្ធិនិងភារកិច្ចពីរដ្ឋហើយស្ថិតក្រោមការគ្រប់គ្រង និងត្រួតពិនិត្យរបស់រដ្ឋ ឬភ្នាក់ងាររដ្ឋ។[៣២]

រដ្ឋបាលឃុំ សង្កាត់គឺជាស្ថាប័នមានសមត្ថកិច្ចមួយដែលដឹកនាំដោយក្រុមប្រឹក្សាកើតពីការបោះឆ្នោតដោយផ្ទាល់ពីប្រជាពលរដ្ឋក្នុងមូលដ្ឋានរបស់ខ្លួន។ ក្នុងន័យនេះ ក្រុមប្រឹក្សាឃុំ សង្កាត់មានសមត្ថកិច្ចផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋ។ ក្របខ័ណ្ឌច្បាប់ និងលិខិតបទដ្ឋានគតិយុត្តសំខាន់ៗដែលកំណត់អំពីការផ្តល់សេវាសាធារណៈដោយរដ្ឋបាលឃុំ សង្កាត់មានដូចជា៖

- ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់

[៣១] អនុក្រឹត្យស្តីពីប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុឃុំ សង្កាត់ មាត្រា៥៥

[៣២] គោលនយោបាយស្តីពីការផ្តល់សេវាធារណៈ អនុម័តដោយគណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គ ថ្ងៃទី០៥ ឧសភា ២០០៦

- អនុក្រឹត្យលេខ២២អនក្រ.បក ចុះថ្ងៃទី២៥ ខែមីនា ឆ្នាំ២០០២ ស្តីពីការផ្ទេរមជ្ឈការអំណាច តួនាទី និងភារកិច្ចទៅឲ្យក្រុមប្រឹក្សាឃុំ សង្កាត់
- គោលនយោបាយភូមិ ឃុំ សង្កាត់មានសុវត្ថិភាព ឆ្នាំ២០២១
- អនុក្រឹត្យលេខ១៨ អនក្រ.បក ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១៧ ស្តីពីការបង្កើតយន្តការច្រកចេញចូលតែមួយនៅរដ្ឋបាលថ្នាក់ក្រោមជាតិ
- ប្រកាសលេខ៣៨៤០ ប្រក ចុះថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០២០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់
- សេចក្តីណែនាំលេខ០១៨ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០២២ របស់ក្រសួងមហាផ្ទៃស្តីពីបែបបទ និងនីតិវិធីនៃការផ្តល់សេវារដ្ឋបាលតាមយន្តការច្រកចេញចូលតែមួយនៃរដ្ឋបាលឃុំ សង្កាត់
- លិខិតបទដ្ឋាន និងឯកសារពាក់ព័ន្ធផ្សេងៗទៀត។

ផ្អែកតាមលិខិតបទដ្ឋានខាងលើការផ្តល់សេវាសាធារណៈដោយរដ្ឋបាលឃុំ សង្កាត់ជារួមអាចធ្វើការបែងចែកដូចខាងក្រោម៖

**សេវារដ្ឋបាល**

- ការងារអត្រានុកូលដ្ឋាន
- ការចេញលិខិតបញ្ជាក់
- ការសម្របសម្រួលពាក់ព័ន្ធការងារបោះឆ្នោត
- ការអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋាន
- ការងារសង្គមកិច្ច
- ការងារសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងសុវត្ថិភាពសង្គម
- ការងារបរិស្ថាន និងអន្តរវិស័យ។

### ១.៧.១. ប្រភេទនៃសេវាសាធារណៈ

សេវាសាធារណៈដូចបានកំណត់ន័យខាងលើ និងដែលមានចែងក្នុងគោលនយោបាយនេះត្រូវបានចងក្រង និងប្រមូលផ្តុំជា ៧ ប្រភេទធំៗទៅតាមវិស័យ និងការទទួលខុសត្រូវរបស់ក្រសួង ស្ថាប័នដូចខាងក្រោម៖[៣៣]

[៣៣] គោលនយោបាយស្តីពីការផ្តល់សេវាសាធារណៈ អនុម័តដោយគណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គ ថ្ងៃទី០៥ ឧសភា ២០០៦

**ក. ចង្កោមសេវាពាក់ព័ន្ធនឹងអធិបតេយ្យភាពរដ្ឋ**

ចង្កោមសេវាពាក់ព័ន្ធនឹងអធិបតេយ្យភាពរដ្ឋ គឺជាសេវាទទួលខុសត្រូវផ្ដាច់មុខរបស់រដ្ឋដែលផ្ដល់ដោយអង្គភាពរដ្ឋ ឬនីតិបុគ្គលនៃនីតិសាធារណៈដែលរដ្ឋបានប្រគល់សិទ្ធិអំណាចឲ្យដើម្បីអនុវត្ត ។ ចង្កោមសេវាពាក់ព័ន្ធនឹងអធិបតេយ្យភាពរដ្ឋមានដូចជា លិខិតអនុញ្ញាត អាជ្ញាប័ណ្ណ បញ្ជីអត្រានុកូលដ្ឋាន សំបុត្របញ្ជាក់កំណើត ប័ណ្ណសំគាល់យានយន្ត អាកាស យាន និងនាវា វិញ្ញាប័ណ្ណប័ត្រទទួលស្គាល់កម្មសិទ្ធិអត្តសញ្ញាណប័ណ្ណប្រជាពលរដ្ឋខ្មែរ សៀវភៅគ្រួសារ ការធ្វើនីត្យានុកូលកម្មជាដើម ។

ពាក់ព័ន្ធទៅនឹងចង្កោមនៃសេវាសាធារណៈនេះការរៀបចំ និងការប្រតិបត្តិការនៃការផ្ដល់សេវាត្រូវទទួលខុសត្រូវដោយរដ្ឋ ឬភ្នាក់ងាររបស់រដ្ឋ ។

**ខ. ចង្កោមសេវាពាក់ព័ន្ធនឹងផ្នែកសន្តិសុខសណ្ដាប់ធ្នាប់សាធារណៈ និងសុវត្ថិភាពសង្គម**

ចង្កោមសេវាពាក់ព័ន្ធផ្នែកសន្តិសុខសណ្ដាប់ធ្នាប់សាធារណៈការស្នាក់នៅការធ្វើដំណើរការប្រាស្រ័យទាក់ទងរបស់ប្រជាពលរដ្ឋ និងសុវត្ថិភាពសង្គមគឺជាសមត្ថកិច្ចរបស់អាជ្ញាធរមានសមត្ថកិច្ចនគរបាលជាតិ កងរាជអាវុធហត្ថ និងកងយោធពលខេមរភូមិន្ទគ្រប់លំដាប់ថ្នាក់ទូទាំងប្រទេស ។ ចង្កោមសេវានេះជាសេវាដ៏ចាំបាច់ និងមិនអាចខ្វះបានដើម្បីធានាបរិយាកាសល្អដល់ការអភិវឌ្ឍសង្គមជាតិការកាត់បន្ថយភាពក្រីក្រ ភាពសុខសាន្តរបស់ប្រជាពលរដ្ឋ និងជាទំនុកចិត្តដល់វិនិយោគិន ធុរជនក្នុងការប្រកបរបរអាជីវកម្ម និងជំនួញជួញដូរ ។

ពាក់ព័ន្ធទៅនឹងចង្កោមនៃសេវាសាធារណៈនេះការរៀបចំ និងការប្រតិបត្តិការនៃការផ្ដល់សេវាត្រូវធ្វើឡើងដោយរដ្ឋ ឬភ្នាក់ងាររបស់រដ្ឋ ។

**គ. ចង្កោមសេវាពាក់ព័ន្ធនឹងយុត្តិធម៌ និងអាជ្ញាកណ្ដាល**

ចង្កោមសេវាពាក់ព័ន្ធនឹងយុត្តិធម៌ និងអាជ្ញាកណ្ដាលដូចជាវិវាទរវាងប្រជាពលរដ្ឋ និង ប្រជាពលរដ្ឋ ឬរវាងប្រជាពលរដ្ឋ និង អ្នករាជការ ឬ រវាងប្រជាពលរដ្ឋ និងផ្នែកឯកជន ឬរវាងអ្នករាជការ និង ផ្នែកឯកជនជាដើម សេវាដោះស្រាយវិវាទនេះធ្វើឡើងតាម រូបភាព ២ យ៉ាង :

- តាមរយៈក្រុមប្រឹក្សាអាជ្ញាកណ្ដាលដែលជាអ្នកសម្របសម្រួល និង ដោះស្រាយចំពោះករណីវិវាទមិនធ្ងន់ធ្ងរដើម្បីសម្រួលដល់គូភាគីទាំងសងខាងដោយមិនចាំបាច់ពឹងផ្អែកតែទៅលើតុលាការ និងកាត់បន្ថយការកកស្ទះសំណុំរឿងនៅតុលាការ ។
- ក្នុងករណីគូភាគីវិវាទមិនទទួលយកនូវដំណោះស្រាយរបស់ក្រុមប្រឹក្សាអាជ្ញាកណ្ដាលទេនោះការដោះស្រាយវិវាទត្រូវធ្វើឡើងតាមរយៈតុលាការ ។

ភាពជឿទុកចិត្តរបស់អ្នកប្រើប្រាស់សេវា និងអ្នកពាក់ព័ន្ធទាំងអស់អាស្រ័យទៅលើការអនុវត្តច្បាប់ឲ្យបានត្រឹមត្រូវនៅក្នុងបរិបទនៃនីតិរដ្ឋ ។ ដូចនេះរាល់សកម្មភាពកែលំអប្រព័ន្ធការងារទាំងអស់ត្រូវរៀបចំឡើងជាជំហានៗ និងដោយប្រុងប្រយ័ត្នក្នុងទិសដៅបង្កើនគុណភាព និងប្រសិទ្ធភាពនៃសេវាកម្មយុត្តិធម៌។

**ឃ. ចង្កោមសេវាពាក់ព័ន្ធនឹងការលើកកម្ពស់កិច្ចការពាណិជ្ជកម្មសហគ្រាសធុនតូចនិងមធ្យមបរិស្ថានវិនិយោគ និងការចូលរួមរបស់ផ្នែកឯកជនក្នុងការកសាងនិងការថែទាំហេដ្ឋារចនាសម្ព័ន្ធ**

➢ ការលើកកម្ពស់កិច្ចការពាណិជ្ជកម្ម

រាជរដ្ឋាភិបាលដែលជាអ្នករៀបចំយុទ្ធសាស្ត្រ និងជាអ្នកគ្រប់គ្រងការអភិវឌ្ឍដើម្បីធ្វើឲ្យបរិស្ថានធុរកិច្ចកាន់តែប្រសើរសម្រាប់វិស័យឯកជនបានចាត់ទុកវិស័យឯកជនជាក្បាលម៉ាស៊ីននៃកំណើនសេដ្ឋកិច្ច។ អាទិភាពជាពិសេសនឹងត្រូវផ្តោតទៅលើការរៀបចំឲ្យកាន់តែប្រសើរឡើងនូវបរិស្ថានរួមសម្រាប់ការអភិវឌ្ឍវិស័យឯកជនតាមរយៈវិធានការជាក់ស្តែងនានា :

- ពង្រឹងអភិបាលកិច្ចល្អទាំងក្នុងវិស័យសាធារណៈ និង វិស័យឯកជន ។
- កាត់បន្ថយរាល់បែបបទស្មុគស្មាញ និងវែងអន្លាយនៅតាមក្រសួងស្ថាប័នដែលពាក់ព័ន្ធដល់ការនាំចេញ នាំចូល ។
- បំបាត់ចោលនូវភារកិច្ចជាន់គ្នារបស់ក្រសួង ស្ថាប័នពាក់ព័ន្ធដើម្បីជំរុញដំណើរការត្រួតពិនិត្យតែមួយកន្លែងឲ្យមានប្រសិទ្ធភាព។
- ពង្រឹងការអនុវត្តយន្តការការិយាល័យច្រក ចេញចូលតែមួយនៅតាមបណ្តាច្រកអន្តរជាតិ ។

➢ សហគ្រាសធុនតូច និងមធ្យម :

រាជរដ្ឋាភិបាលបន្តជំរុញការអភិវឌ្ឍសហគ្រាសធុនតូច និងមធ្យមតាមរយៈគោលនយោបាយ៖

- លើកទឹកចិត្តដល់សហគ្រាសធុនតូចនិង មធ្យមជាពិសេសតាមរយៈការផ្តល់ឥណទានរយៈពេលមធ្យម និង រយៈពេលវែង
- ទប់ស្កាត់ការរត់គេចពន្ធគ្រប់ប្រភេទ
- កាត់បន្ថយបែបបទការចុះបញ្ជី និងការរៀបចំដំណើរការក្រុមហ៊ុន ។
- សម្រួលដល់ការនាំចេញនាំចូលតាមរយៈការកាត់បន្ថយបែបបទស្មុគស្មាញក្នុងការស្នើសុំអាជ្ញាប័ណ្ណ និងលិខិតអនុញ្ញាតផ្សេងៗ ។ល។
- កាត់បន្ថយពេលវេលា និងកាត់បន្ថយថ្លៃសេវាកម្មក្នុងការអនុញ្ញាតឲ្យដំណើរការផលិតកម្មនៃសហគ្រាសធុនតូច និងមធ្យមតាមរយៈការអនុវត្តយន្តការការិយាល័យច្រកចេញចូលតែមួយ ។
- ផ្តល់ការគាំពារដល់សហគ្រាសមួយចំនួនក្នុងរយៈពេលមួយសមស្រប ។

- ជំរុញឲ្យមានសម្ព័ន្ធភាពរវាងសហគ្រាសធុនតូច និងមធ្យមជាមួយនឹងឧស្សាហកម្មធុនធំជាដើម ។

ដើម្បីសម្រេចគោលដៅខាងលើរាជរដ្ឋាភិបាលយកចិត្តទុកដាក់៖

- ជំរុញលើកទឹកចិត្តដល់ការផលិតទំនិញបម្រើទីផ្សារក្នុងស្រុកជំនួសការនាំចូលដើម្បីឆ្លើយតបទៅនឹងយុទ្ធសាស្ត្រនៃការបង្កើតមូលដ្ឋានផលិតកម្មទំនិញក្នុងប្រទេសឲ្យបានច្រើនស្របទៅនឹងយុគសម័យនៃតំបន់ភាវូបនីយកម្ម និងសកលភាវូបនីយកម្ម
- រៀបចំយុទ្ធសាស្ត្របង្កើនសមត្ថភាពប្រកួតប្រជែងសម្រាប់សហគ្រាសធុនតូច និង មធ្យម
- រៀបចំផែនការសកម្មភាព និង បទប្បញ្ញត្តិនានាដើម្បីគ្រប់គ្រងតាមដានត្រួតពិនិត្យ និងគាំទ្រដល់ដំណើរការរបស់សហគ្រាសធុនតូច និង មធ្យម ។

➢ បរិស្ថានវិនិយោគ និងការចូលរួមផ្នែកឯកជនក្នុងការកសាង និងថែទាំហេដ្ឋារចនាសម្ព័ន្ធ

ពាក់ព័ន្ធនឹងការងារនេះរាជរដ្ឋាភិបាលនឹងចាត់វិធានការចាំបាច់ដើម្បីពង្រឹងនិងកែលំអបរិស្ថានវិនិយោគនិងធុរកិច្ចរួមមានគោលនយោបាយលើកទឹកចិត្តលិខិតបទដ្ឋានសម្រាប់ណែនាំ និងជំរុញការចូលរួមរបស់ផ្នែកឯកជនក្នុងការកសាង និងថែទាំហេដ្ឋារចនាសម្ព័ន្ធ ។

រចនាសម្ព័ន្ធនៃផ្នែកពាក់ព័ន្ធទៅនឹងចង្កោមសេវានេះដែលមិនទាន់អាចឆ្លើយតបបានទៅនឹងតម្រូវការជាចាំបាច់ក្នុងការសម្រួលដល់ការធ្វើអាជីវកម្មការវិនិយោគទុន និងការអភិវឌ្ឍផ្នែកឯកជនត្រូវធ្វើការកែសម្រួលឲ្យបានសមស្រប និងឲ្យបានឆាប់រហ័សទៅតាមស្ថានភាពជាក់ស្តែង និងធនធានដែលមាន ។

**ង. ចង្កោមសេវាសង្គមកិច្ច វប្បធម៌ និងកិច្ចការនារី**

ចង្កោមសេវានេះរួមមានសេវាអប់រំ (លើកកម្ពស់គុណភាពសេវាអប់រំសម្រាប់ទាំងអស់គ្នាសម្ភារសិក្សាគ្រប់គ្រាន់ និងសិទ្ធិទទួលបានសេវាអប់រំជាមូលដ្ឋាន) សេវាអនាម័យនិងសុខភាព (បង្កលក្ខណៈងាយស្រួលគុណភាពប្រសិទ្ធភាពដើម្បីផ្គត់ផ្គង់សេវាសុខាភិបាលមូលដ្ឋានប្រកបដោយសមធម៌ និងនិរន្តរភាពជូនប្រជាពលរដ្ឋគ្រប់រូបជាពិសេសជនក្រីក្រ និងក្រុមជនងាយរងគ្រោះ) សេវាសម្រាប់ការកំសាន្តសេវាសង្គមកិច្ចសេវាគាំពារកុមារកំព្រាកុមារងាយរងគ្រោះ ជនពិការសេវាលើកស្ទួយ និងការចូលរួមរបស់ស្ត្រីក្នុងការអភិវឌ្ឍសេដ្ឋកិច្ច និងសេវាដទៃទៀតដែលរួមចំណែកដល់ការកាត់បន្ថយភាពក្រីក្រ ។

**ច. ចង្កោមសេវាពាក់ព័ន្ធនឹងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត**

ការផ្តល់សេវានៃការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្តគឺជាអាទិភាពចំបងមួយរបស់រាជរដ្ឋាភិបាលដើម្បីជំរុញ និងបង្កើនល្បឿនកំណើនសេដ្ឋកិច្ច និងការកាត់បន្ថយភាពក្រីក្រ ។

ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្តត្រូវផ្តោតជាសំខាន់លើការបន្តការកសាងប្រព័ន្ធគមនាគមន៍ដឹកជញ្ជូនរួមមានផ្លូវថ្នល់ ស្ពាន ផ្លូវដែក ផ្លូវទឹក កំពង់ផែ និងអាកាសយានដ្ឋានដែលអាចតភ្ជាប់ទីក្រុងទៅជនបទ និង

គ្រប់ទីកន្លែងទូទាំងប្រទេសកសាងមន្ទីរពេទ្យ សាលារៀន អណ្តូងទឹក ប្រព័ន្ធទឹកស្អាតប្រព័ន្ធធារាសាស្ត្រអគ្គីសនី ថាមពលបច្ចេកវិទ្យាព័ត៌មានប្រៃសណីយ៍ និងទូរគមនាគមន៍ ។ល។ ពាក់ព័ន្ធនឹងចង្កោមសេវានេះរាជរដ្ឋាភិបាល មានគោលនយោបាយលើកទឹកចិត្តឲ្យមានការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធទាំងអស់ជាពិសេសផ្នែកឯកជន ។

**ឆ. ចង្កោមសេវាពាក់ព័ន្ធនឹងការប្រមូលចំណូលការធ្វើវិចារណកម្មចំណាយ និងការបើកផ្តល់**

ចង្កោមសេវានេះពាក់ព័ន្ធនឹងការកែលំអការគ្រប់គ្រងចំណូលចំណាយ និងការបើកផ្តល់ឲ្យមានតម្លាភាព និងប្រសិទ្ធភាពខ្ពស់ជាងមុនសំដៅកាត់បន្ថយការលំបាករបស់អ្នកប្រើប្រាស់សេវា។

ដើម្បីសម្រួលដល់ការអនុវត្តក្រសួង ស្ថាប័នដែលមានភារកិច្ចពាក់ព័ន្ធនឹងចង្កោមសេវាណាមួយក្នុង ចំណោមចង្កោមសេវាទាំង៧ ខាងលើត្រូវរៀបចំចងក្រងបញ្ជីសេវានេះឲ្យបានសមស្រប ។

ក្នុងករណីមានការវិវត្តនៃសេដ្ឋកិច្ចទីផ្សារ បច្ចេកវិទ្យាទំនើប និងតម្រូវការជាក់ស្តែងដទៃទៀតដែលកើតមាន ឡើងពីការវិវត្តរបស់សង្គមជាតិសេវាសាធារណៈនឹងត្រូវកំណត់តាមស្ថានការណ៍វិវត្តនោះ ។

ការផ្តល់សេវាសាធារណៈគ្រប់ប្រភេទទោះបីជាតាមយន្តការទីកន្លែងនិងកាលៈទេសៈណាក៏ដោយត្រូវគិត ទៅដល់លទ្ធភាព និងការគាំទ្រដល់ជនក្រីក្រជនពិការ ចាស់ជរា និងកុមារទាំងនៅក្នុងទីក្រុង និងនៅជនបទក្នុង ការទទួលយកសេវាទៅប្រើប្រាស់ ។

**១.៧.២ គោលដៅ**

គោលដៅជាយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលក្នុងការផ្តល់សេវាសាធារណៈគឺដើម្បីបម្រើប្រជាពលរដ្ឋឲ្យបាន កាន់តែល្អប្រសើរឡើងមានន័យថារដ្ឋបាលសាធារណៈត្រូវ ៖

**ក. ធានាភាពងាយស្រួលក្នុងការទទួលយកសេវាទៅប្រើប្រាស់**

ផ្តល់ព័ត៌មានគ្រប់គ្រាន់ច្បាស់លាស់ និងងាយយល់កាត់បន្ថយការិយាធិបតេយ្យ និងនីតិវិធីស្មុគស្មាញ សំដៅកាត់បន្ថយការលំបាករបស់អ្នកប្រើប្រាស់សេវាក្នុងការស្វែងរកសេវាដោយខ្លួនឯង និងចំណាយបន្ថែមទៅ លើអ្នករត់ការក្រៅផ្លូវការ ។

**ខ. ផ្តោតទៅលើតម្រូវការជាក់ស្តែងរបស់ អ្នកប្រើប្រាស់សេវា**

កន្លងមកមន្ត្រីរាជការក្នុងឥរិយាបថជាអ្នកគ្រប់គ្រងបានកំណត់ជាស្រេចនូវប្រភេទសេវាដែលត្រូវផ្តល់ជូន អ្នកប្រើប្រាស់ទោះជាសេវាមួយចំនួនអ្នកប្រើប្រាស់មិនត្រូវការក៏ដោយ។ ប៉ុន្តែក្នុងឥរិយាបថជាអ្នកផ្តល់សេវា គឺ ត្រូវកំណត់ប្រភេទសេវាទៅតាមតម្រូវការរបស់ទីផ្សារ និងរបស់អ្នកប្រើប្រាស់វិញ ។

**គ. ផ្តល់សេវាឲ្យចំទីកន្លែងនៃតម្រូវការរបស់ អ្នកប្រើប្រាស់សេវា**

រដ្ឋបាលសាធារណៈត្រូវផ្តល់សេវាដល់ទីកន្លែងដែលអ្នកប្រើប្រាស់ត្រូវការលើកលែងតែក្នុងករណីពិសេសមួយចំនួនដែលមិនអាចផ្គត់ផ្គង់បាន។ ឧទាហរណ៍ សេវាវះកាត់បេះដូងដែលបច្ចុប្បន្ននេះមានតែមួយកន្លែងគត់នៅរាជធានីភ្នំពេញ ។

ក្នុងន័យនេះរដ្ឋបាលសាធារណៈត្រូវតែបង្ខិតឲ្យនៅជិតប្រជាពលរដ្ឋដើម្បីសម្រួលការទទួលយកសេវាទៅប្រើប្រាស់ ។ ឧទាហរណ៍ បើអ្នកប្រើប្រាស់ត្រូវការប្រភេទសេវាណាមួយនៅតំបន់ណាមួយយើងត្រូវកំណត់ឲ្យមានសេវាប្រភេទនោះនៅតំបន់នោះតែម្តងមិនត្រូវឲ្យអ្នកប្រើប្រាស់រត់រកសេវានោះនៅភ្នំពេញទេ ។

**ឃ. ត្រូវមានតម្លាភាព និងការទទួលខុសត្រូវក្នុងការផ្តល់សេវា**

អ្នកផ្តល់សេវាត្រូវផ្តល់ព័ត៌មានឲ្យបានទូលំទូលាយជាចំហដោយគ្មានការរើសអើង និងយកចិត្តទុកដាក់ផ្តល់សេវាឲ្យបានទាន់ពេលវេលាកំណត់ និងមានគុណភាពជូនអ្នកប្រើប្រាស់ដោយស្មារតីទទួលខុសត្រូវខ្ពស់ ។ ទន្ទឹមនឹងនោះអ្នកផ្តល់សេវាក៏ត្រូវទុកលទ្ធភាពឲ្យអ្នកប្រើប្រាស់តាមដាននិងស្វែងយល់អំពីនីតិវិធីនៃការផ្តល់សេវា និងអាចធ្វើការទិទៀនតវ៉ា ឬទាមទារឲ្យមានការកែលំអការខ្វះខាតផ្សេងៗតាមតម្រូវការសំដៅលើកកម្ពស់ប្រសិទ្ធភាព និងតម្លាភាពស្របតាមគោលការណ៍អភិបាលកិច្ចល្អ ។

**ង. គុណភាព និងប្រសិទ្ធភាពនៃសេវា**

អ្នកផ្តល់សេវាត្រូវគោរពឲ្យបាននូវស្តង់ដារកំណត់មានន័យថាអ្វីដែលបានកំណត់ជូនអ្នកប្រើប្រាស់ត្រូវតែធ្វើឲ្យបានទៅតាមការកំណត់នោះទាំងតម្លៃទាំងពេលវេលា និងគុណភាព ។ គុណភាពនៃសេវាត្រូវបានកំណត់ផ្អែកទៅលើការពេញចិត្តរបស់អ្នកប្រើប្រាស់សេវានៅពេលដែលសេវាត្រូវបានផ្តល់ជូននោះឆ្លើយតបទៅនឹងតម្រូវការ និងផលប្រយោជន៍ទូទៅរបស់អ្នកប្រើប្រាស់ ។

សេវាទាំងឡាយណាដែលរដ្ឋបាលសាធាពុំទាន់មានលទ្ធភាពផ្តល់ជូនអ្នកប្រើប្រាស់បានរដ្ឋអាចស្វែងរកដៃគូអភិវឌ្ឍន៍ដែលមានលទ្ធភាពដើម្បីជួយសម្រួលដល់អ្នកប្រើប្រាស់សេវាស្របតាមតម្រូវការ ។

# ជំពូកទី ២
# ដំណើរការប្រព្រឹត្តទៅនៃ
# ការគ្រប់គ្រងរដ្ឋបាល
# សង្កាត់ចាក់អង្រែក្រោម

# ជំពូកទី២

# ដំណើរការប្រព្រឹត្តទៅនៃការគ្រប់គ្រងរដ្ឋបាលសង្កាត់ចាក់អង្រែក្រោម

## ២.១. ស្ថានភាពទូទៅ

### ២.១.១. ទីតាំងភូមិសាស្ត្រ និងប្រជាសាស្ត្រ

សង្កាត់ចាក់អង្រែក្រោម កកើតឡើងនៅចុងឆ្នាំ ១៩៨៦ និងមានព្រំប្រទល់ ខាងជើងទល់នឹងសង្កាត់ចាក់អង្រែលើ ខាងត្បូងមានព្រំប្រទល់ជាប់ជាមួយនឹង សង្កាត់ដើមមៀន ខេត្តកណ្តាល ខាងកើតមានព្រំប្រទល់ជាប់នឹងទន្លេបាសាក់ សង្កាត់ព្រែកប្រា ខណ្ឌច្បារអំពៅ ខាងលិចមានព្រំប្រទល់ជាប់នឹង សង្កាត់ជើងឯក ខណ្ឌដង្កោ។ សង្កាត់ចាក់អង្រែក្រោម មានទំហំផ្ទៃដី ៩.៨៩ គីឡូម៉ែត្រការ៉េស្មើនឹង ៤០.៥៣% នៃផ្ទៃដីខណ្ឌមានជ័យ។[៣៤]

សង្កាត់ចាក់អង្រែក្រោមជាសង្កាត់មួយក្នុងចំណោមសង្កាត់ទាំង៤ ក្នុងខណ្ឌមានជ័យដែលមានចម្ងាយពីសាលាខណ្ឌប្រមាណ៥០០ម៉ែត្រ តាមបណ្តោយផ្លូវជាតិលេខ២។[៣៥]

សង្កាត់ចាក់អង្រែត្រូវបានបែងចែកជា៨ភូមិ ដែលមានដូចជាៈ

- ភូមិ ទួលរកា
- ភូមិ ទួលរកា១
- ភូមិ ទួលរកា២
- ភូមិ ទួលរកា៣
- ភូមិ ព្រែកតាឡុង
- ភូមិ ព្រែកតាឡុង១
- ភូមិ ព្រែកតាឡុង២
- ភូមិ ព្រែកតាឡុង៣។[៣៦]

ចំពោះស្ថានភាពប្រជាសាស្ត្រនៅសង្កាត់ចាក់អង្រែក្រោមយោងតាមឆ្នាំ២០២៣ មានប្រជាជនសរុបចំនួន ២៩ ៥៧៣ នាក់ (ចំនួនប្រជាជនអចិន្ត្រៃយ៍) និងប្រជាជនដែលមានអាយុចាប់ពី១៨ឆ្នាំឡើងទៅមានចំនួន ២២ ២២០ នាក់ ស្ត្រីមានចំនួន ១៤ ៤២០ នាក់។ ក្នុងនោះផងដែរមាន ៦៤៥៥ គ្រួសារ និងផ្ទះមានចំនួន ៦០០៩ ខ្នង។[៣៧]

---

[៣៤] ជួបសម្ភាសន៍ផ្ទាល់ជាមួយ លោក ជឹម សុរិទ្ធិ ជាសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ នាពេលរសៀល

[៣៥] ជួបសម្ភាសន៍ផ្ទាល់ជាមួយ លោក ជឹម សុរិទ្ធិ ជាសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់

[៣៦] ជួបសម្ភាសន៍ផ្ទាល់ជាមួយ លោក ជឹម សុរិទ្ធិ ជាសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់

[៣៧] ជួបសម្ភាសន៍ផ្ទាល់ជាមួយ លោក ជឹម សុរិទ្ធិ ជាសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់

### ២.១.២. ស្ថានភាពសេដ្ឋកិច្ច

នៅក្នុងសង្កាត់ចាក់អង្រែក្រោមមានដង់ស៊ីតេប្រជាជន ៣១៤៨/១គីឡូម៉ែត្រការ៉េ ។ មុខរបរប្រជាពលរដ្ឋមាន ដូចជា មន្រ្តីរាជការ ២.៥៩% , អាជីវករ ៥.៦៨% , កម្មករ ២៥.៣៤% , កសិករ 0.0៥% , កងទ័ព ១.២៤% , នគរបាល ១.៩២% , ប្រជាការពារ 0.0៥% និងការងារផ្សេងៗទៀត។[៣៨]

### ២.១.៣. ស្ថានភាពសង្គមកិច្ច

ស្ថានភាពសង្គមកិច្ចនៅក្នុងសង្កាត់ចាក់អង្រែក្រោមមាន វត្តអារាមចំនួន១ ព្រះសង្ឃចំនួន២៧អង្គ តាជី ៤នាក់ និងយាយជី ១0នាក់ , ភាហិរសាសនាចំនួន៤ , វត្តគង់សេអ៊ីមចំនួន១ និងវិហាគ្រឹះសាសនាចំនួន ៣កន្លែង។[៣៩]

## ២.២. រចនាសម្ព័ន្ធសង្កាត់ចាក់អង្រែក្រោម

### ២.២.១. ក្រុមប្រឹក្សា

ឃុំ សង្កាត់នីមួយៗត្រូវមានក្រុមប្រឹក្សាមួយហៅថាក្រុមប្រឹក្សាឃុំ សង្កាត់។ ក្រុមប្រឹក្សាឃុំ សង្កាត់ជាអង្គការ តំណាងប្រជាពលរដ្ឋក្នុងឃុំ សង្កាត់របស់ខ្លួន និងមានបេសកកម្មបម្រើផលប្រយោជន៍ទូទៅនៅក្នុងឃុំ សង្កាត់ របស់ខ្លួន។

ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវបានជ្រើសរើសឡើងតាមការបោះឆ្នោតដោយប្រជាពលរដ្ឋនៃឃុំ សង្កាត់របស់ខ្លួន ស្របទៅតាមនីតិវិធីដែលកំណត់ដោយច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់។[៤0]

#### ២.២.១.១. អាណត្តិរបស់ក្រុមប្រឹក្សាឃុំ សង្កាត់

ក្រុមប្រឹក្សាឃុំ សង្កាត់មានអាណត្តិ ៥ឆ្នាំហើយត្រូវផុតកំណត់នៅពេលក្រុមប្រឹក្សាថ្មីចូលកាន់តំណែង។ ក្នុងដំណាក់កាលអន្តរកាលនេះក្រុមប្រឹក្សាឃុំសង្កាត់ដែលផុតអាណត្តិមានភារកិច្ចសម្រួលកិច្ចការប្រចាំថ្ងៃតែ ប៉ុណ្ណោះ។

#### ២.២.១.២. សមាសភាពក្រុមប្រឹក្សាសង្កាត់ចាក់អង្រែក្រោម

| | | |
|---|---|---|
| ១. | លោក ជា សុខៃ | ចៅសង្កាត់ |
| ២. | លោក សេង ឈុនហេង | ចៅសង្កាត់រងទី១ |
| ៣. | លោក នូ សេងហេង | ចៅសង្កាត់រងទី២ |
| ៤. | លោក កែវ រតនា | សមាជិកក្រុមប្រឹក្សា |
| ៥. | កញ្ញា លី ណារី | សមាជិកក្រុមប្រឹក្សា |

[៣៨] ជួបសម្ភាសន៍ផ្ទាល់ជាមួយ លោក ជឹម សុរិទ្ធិ ជាសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ នាពេលរសៀល

[៣៩] ជួបសម្ភាសន៍ផ្ទាល់ជាមួយ លោក ជឹម សុរិទ្ធិ ជាសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ នាពេលរសៀល

[៤0] ច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់

៦. លោក ជា រដ្ឋា សមាជិកក្រុមប្រឹក្សា

៧. កញ្ញា អ៊ឹម ស៊ីផាត សមាជិកក្រុមប្រឹក្សា

៨. លោក ជឹម សុរិទ្ធិ សមាជិកក្រុមប្រឹក្សា

៩. លោក ហុង គីមហ័រ សមាជិកក្រុមប្រឹក្សា។[៤១]

**២.២.១.៣. លក្ខខណ្ឌនៃការឈរឈ្មោះ**

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទដែលមានសិទ្ធិ និងមានបំណងឈរឈ្មោះជាបេក្ខជនត្រូវបំពេញលក្ខខណ្ឌសំខាន់ៗដូចខាងក្រោមៈ

- មានសញ្ជាតិខ្មែរពីកំណើត
- ចេះអាន និងសរសេអក្សរខ្មែរ
- បានចុះឈ្មោះក្នុងបញ្ជីឈ្មោះអ្នកបោះឆ្នោតក្នុងឃុំ សង្កាត់ដែលខ្លួនមានបំណងឈរឈ្មោះ
- មានអាយុយ៉ាងតិច២៥ឆ្នាំគិតមកទល់ថ្ងៃបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ឃុំ សង្កាត់
- មានលក្ខណៈសម្បត្តិគ្រប់គ្រាន់តាមលក្ខខណ្ឌដែលបានកំណត់ដោយច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ។[៤២]

**២.២.១.៤. ការងារត្រូវធ្វើក្រោយប្រកាសចូលកាន់តំណែង**

ក្នុងអំឡុងពេល១៨ថ្ងៃក្រោយពីការប្រកាសលទ្ធផលជាផ្លូវការនៃការបោះឆ្នោតត្រូវចាត់ឲ្យមានការប្រជុំជាលើកដំបូងនៃក្រុមប្រឹក្សាឃុំ សង្កាត់ក្រោមអធិបតីភាពមន្ត្រីម្នាក់ដែលចាត់តាំងដោយរដ្ឋមន្ត្រីក្រសួងមហាផ្ទៃដើម្បីប្រកាសសុពលភាពសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ និងប្រកាសឈ្មោះប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ មេឃុំ ចៅសង្កាត់ ជំទប់ និងចៅសង្កាត់រង។ ដើម្បីអនុវត្តការងារនេះក្រសួងមហាផ្ទៃបានចេញប្រកាសលេខ១៥០១ ប្រក ចុះថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០១៧ និងការណែនាំមួយចំនួនទៀតក្នុងគោលបំណងធ្វើប្រតិភូកម្មអំណាចដល់រដ្ឋបាលរាជធានីខេត្តក្នុងការចាត់ចែងដំណើរការនៃកិច្ចប្រជុំលើកដំបូងរបស់ក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិថ្មី។ ក្នុងកិច្ចប្រជុំដំបូងនេះក៏មានការប្រគល់ទទួលគ្រារដ្ឋបាលឃុំ សង្កាត់ពីអធិបតីនៃអង្គប្រជុំដល់ប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ថ្មីផងដែរ។

ជាមួយនេះមាត្រា២០ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់បានកំណត់ថាមុនចាប់ផ្តើមការងារក្រុមប្រឹក្សាឃុំ សង្កាត់នីមួយៗត្រូវរៀបចំ និងអនុម័តបទបញ្ជាផ្ទៃក្នុងដើម្បីកំណត់នូវវិធានទាំងឡាយសម្រាប់អង្គប្រជុំ និងរបៀបរបបធ្វើការងាររបស់ខ្លួន។

[៤១] ជួបសម្ភាសន៍ផ្ទាល់ជាមួយ លោក ជឹម សុរិទ្ធិ ជាសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ នាពេលរសៀល

[៤២] ច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់

ក្នុងន័យដូចខាងលើដើម្បីធានានិរន្តរភាព និងភាពរលូននៃការងាររបស់ក្រុមប្រឹក្សាអាណត្តិចាស់មកក្រុមប្រឹក្សាអាណត្តិថ្មីការងារចាំបាច់មួយចំនួនដែលក្រុមប្រឹក្សាអាណត្តិថ្មីត្រូវធ្វើបន្ទាប់ពីការប្រកាសចូលកាន់តំណែងរួមមានដូចខាងក្រោម៖[៤៣]

**ក. ការរៀបចំបទបញ្ជាផ្ទៃក្នុង**

បទបញ្ជាផ្ទៃក្នុងរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវធ្វើជាទម្រង់ដីកា និងត្រូវពិភាក្សាអនុម័តក្នុងកិច្ចប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់យ៉ាងយូរបំផុតក្នុងរយៈពេល ៣០ថ្ងៃ បន្ទាប់ពីកិច្ចប្រជុំដំបូង មុននឹងឈាន ទៅអនុវត្តកិច្ចការផ្សេងទៀត។

ខ្លឹមសារនៃបទបញ្ជាផ្ទៃក្នុងត្រូវចែងអំពីលក្ខខណ្ឌចាំបាច់នានាក្នុងការកំណត់នូវវិធានទាំងឡាយសម្រាប់រៀបចំដំណើរការប្រជុំ និងរបៀបរបបធ្វើការងាររបស់ក្រុមប្រឹក្សាព្រមទាំងគណៈកម្មាធិការពាក់ព័ន្ធ និងត្រូវធានាថាខ្លឹមសារទាំងនោះស្របតាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់។

- **ការរៀបចំសេចក្តីព្រាងបទបញ្ជាផ្ទៃក្នុង**

ប្រធានក្រុមប្រឹក្សាត្រូវធ្វើការណែនាំដល់ស្មៀនឃុំ សង្កាត់ឲ្យរៀបចំសេចក្តីព្រាងបទបញ្ជាផ្ទៃក្នុងឲ្យបានឆាប់ដោយផ្អែកតាមគំរូបទបញ្ជាផ្ទៃក្នុងដូចមានភ្ជាប់នៅក្នុងសេចក្តីណែនាំលេខ០៣២ សណន ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០២២របស់ក្រសួងមហាផ្ទៃស្តីពីគំរូបទបញ្ជាផ្ទៃក្នុងថ្មីរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ក៏បានកំណត់អំពីលក្ខខណ្ឌអប្បបរមានៃការរៀបចំកិច្ចប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់។ ដោយឡែកចំពោះដំណើរការនៃការរៀបចំបទបញ្ជាផ្ទៃក្នុង ការអនុម័តបទបញ្ជាផ្ទៃក្នុងឃុំ សង្កាត់ និងការពិនិត្យ នីត្យានុកូលភាពដីការបទបញ្ជាផ្ទៃក្នុងត្រូវអនុវត្តតាមខ្លឹមសារដែលបានកំណត់ក្នុងសេចក្តីណែនាំលេខ ០១៤ សណន ចុះថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០១៧ របស់ក្រសួងមហាផ្ទៃស្តីពីសេចក្តីណែនាំស្តីពីការរៀបចំបទបញ្ជាផ្ទៃក្នុងរបស់ក្រុមប្រឹក្សាឃុំ សង្កាត់។

- **ការពិនិត្យ និងការអនុម័តបទបញ្ជាផ្ទៃក្នុង**

ស្មៀនឃុំ សង្កាត់ត្រូវរៀបចំដាក់ជូនសេចក្តីព្រាងបទបញ្ជាផ្ទៃក្នុងរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ទៅមេឃុំ ចៅសង្កាត់របស់ខ្លួនដើម្បីស្នើសុំពិនិត្យ និងឯកភាពជាបឋមលើសេចក្តីព្រាងនេះមុននឹងដាក់ជូនកិច្ចប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់ ដើម្បីពិភាក្សា និងអនុម័តលើសេចក្តីព្រាងបទបញ្ជាផ្ទៃក្នុងរបស់ក្រុមប្រឹក្សា ឃុំ សង្កាត់។

បន្ទាប់ពីឯកភាពលើសេចក្តីព្រាងបទបញ្ជាផ្ទៃក្នុងដែលរៀបចំឡើងដោយស្មៀន មេឃុំ ចៅសង្កាត់ត្រូវរៀបចំកោះប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់ ដើម្បីពិនិត្យពិភាក្សា និងអនុម័តលើសេចក្តីព្រាងបទបញ្ជាផ្ទៃក្នុងរបស់ខ្លួន។ ក្នុងការពិនិត្យអនុម័តនេះក្រុមប្រឹក្សាត្រូវផ្អែកទៅតាមខ្លឹមសារនៃមាត្រា២២ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ

[៤៣] ជំពូកទី៣ នៃសៀវភៅណែនាំពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់

សង្កាត់ ដែលបានកំណត់ថាការប្រជុំអនុម័តបទបញ្ជាផ្ទៃក្នុងនេះនឹងយកជាការលុះត្រាតែចំនួនលើសពីពាក់កណ្តាលនៃសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ទាំងមូលហើយត្រូវបានអនុម័តដោយសម្លេងភាគច្រើនដាច់ខាតនៃសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ទាំងមូល។ ក្នុងការអនុម័តនេះប្រសិនបើមានសម្លេងឆ្នោតស្មើគ្នាសម្លេងរបស់អធិបតីនៃអង្គប្រជុំមានឧត្តមានុភាព។

សម្លេងភាគច្រើនដាច់ខាតមានន័យថាៈ

- បើក្រុមប្រឹក្សាឃុំ សង្កាត់មានសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ចំនួន៥រូបត្រូវមានសមាជិកយ៉ាងតិចចំនួន៣រូបចូលរួមប្រជុំហើយត្រូវបោះឆ្នោតអនុម័តដោយសម្លេងយល់ព្រមយ៉ាងតិចចំនួន៣សម្លេង
- បើក្រុមប្រឹក្សាឃុំ សង្កាត់មានសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ចំនួន៧រូបត្រូវមានសមាជិកយ៉ាងតិចចំនួន៤រូបចូលរួមប្រជុំ យល់ព្រមយ៉ាងតិចចំនួន៤សម្លេងហើយត្រូវបោះឆ្នោតអនុម័តដោយសម្លេង
- បើក្រុមប្រឹក្សាឃុំ សង្កាត់មានសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ចំនួន៩រូបត្រូវមានសមាជិកយ៉ាងតិចចំនួន៥រូបចូលរួមប្រជុំហើយត្រូវបោះឆ្នោតអនុម័តដោយសម្លេងយល់ព្រមយ៉ាងតិចចំនួន៥សម្លេង
- បើក្រុមប្រឹក្សាឃុំ សង្កាត់មានសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ចំនួន១១រូបត្រូវមានសមាជិកយ៉ាងតិចចំនួន៦រូបចូលរួមប្រជុំហើយត្រូវបោះឆ្នោតអនុម័តដោយសម្លេងយល់ព្រមយ៉ាងតិចចំនួន៦សម្លេង

ក្នុងពេលប្រជុំពិនិត្យ និងអនុម័តបទបញ្ជាផ្ទៃក្នុងស្មៀនឃុំ សង្កាត់ត្រូវធ្វើកំណត់ហេតុកិច្ចប្រជុំឲ្យបានច្បាស់លាស់ និងត្រឹមត្រូវ។

ក្រោយពីក្រុមប្រឹក្សាឃុំ សង្កាត់បានអនុម័តបទបញ្ជាផ្ទៃក្នុងរបស់ក្រុមប្រឹក្សាឃុំ សង្កាត់រួចហើយស្មៀនឃុំ សង្កាត់ត្រូវរៀបចំដាក់ជូនប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ចុះហត្ថលេខាលើដីកាស្តីពីបទបញ្ជាផ្ទៃក្នុងក្រុមប្រឹក្សាឃុំ សង្កាត់ និងត្រូវថតចម្លងចែកជូនគ្រប់សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ព្រមទាំងត្រូវផ្ញើជូនអភិបាលរាជធានីខេត្ត ក្រុង ស្រុក ខណ្ឌ និងរក្សាទុកជាឯកសារក្នុងរដ្ឋបាលឃុំ សង្កាត់សាមី។

ក្នុងករណីក្រុមប្រឹក្សាឃុំ សង្កាត់ណាអនុម័តបទបញ្ជាផ្ទៃក្នុងរបស់ខ្លួនមិនបានទាន់ពេលវេលាកំណត់៣០ថ្ងៃបន្ទាប់ពីកិច្ចប្រជុំប្រកាសសុពលភាពរបស់ក្រុមប្រឹក្សាឃុំ សង្កាត់នោះក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវអនុវត្តតាមគំរូបទបញ្ជាផ្ទៃក្នុងដែលភ្ជាប់ជាមួយសេចក្តីណែនាំលេខ០១៤សណន ចុះថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០១៧ របស់ក្រសួងមហាផ្ទៃស្តីពីសេចក្តីណែនាំស្តីពីការរៀបចំបទបញ្ជាផ្ទៃក្នុងរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ឬអនុវត្តបទបញ្ជាផ្ទៃក្នុងរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ចាស់ដែលទើបបញ្ចប់អាណត្តិថ្មីៗនេះ។

➢ **ការពិនិត្យនីត្យានុកូលភាពនៃបទបញ្ជាផ្ទៃក្នុង**

ដីកាស្តីពីបទបញ្ជាផ្ទៃក្នុងរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ដែលបានអនុម័តរួចហើយត្រូវថតចម្លងចំនួនមួយច្បាប់ជូនអភិបាលរាជធានីខេត្តក្នុងរយៈពេលយ៉ាងយូរ០៥ថ្ងៃបន្ទាប់ពីថ្ងៃអនុម័តដើម្បីធ្វើការពិនិត្យ នីត្យានុកូលភាព។

ក្នុងករណីមានការណែនាំឲ្យកែតម្រូវពីអភិបាលរាជធានីខេត្ត មេឃុំ ចៅសង្កាត់ត្រូវធ្វើការពិនិត្យ និងកែតម្រូវឡើងវិញហើយដាក់ជូនក្រុមប្រឹក្សាពិនិត្យ និងអនុម័តក្នុងកិច្ចប្រជុំសាមញ្ញ ឬវិសាមញ្ញបន្ទាប់។

រាល់ការកែប្រែបទបញ្ជាផ្ទៃក្នុងរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវថតចម្លងចំនួនមួយច្បាប់ជូនអភិបាលរាជធានីខេត្តក្នុងរយៈពេលយ៉ាងយូរ០៥ថ្ងៃបន្ទាប់ពីថ្ងៃអនុម័តដើម្បីធ្វើការពិនិត្យនីត្យានុកូលភាពលើខ្លឹមសារដែលបានកែប្រែនោះ។

**ខ. ការបន្តការងារគ្រប់គ្រង និងដឹកនាំរដ្ឋបាលឃុំ សង្កាត់**

បន្ទាប់ពីបានអនុម័តបទបញ្ជាផ្ទៃក្នុងរបស់ក្រុមប្រឹក្សាឃុំ សង្កាត់រួចរាល់នៅថ្ងៃដដែល ឬថ្ងៃបន្ទាប់ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវជួបប្រជុំគ្នាធ្វើការពិនិត្យលើការងារគ្រប់គ្រង និងដឹកនាំរបស់រដ្ឋបាលឃុំ សង្កាត់ព្រមទាំងការពិនិត្យមើលទៅលើគម្រោងកម្មវិធីអភិវឌ្ឍន៍ និងគម្រោងសេវាកម្មនានាដែលនៅសេសសល់ពីក្រុមប្រឹក្សាអាណត្តិចាស់ជាពិសេសផ្អែកលើរបាយការណ៍សង្ខេបសម្រាប់ផ្ទេរក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិចាស់ទៅឲ្យក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិថ្មីក្នុងនោះរួមមានដូចជា៖

- ការងារគម្រោងកម្មវិធីអភិវឌ្ឍន៍ និងសេវាកម្មនានារបស់រដ្ឋបាលឃុំ សង្កាត់
- ការពិនិត្យកែសម្រួលគណៈកម្មាធិការ ឬគណៈកម្មការនានារបស់ក្រុមប្រឹក្សា
- ការអនុវត្តច្បាប់ និងលិខិតបទដ្ឋាននានា។

➢ **ការងារគម្រោងកម្មវិធីអភិវឌ្ឍន៍ និងសេវាកម្មនានារបស់រដ្ឋបាលឃុំ សង្កាត់**

ពាក់ព័ន្ធគម្រោងកម្មវិធីអភិវឌ្ឍន៍ និងសេវាកម្មនានាដែលគាំទ្រដោយមូលនិធិឃុំ សង្កាត់ដែលបានធ្វើលទ្ធកម្មរួចហើយតែមិនទាន់បានអនុវត្ត ឬកំពុងអនុវត្ត ឬកំពុងស្ថិតក្នុងកិច្ចសន្យាក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិថ្មីត្រូវទទួលអនុវត្តបន្តនូវគម្រោងកម្មវិធីអភិវឌ្ឍន៍ និងសេវាកម្មទាំងនេះរហូតដល់បញ្ចប់គម្រោង ឬកិច្ចសន្យា។

ចំពោះគម្រោងកម្មវិធីអភិវឌ្ឍន៍ និងសេវាកម្មនានាដែលក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិចាស់បានលើកឡើងហើយមិនទាន់បានធ្វើលទ្ធកម្មក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិថ្មីត្រូវធ្វើការពិភាក្សា និងសម្របសម្រួលដើម្បីអនុវត្តបន្តរហូតដល់ពេលរៀបចំនូវផែនការអភិវឌ្ឍរបស់ខ្លួន។

សម្រាប់គម្រោងកម្មវិធីអភិវឌ្ឍន៍ និងសេវាកម្មនានាដែលគាំទ្រដោយដៃគូអភិវឌ្ឍន៍អង្គការមិនមែនរដ្ឋាភិបាល និងសង្គមស៊ីវិលនានានិងមិនស្ថិតនៅក្នុងថវិការបស់ឃុំ សង្កាត់ ក្រុមប្រឹក្សា ឃុំ សង្កាត់ត្រូវធ្វើការពិភាក្សាជាមួយដៃគូអភិវឌ្ឍន៍ និងអ្នកពាក់ព័ន្ធដើម្បីបន្តអនុវត្តគម្រោងទាំងនោះស្របតាមគោលការណ៍របស់ក្រុមប្រឹក្សាឃុំ សង្កាត់ និងសំណូមពររបស់ដៃគូអភិវឌ្ឍន៍អង្គការមិនមែនរដ្ឋាភិបាល និងសង្គមស៊ីវិលទាំងនោះ។

គម្រោងកម្មវិធីអភិវឌ្ឍន៍ និងគម្រោងសេវាកម្មទាំងនោះក្រោយពីក្រុមប្រឹក្សាឃុំ សង្កាត់បានសម្រេចរួចត្រូវជូនព័ត៌មានជាបន្ទាន់ដល់អភិបាលរាជធានី ខេត្តដៃគូអភិវឌ្ឍន៍អង្គការមិនមែនរដ្ឋាភិបាលនិងសង្គមស៊ីវិល

អំពីការសម្រេចចិត្តរបស់ខ្លួន និងត្រូវបិទផ្សាយភ្លាមនូវសេចក្តីសម្រេចនេះនៅលើក្តារព័ត៌មានរបស់រដ្ឋបាលឃុំ សង្កាត់។

ទន្ទឹមនឹងការពិភាក្សាពិនិត្យឡើងវិញនូវគម្រោងកម្មវិធីអភិវឌ្ឍន៍ និងគម្រោងសេវាកម្មនានាខាងលើក្រុមប្រឹក្សាឃុំ សង្កាត់ក៏ត្រូវយកចិត្តទុកដាក់អនុវត្តការងារចាំបាច់បន្ទាន់មួយទៀតដូចជាៈ

- សម្របសម្រួល និងរៀបចំបែបបទស្នើតម្កល់គំរូហត្ថលេខាឡើងវិញទៅរតនាគារ និងធនាគារពាក់ព័ន្ធដែលមានគណនីរបស់ឃុំ សង្កាត់
- ធ្វើការពិនិត្យផ្ទៀងផ្ទាត់បញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិសាច់ប្រាក់ដែលមានក្នុងបេឡារបស់ឃុំ សង្កាត់ សាច់ប្រាក់ដែលមាននៅក្នុងគណនីរបស់រដ្ឋបាលឃុំ សង្កាត់នៅរតនាគារ និងធនាគារនានាបញ្ជីបុគ្គលិក ឯកសារ និងកិច្ចសន្យានានាដែលក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិចាស់បានចុះហត្ថលេខា និងដែលនៅមានសុពលភាពដើម្បីគ្រប់គ្រងកិច្ចសន្យានេះរហូតដល់បញ្ចប់។

➢ **ការបង្កើតការកែសម្រួលគណៈកម្មាធិការ ឬគណៈកម្មការនានារបស់ក្រុមប្រឹក្សាឃុំ សង្កាត់**

គណៈកម្មាធិការ ឬគណៈកម្មការជាកាតព្វកិច្ចគឺជាគណៈកម្មាធិការ ឬគណៈកម្មការដែលក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវបង្កើតឡើងដោយផ្អែកតាមលក្ខខណ្ឌតម្រូវនៃច្បាប់អនុក្រឹត្យ និងលិខិតបទដ្ឋាននានាក្នុងនោះមានជាអាទិ៍គណៈកម្មាធិការកសាងផែនការ និងថវិកាគណៈកម្មការលទ្ធកម្ម និងគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារ។

ក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិថ្មីត្រូវពិនិត្យមើលឡើងវិញនូវសមាជិកភាពគណៈកម្មាធិការ ឬគណៈកម្មការដែលជាសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់តែប៉ុណ្ណោះ។ ក្នុងករណីសមាជិកគណៈកម្មាធិការ ឬគណៈកម្មការរូបណាមួយជាសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ដែលមិនបានជាប់ឆ្នោតបន្តទៀតក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិថ្មីត្រូវជ្រើសរើសសមាជិកក្រុមប្រឹក្សាថ្មីដែលជាប់ឆ្នោតឲ្យជំនួសស្របទៅតាមនីតិវិធីតាមរយៈការចេញសេចក្តីសម្រេចរបស់ឃុំ សង្កាត់។

ដោយឡែកចំពោះគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិថ្មីត្រូវជ្រើសរើសអ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់តាមករណីដូចខាងក្រោមៈ

- ករណីក្រុមប្រឹក្សាឃុំ សង្កាត់មានសមាជិកតែមួយរូបជាស្ត្រីហើយមិនត្រូវបានតែងតាំងជាមេឃុំ ចៅសង្កាត់ ឬជាជំទប់ទី១ ចៅសង្កាត់រងទី១សមាជិកក្រុមប្រឹក្សាជាស្ត្រីមួយរូបនោះត្រូវបានជ្រើសរើសជាអ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់
- ករណីក្រុមប្រឹក្សាឃុំ សង្កាត់មានសមាជិកជាស្ត្រីលើសពីមួយរូបហើយមិនត្រូវបានតែងតាំងជាមេឃុំ ចៅសង្កាត់ ឬជាជំទប់ទី១ ចៅសង្កាត់រងទី១ ប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវកោះប្រជុំក្រុមប្រឹក្សារបស់ខ្លួន

ដើម្បីសម្រេចជ្រើសរើសសមាជិកក្រុមប្រឹក្សាជាស្ត្រីមួយរូបជាអ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់

- ករណីក្រុមប្រឹក្សាឃុំ សង្កាត់មានសមាជិកតែមួយរូបជាស្ត្រីហើយត្រូវបានតែងតាំងជាមេឃុំ ចៅសង្កាត់ ឬជាជំទប់ទី១ ចៅសង្កាត់រងទី១ ឬក្នុងករណីក្រុមប្រឹក្សាឃុំ សង្កាត់ពុំមានសមាជិកជាស្ត្រី មេឃុំ ចៅសង្កាត់ត្រូវសម្របសម្រួលជ្រើសរើសថ្នាក់ដឹកនាំភូមិ (មេភូមិ ឬអនុប្រធានភូមិ ឬសមាជិកភូមិ)ជាស្ត្រីមួយរូបដែលមានសមត្ថភាពនិងបទពិសោធន៍កិច្ចការសេវាសង្គមសម្រាប់ធ្វើជាអ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ហើយដាក់ជូនកិច្ចប្រជុំក្រុមប្រឹក្សាពិនិត្យ និងអនុម័ត។

ម្យ៉ាងទៀតក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិថ្មីក៏អាចធ្វើការពិនិត្យមើលឡើងវិញ និងវាយតម្លៃអំពី ភាពចាំបាច់ ឬមិនចាំបាច់នៃគណៈកម្មាធិការ និងឬគណៈកម្មការនានាដែលមានជាធរមាន។ ក្នុងករណីដែលក្រុមប្រឹក្សាអាណត្តិថ្មីយល់ឃើញថាគណៈកម្មាធិការ ឬគណៈកម្មការមានភាពចាំបាច់ក្រុមប្រឹក្សា ឃុំ សង្កាត់អាណត្តិថ្មីអាចបន្តនិរន្តភាពការងាររបស់គណៈកម្មាធិការ ឬគណៈកម្មាការទាំងនោះជាបន្តទៀតដោយគ្រាន់តែធ្វើការផ្លាស់ប្តូរសមាសភាពដែលជាសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ដែលមិនជាប់ឆ្នោតដោយដាក់ជំនួសសមាជិកក្រុមប្រឹក្សាថ្មីដែលជាប់ឆ្នោត ឬចាំបាច់ត្រូវធ្វើការរៀបចំសមាសភាពគណៈកម្មាធិការ ឬគណៈកម្មការជាថ្មីឡើងវិញទាំងស្រុងដោយផ្អែកទៅតាមការពិភាក្សាសម្រេចរបស់ក្រុមប្រឹក្សា។ ចំពោះគណៈកម្មាធិការ ឬគណៈកម្មាការដែលក្រុមប្រឹក្សាឃុំ សង្កាត់យល់ឃើញថាមិនចាំបាច់ក្រុមប្រឹក្សាអាចរំសាយចោលបានទៅតាមការសម្រេចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់។

- **ការអនុវត្តច្បាប់ និងលិខិតបទដ្ឋាននានា**

ក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិថ្មីត្រូវអនុវត្តឲ្យបានត្រឹមត្រូវទៅតាមច្បាប់ និងលិខិតបទដ្ឋាននានាដែលមានជាធរមានក្នុងការចាត់ចែងការងារនៅក្នុងឃុំ សង្កាត់របស់ខ្លួន។

ក្រុមប្រឹក្សាអាណត្តិថ្មីត្រូវបន្តអនុវត្តដីកា សេចក្តីសម្រេច និងលិខិតបទដ្ឋាននានារបស់ក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិចាស់ឲ្យបានត្រឹមត្រូវ និងមានប្រសិទ្ធភាពរហូតដល់មានដីកា សេចក្តីសម្រេច ឬលិខិតបទដ្ឋានថ្មីមកជំនួស ឬត្រូវបានកែសម្រួលស្របតាមនីតិវិធីជាធរមាន។

### គ. ការរៀបចំផែនការអភិវឌ្ឍរបស់ក្រុមប្រឹក្សាឃុំ សង្កាត់

ក្នុងនាមក្រុមប្រឹក្សាឃុំ សង្កាត់ មេឃុំ ចៅសង្កាត់ត្រូវចាត់ចែងរៀបចំផែនការអភិវឌ្ឍរយៈពេលប្រាំឆ្នាំរបស់ក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិថ្មីក្នុងគោលបំណងកំណត់នូវទស្សនវិស័យកម្មវិធី និងកិច្ចអភិវឌ្ឍន៍ឃុំ សង្កាត់។ ផែនការអភិវឌ្ឍឃុំ សង្កាត់ត្រូវស្របទៅនឹងផែនការអភិវឌ្ឍសេដ្ឋកិច្ច សង្គមកិច្ចរបស់ជាតិ និងត្រូវអនុម័តយល់

ព្រមដោយក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងឆ្នាំទី១ នៃអាណត្តិរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ (មាត្រា៦១ និង៦២ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់)។ [៤៤]

### ២.២.១.៥. ភារកិច្ចក្រុមប្រឹក្សាឃុំ សង្កាត់

ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវមានប្រធានម្នាក់ហៅថាប្រធានក្រុមប្រឹក្សាឃុំ សង្កាត់។ ប្រធានក្រុមប្រឹក្សាឃុំ សង្កាត់មានភារកិច្ចដូចជា៖

- ធ្វើជាអធិបតីក្នុងសម័យប្រជុំនានារបស់ក្រុមប្រឹក្សាឃុំ សង្កាត់របស់ខ្លួន
- ធានាឲ្យមានកិច្ចប្រជុំនានារបស់ក្រុមប្រឹក្សាឃុំ សង្កាត់យ៉ាងតិចឲ្យបានមួយដងក្នុងមួយខែ
- ធានាឲ្យមានកិច្ចប្រជុំនានារបស់ក្រុមប្រឹក្សាឃុំ សង្កាត់របស់ខ្លួនដំណើរការបានត្រឹមត្រូវទៅតាមវិធាននិងបទបញ្ជាដូចបានចែងក្នុងបទបញ្ជាផ្ទៃក្នុងនៃក្រុមប្រឹក្សាឃុំ សង្កាត់ និងបទបញ្ញត្តិ
- រក្សារបៀបរៀបរយ និង សណ្តាប់ធ្នាប់ក្នុងពេលប្រជុំ
- សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់មានភារកិច្ចដូចខាងក្រោមៈ
- ធានាថាក្រុមប្រឹក្សាឃុំ សង្កាត់ប្រើប្រាស់អំណាចតួនាទី និងមុខងារដូចមានចែងនៅក្នុងច្បាប់និងលិខិតបទដ្ឋានពាក់ព័ន្ធ
- ចូលរួមក្នុងកិច្ចប្រជុំឃុំ សង្កាត់
- ធ្វើសហប្រតិបត្តិការជាមួយនិងប្រជាពលរដ្ឋ ។

### ២.២.១.៦. ការប្រជុំរបស់ក្រុមប្រឹក្សាឃុំ សង្កាត់

ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវធ្វើការប្រជុំយ៉ាងតិចណាស់ចំនួនមួយដងក្នុងមួយខែ ។ ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវប្រជុំក្នុងសាលា ឃុំ ឬសាលាសង្កាត់របស់ខ្លួន ឬក្នុងករណីចាំបាច់អធិបតីនៃអង្គប្រជុំអាចជ្រើសរើសយកទីកន្លែងណាមួយក្នុងឃុំ សង្កាត់របស់ខ្លួនដើម្បី ប្រជុំ ។

ការប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់នឹងយកជាការបានលុះត្រាតែមានចំនួនលើសពីពាក់កណ្តាលនៃសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ទាំងមូលចូលរួម ។ ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវធ្វើការបោះឆ្នោតអនុម័តដោយសម្លេងភាគច្រើនដាច់ខាតនៃសមាជិកក្រុមប្រឹក្សាទាំងមូលដើម្បីសម្រេចបញ្ហាណាមួយដូចខាងក្រោម៖

- អនុម័តលើគម្រោងថវិកា ឃុំ សង្កាត់
- កំណត់តម្លៃសារពើពន្ធមូលដ្ឋានមិនមែនសារពើពន្ធមូលដ្ឋាន និងកម្រៃសេវាផ្សេងៗ
- អនុម័តបទបញ្ជាផ្ទៃក្នុង និងដីកាឃុំ សង្កាត់

[៤៤] ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ មាត្រា៦១,៦២

- កិច្ចការផ្សេងៗទៀតដែលកំណត់ដោយរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។ ក្នុងពេលអនុម័តប្រសិនបើមានសម្លេងឆ្នោតស្មើគ្នាសម្លេងរបស់អធិបតីនៃអង្គប្រជុំមានឧត្តមានុភាព។

ការប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវធ្វើជាសាធារណៈនិងមានលក្ខណៈប្រជាធិបតេយ្យ។ ក្រុមប្រឹក្សាឃុំ សង្កាត់អាចប្រជុំជាសម្ងាត់បាន។ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវចេញសេចក្តីណែនាំ អំពីរបៀបរបបប្រជុំខាងលើនេះ ។[៤៥]

### ២.២.២. មេឃុំ ចៅសង្កាត់

#### ២.២.២.១. លក្ខខណ្ឌនៃការជ្រើសរើសមេឃុំ ចៅសង្កាត់

ប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ដែលជាមេឃុំ ចៅសង្កាត់ត្រូវជ្រើសរើសចេញពីបេក្ខជនលេខរៀងលើគេបង្អស់នៃបញ្ជីបេក្ខជនដែលបានទទួលសម្លេងឆ្នោតច្រើនជាងគេបង្អស់។ ប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ដែលជាមេឃុំ ចៅសង្កាត់មានអាណត្តិស្មើនឹងអាណត្តិរបស់ ក្រុមប្រឹក្សាឃុំ សង្កាត់ ។

ក្នុងករណីដែលលទ្ធផលជាផ្លូវការនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ណាបានផ្តល់សម្លេងគាំទ្រដល់បញ្ជីបេក្ខជនតែមួយដែលមានលក្ខណៈសម្បត្តិទទួលបានអាសនៈទាំងអស់ក្នុងក្រុមប្រឹក្សាត្រូវជ្រើសរើសសមាជិកក្រុមប្រឹក្សាពីក្នុងបញ្ជីតែមួយនោះឲ្យទទួលតំណែងជាមេឃុំ ឬ ចៅសង្កាត់ ជំទប់ទី១ ឬចៅសង្កាត់រងទី១ ជំទប់ទី២ ឬចៅសង្កាត់រងទី២។

#### ២.២.២.២. តួនាទីភារកិច្ចមេឃុំ សង្កាត់

មេឃុំ ចៅសង្កាត់បំពេញតួនាទីភារកិច្ចដូចខាងក្រោមៈ

- អនុវត្តសេចក្តីសម្រេចក្រុមប្រឹក្សាឃុំ សង្កាត់
- អនុវត្តនូវបទប្បញ្ញត្តិ និង គោលការណ៍នានាដែលបានទទួលបានពីក្រុមប្រឹក្សាឃុំ សង្កាត់
- ធ្វើសេចក្តីរាយការណ៍អំពីសកម្មភាពការងារជូនក្រុមប្រឹក្សាឃុំ សង្កាត់របស់ខ្លួនយ៉ាងតិចឲ្យបានមួយដងក្នុងមួយខែ ។
- ផ្តល់យោបល់ផ្សេងៗ និងជួយដល់ក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងការៀបចំផែនការ ហិរញ្ញវត្ថុ និងក្នុងការចាត់ចែងអនុវត្តនូវតួនាទីមុខងារ សិទ្ធិអំណាចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ព្រមទាំងកិច្ចការផ្សេងទៀតដែលក្រុមប្រឹក្សាឃុំ សង្កាត់របស់ខ្លួនប្រគល់ឲ្យ ។[៤៦]

#### ២.២.២.៣. សមាសភាពចៅសង្កាត់ចាក់អង្រែក្រោម

បន្ទាប់ពីបានធ្វើការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិទី៤រួចមកនិងមានការទទួលស្គាល់ពីក្រសួងមហាផ្ទៃផងនោះនៅក្នុងក្រុមប្រឹក្សាសង្កាត់ចាក់អង្រែក្រោមអ្នកដែលត្រូវមានតំណែងជាចៅ

---

[៤៥] សៀវភៅណែនាំស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ឆ្នាំ ២០២២

[៤៦] មាត្រា៣៩ នៃច្បាប់ស្តីពីការគ្រប់គ្រងឃុំ សង្កាត់

សង្កាត់គឺ លោក ជា សុខៃ ជាប្រធានក្រុមប្រឹក្សាសង្កាត់ និងជាចៅសង្កាត់ចាក់អង្រែក្រោម ខណ្ឌមានជ័យ រាជធានីភ្នំពេញ ។[៤៧]

### ២.២.៣. ជំទប់ ឬចៅសង្កាត់រង

#### ២.២.៣.១. លក្ខខណ្ឌនៃការជ្រើសរើស

ជំទប់ទី១ ចៅសង្កាត់រងទី១ត្រូវជ្រើសរើសចេញពីបេក្ខជនដែលមានឈ្មោះលេខរៀងលើគេនៃបញ្ជីបេក្ខជនដែលបានទទួលសម្លេងឆ្នោតលំដាប់ទី២ ។ ជំទប់ទី២ ចៅសង្កាត់រងទី២ត្រូវជ្រើសរើសចេញពីបេក្ខជនដែលមានឈ្មោះលេខរៀងលើគេ នៃបញ្ជីបេក្ខជនដែលបាន ទទួលសម្លេងឆ្នោតលំដាប់ទី៣។

ក្នុងករណីដែលលទ្ធផលជាផ្លូវការនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ណាបានផ្តល់សម្លេងគាំទ្រដល់បញ្ជីបេក្ខជនតែមួយដែលមានលក្ខណៈសម្បត្តិទទួលបានអាសនៈទាំងអស់ក្នុងប្រឹក្សាត្រូវជ្រើសរើសសមាជិកក្រុមប្រឹក្សាពីក្នុងបញ្ជីតែមួយនោះឲ្យទទួលតំណែងជាមេឃុំ ឬចៅសង្កាត់ ជំទប់ទី១ឬចៅសង្កាត់រងទី១ ជំទប់ទី២ ឬចៅសង្កាត់រងទី២ ។

ក្នុងករណីដែលលទ្ធផលជាផ្លូវការនៃការបោះឆ្នោតជ្រើសរើសសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ណាបានផ្តល់សម្លេងគាំទ្រដល់បញ្ជីបេក្ខជនតែពីរ ដែលមានលក្ខណៈសម្បត្តិទទួលបានអាសនៈក្នុងក្រុមប្រឹក្សាត្រូវជ្រើសរើសសមាជិកក្រុមប្រឹក្សាជាបេក្ខជនដែលមានឈ្មោះលេខរៀងបន្ទាប់ពីបេក្ខជនដែលមានឈ្មោះលេខរៀងលំដាប់លើគេបង្អស់នៃបញ្ជីដែលបានទទួលសម្លេងឆ្នោតគាំទ្រលំដាប់ទីមួយឲ្យទទួលតំណែងជាជំទប់ទី១ ឬចៅសង្កាត់រងទី១ និងជ្រើសរើសយកសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ជាបេក្ខជនដែលមានឈ្មោះលេខរៀងលើគេបង្អស់នៃបញ្ជីដែលបានទទួលសម្លេងឆ្នោតគាំទ្រលំដាប់ទី២ ឲ្យទទួលតំណែង ជាជំទប់ទី២ ឬចៅសង្កាត់រងទី២ ។

#### ២.២.៣.២. តួនាទី និងភារកិច្ច

ជំទប់ ឬចៅសង្កាត់រងជាជំនួយការរបស់មេឃុំ ចៅសង្កាត់ក្នុងការអនុវត្តភារកិច្ចដែលមេឃុំ សង្កាត់ប្រគល់ឲ្យ និងជំនួសមេឃុំ ចៅសង្កាត់ទៅតាមឋានានុក្រមនៃជំទប់ ចៅសង្កាត់រងនៅពេលដែលមេឃុំ សង្កាត់អវត្តមាន ។ ជំទប់ ឬចៅសង្កាត់រងត្រូវធ្វើការបែងចែកភារកិច្ចដូចខាងក្រោមៈ

- ជំទប់ទី១ ឬចៅសង្កាត់រងទី១ ទទួលជួយមេឃុំ ចៅសង្កាត់លើកិច្ចការសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។
- ជំទប់ទី២ ឬចៅសង្កាត់រងទី២ ទទួលជួយមេឃុំ ចៅសង្កាត់លើកិច្ចការរដ្ឋបាល សង្គមកិច្ចសេវាសាធារណៈ និងសណ្តាប់ធ្នាប់សាធារណៈ។ មេឃុំ ចៅសង្កាត់អាចប្រគល់ភារកិច្ចបន្ថែមពីលើភារកិច្ចដែលបានបែងចែងខាងលើនេះដល់ជំទប់ ឬចៅសង្កាត់រងរបស់ខ្លួន ។

[៤៧] ជួបសម្ភាសន៍ផ្ទាល់ជាមួយ លោក ជឹម សុរិទ្ធិ ជាសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ នាពេលរសៀល

**២.២.៣.៣. សមាសភាពជំទប់ទី១ និងជំទប់ទី២ សង្កាត់ចាក់អង្រែក្រោម**

បន្ទាប់ពីបានធ្វើការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំសង្កាត់អាណត្តិទី៣រួចមក និងមានការទទួលស្គាល់ពីក្រសួងមហាផ្ទៃផងនោះនៅក្នុងក្រុមប្រឹក្សាសង្កាត់ចាក់អង្រែក្រោមអ្នកដែលត្រូវមានតំណែងជាជំទប់ទី១ និងជំទប់ទី២ គឺមាន លោក សេង ឈុនហេងជាចៅសង្កាត់រងទី១ និង លោក នូ សេងហេង ជាចៅសង្កាត់រងទី២ នៃសង្កាត់ចាក់អង្រែក្រោមខណ្ឌមានជ័យ រាជធានីភ្នំពេញ ។[៤៨]

**២.២.៤. ស្មៀនឃុំ សង្កាត់**

សមាសភាពស្មៀនសង្កាត់ចាក់អង្រែក្រោមគឺ លោក ផាន់ បញ្ញា។[៤៩]

**២.២.៤.១. លក្ខខណ្ឌនៃការតែងតាំង**

ឃុំសង្កាត់ត្រូវមានបុគ្គលិកក្របខណ្ឌរដ្ឋបាលនៃក្រសួងមហាផ្ទៃមួយរូបធ្វើជាស្មៀនឃុំ សង្កាត់ ។ ស្មៀនឃុំសង្កាត់តែងតាំងដោយរដ្ឋមន្ត្រីក្រសួងមហាផ្ទៃដែលមានភារកិច្ចជួយកិច្ចការឃុំសង្កាត់និងធានានិរន្តភាពកិច្ចការរដ្ឋបាលឃុំសង្កាត់។ ស្មៀនឃុំសង្កាត់ត្រូវផ្លាស់ប្តូរក្នុងករណីមានសំណើរបស់មេឃុំចៅសង្កាត់អនុលោមតាមការសម្រេចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ។[៥០]

**២.២.៤.២. តួនាទីភារកិច្ច**

ថ្វីត្បិតតែស្មៀនឃុំសង្កាត់ស្ថិតនៅក្នុងក្របខណ្ឌរដ្ឋបាលស៊ីវិលរបស់ក្រសួងមហាផ្ទៃក៏ពិតមែនប៉ុន្តែក្នុងការអនុវត្តការងារ ស្មៀនឃុំសង្កាត់ ត្រូវស្ថិតនៅក្នុងការដឹកនាំរបស់ក្រុមប្រឹក្សា ឃុំសង្កាត់ ។

ស្មៀនឃុំសង្កាត់ជាអ្នកៈ

- ជួយក្រុមប្រឹក្សាឃុំសង្កាត់ មេឃុំ ចៅសង្កាត់ ជំទប់ ចៅសង្កាត់រង និងគណៈកម្មាធិការនានាបំពេញតួនាទីនិងមុខងារស្របទៅតាមតម្រូវការផ្នែកច្បាប់
- បំពេញការងាររដ្ឋបាល
- ធានាថាសេចក្តីសម្រេច និងការអនុវត្តសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាឃុំសង្កាត់ស្របនឹងលក្ខខណ្ឌច្បាប់
- ជួយក្រុមប្រឹក្សាឃុំសង្កាត់ក្នុងការរៀបចំ និង អនុវត្តកិច្ចប្រជុំរបស់ក្រុមប្រឹក្សា និងគណៈកម្មាធិការនានារបស់ឃុំសង្កាត់
- ចូលរួមគ្រប់កិច្ចប្រជុំរបស់ក្រុមប្រឹក្សាឃុំសង្កាត់ ឬគណៈកម្មាធិការលើកលែងតែ បានទទួលការអនុវត្តឲ្យអវត្តមានជាមុនពីក្រុមប្រឹក្សាឃុំសង្កាត់ ឬ មេឃុំ ចៅសង្កាត់

[៤៨] ជួបសម្ភាសន៍ផ្ទាល់ជាមួយ លោក ជឹម សុរិទ្ធិ ជាសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ នាពេលរសៀល

[៤៩] ជួបសម្ភាសន៍ផ្ទាល់ជាមួយ លោក ជឹម សុរិទ្ធិ ជាសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ នាពេលរសៀល

[៥០] មាត្រា២៨ នៃច្បាប់ស្តីពីការគ្រប់គ្រងឃុំ សង្កាត់

- ជួយដល់ក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងការរៀបចំឲ្យមានក្តារខៀនព័ត៌មានមួយឬច្រើនកន្លែងដើម្បីបិទផ្សាយសេចក្តីជូនដំណឹងសេចក្តីសម្រេច និងលិខិតបទដ្ឋានផ្សេងៗរបស់ក្រុមប្រឹក្សាឃុំសង្កាត់ និងមេឃុំ ចៅសង្កាត់សម្រាប់ឲ្យសាធារណជនទូទៅបានដឹងនូវព័ត៌មានទាំងនោះ ។

### ២.២.៥. មេភូមិ និងជំនួយការភូមិ

ភូមិគឺប្រមូលផ្តុំដោយផ្ទះ និងគ្រួសារប្រជាពលរដ្ឋជាច្រើន។ ភូមិជាច្រើនប្រមូលផ្តុំគ្នាបង្កើតបានជាឃុំ ឬសង្កាត់មួយ។ ភូមិមិនមែនជាថ្នាក់រដ្ឋបាលដែលបានចែងក្នុងរដ្ឋធម្មនុញ្ញឡើយ។ ភូមិនីមួយៗត្រូវគ្រប់គ្រងដោយមេភូមិម្នាក់អមដោយអនុប្រធានម្នាក់ និងសមាជិកម្នាក់ជាជំនួយការ។

#### ២.២.៥.១. លក្ខខណ្ឌនៃការជ្រើសរើស

**លក្ខណៈសម្បត្តិនៃបេក្ខជនមេភូមិ**

បេក្ខជនមេភូមិគឺត្រូវតែជាប្រជាពលរដ្ឋខ្មែរទាំងពីរភេទដែលមានលក្ខណៈសម្បត្តិដូចខាងក្រោម៖

- មានសញ្ជាតិខ្មែរ
- មានឈ្មោះក្នុងបញ្ជីឈ្មោះបោះឆ្នោតក្នុងឃុំ សង្កាត់ដែលសាមីខ្លួនកំពុងរស់នៅ
- មានអាយុយ៉ាងតិច២៥ឆ្នាំគិតត្រឹមថ្ងៃដាក់ស្នើបេក្ខជន
- ចេះអាននិងសរសេរអក្សរខ្មែរ
- ទីលំនៅអចិន្ត្រៃយ៍ក្នុងភូមិ ដែលបានដាក់ស្នើបេក្ខជននោះយ៉ាងតិច០៦ខែជាប់ៗគ្នា។
- មេភូមិនីមួយៗ ដែលបានទទួលការតែងតាំងជាផ្លូវការ រួចហើយត្រូវធ្វើការ ជ្រើសរើសបេក្ខជនជំនួយការរបស់ខ្លួនជាអនុប្រធាន និងសមាជិកភូមិក្នុងរយៈពេលយ៉ាងយូរ ៧ថ្ងៃបន្ទាប់ពីថ្ងៃតែងតាំងមេភូមិជាផ្លូវការ ។

❖ លក្ខណៈសម្បត្តិនៃបេក្ខជនជំនួយការមេភូមិមានដូចតទៅ ៖

- មានសញ្ជាតិខ្មែរ
- មានឈ្មោះក្នុងបញ្ជីឈ្មោះបោះឆ្នោតក្នុងឃុំ សង្កាត់ដែលសាមីខ្លួនកំពុងរស់នៅ
- មានអាយុយ៉ាងតិច២៥ឆ្នាំ គិតត្រឹមថ្ងៃដាក់ស្នើបេក្ខជន
- ចេះអាន និងចេះសរសេរអក្សរខ្មែរ
- មានទីលំនៅអចិន្ត្រៃយ៍ក្នុងភូមិ ដែលបានដាក់ស្នើបេក្ខជននោះយ៉ាងតិច ៦ខែជាប់ៗគ្នា។

#### ២.២.៥.២. អាណត្តិការងារ

មេភូមិ អនុប្រធានភូមិនិងសមាជិកភូមិមិនត្រូវកំណត់អាណត្តិការងារឡើយ ។ មេភូមិអនុប្រធានភូមិ និងសមាជិកភូមិក្នុងមុខតំណែងត្រូវបានបន្តការងាររហូតដល់មានការតែងតាំងមេភូមិ អនុប្រធានភូមិ និងសមាជិកភូមិថ្មីមកជំនួសវិញ។

**២.២.៥.៣. តួនាទីភារកិច្ច**

❖ មេភូមិមានតួនាទីដូចខាងក្រោមៈ

- ទទួលខុសត្រូវរួមក្នុងភូមិរបស់ខ្លួន
- ជាតំណាងឲ្យប្រជាពលរដ្ឋនៅក្នុងភូមិ និងជាខ្សែរយៈចម្បងសម្រាប់ភ្ជាប់ទំនាក់ទំនងរវាងភូមិ និងក្រុមប្រឹក្សាឃុំ សង្កាត់
- បង្កើនការពិគ្រោះយោបល់ទទួលការណែនាំនិងធ្វើកិច្ចសហប្រតិបត្តិការជាមួយក្រុមប្រឹក្សាឃុំ សង្កាត់របស់ខ្លួន។
- ចូលរួមក្នុងកិច្ចប្រជុំគណៈកម្មាធិការនានារបស់ឃុំ សង្កាត់ នៅពេលដែលក្រុមប្រឹក្សា ឃុំ សង្កាត់តម្រូវដើម្បីផ្តល់យោបល់អំពីកិច្ចការដែលពាក់ព័ន្ធក្នុងភូមិរបស់ខ្លួនមានជាអាទិ៍ៈ
    - ផ្តល់យោបល់ដល់ក្រុមប្រឹក្សាឃុំ សង្កាត់អំពីតម្រូវការ និងផលប្រយោជន៍របស់ភូមិ។
    - ផ្តល់យោបល់ដល់ក្រុមប្រឹក្សាឃុំ សង្កាត់អំពីរបៀបបង្កើត និងកសាងសមត្ថភាព និងធនធានរបស់ភូមិ។
- ផ្តល់យោបល់ដល់គណៈកម្មាធិការកសាងផែនការ និងថវិកាឃុំ សង្កាត់អំពីតម្រូវការ និងអាទិភាពរបស់ភូមិដើម្បីបញ្ចូលក្នុងផែនការអភិវឌ្ឍឃុំ សង្កាត់។ ការអនុវត្តផែនការអភិវឌ្ឍឃុំ សង្កាត់ក្នុងភូមិរបស់ខ្លួន ការត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តផែនការអភិវឌ្ឍឃុំ សង្កាត់ក្នុងភូមិរបស់ខ្លួន។
- ត្រូវធ្វើសេចក្តីរាយការណ៍រាល់បញ្ហាដែលពាក់ព័ន្ធ និងភូមិរបស់ខ្លួនដើម្បីដាក់បញ្ចូលក្នុងរបាយការណ៍ប្រចាំឆ្នាំរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ។
- ត្រូវរួមកិច្ចប្រជុំរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងករណីមានសំណូមពររបស់ក្រុម ប្រឹក្សាឃុំ សង្កាត់ ។
- ត្រូវធានាផ្តល់ព័ត៌មានជាឯកសារសាធារណៈដែលពាក់ព័ន្ធនឹងភូមិរបស់ខ្លួន ។ ឯកសារព័ត៌មានទាំងនោះអាចរួមមានព័ត៌មានស្តីពីការប្រជុំរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ផែនការ អភិវឌ្ឍន៍និងថវិកាឃុំ សង្កាត់។
- ត្រូវទទួលខុសត្រូវអនុវត្តការងារដែលបានប្រគល់ឲ្យដោយក្រុមប្រឹក្សា ឃុំ សង្កាត់របស់ខ្លួន ។

❖ ជំនួយការមេភូមិមានតួនាទីដូចខាងក្រោមៈ

- អនុប្រធានភូមិទទួលការងារជំនួសមេភូមិក្នុងពេលមេភូមិអវត្តមានដោយមូលហេតុច្បាស់លាស់ដូចជាមានជម្ងឺ ឬមានបេសកកម្មចេញក្រៅឃុំសង្កាត់របស់ខ្លួនលើសពី១ថ្ងៃក្រៅពីនេះអនុប្រធានត្រូវទទួលជួយមេភូមិលើការអនុវត្តគម្រោងអភិវឌ្ឍន៍នានាក្នុងភូមិតាមគ្រោងផែនការរបស់ឃុំ សង្កាត់ ។
- សមាជិកភូមិទទួលជួយធ្វើជាលេខាធិការឲ្យមេភូមិ និងទទួលជួយមេភូមិលើការងារ ស្ថិតិការចុះបញ្ជីប្រជាពលរដ្ឋ និងការរក្សាឯកសារនានារបស់ភូមិ

**ក. ភូមិទួលរកា**

ភូមិទួលរកា មានប្រជាពលរដ្ឋរស់នៅចំនួន ១.២៣៦ គ្រួសារ និងមានផ្ទៃដីសរុប ៩២០២៤២.១២ ម៉ែត្រការ៉េ ។ ម្យ៉ាងវិញទៀតប្រជាពលរដ្ឋដែលរស់នៅក្នុងភូមិទួលរកាភាគច្រើនជាអ្នកប្រកបរបររកស៊ីលក់ដូរឬជាអាជីវករនៅតាមផ្ទះ ជាមន្ត្រីរាជការ និងអ្នកធ្វើការ រោងចក្រ ។[៥១]

**ក.១. ភូមិទួលរកា១**

ភូមិទួលរកា១ មានប្រជាពលរដ្ឋរស់នៅចំនួន ១.២៧១គ្រួសារ និងមានផ្ទៃដីសរុប ១២៤៨៦៥១.១៨ ម៉ែត្រការ៉េ។ ជាក់ស្តែងប្រជាពលរដ្ឋដែលកំពុងរស់នៅក្នុងភូមិទួលរកា១ ភាគច្រើនជាអ្នកប្រកបរបររកស៊ីលក់ដូរនៅតាមផ្ទះ នៅតាមរោងចក្រជាមន្ត្រីរាជការ និងអ្នកធ្វើការរោងចក្រ ។

**ក.២. ភូមិទួលរកា២**

ភូមិទួលរកា២ មានប្រជាពលរដ្ឋរស់នៅចំនួន ៣៧៩គ្រួសារ និងមានផ្ទៃដីសរុប ៩៤៨៩២០.៧៧ ម៉ែត្រការ៉េ។ ជាក់ស្តែងប្រជាពលរដ្ឋដែលកំពុងរស់នៅ ក្នុងភូមិទួលរកា២ភាគច្រើន ជាអ្នកប្រកបរបររកស៊ីលក់ដូរនៅតាមផ្សារ នៅតាមរោងចក្រ ជាមន្ត្រីរាជការ និងអ្នកធ្វើការរោងចក្រ ។

**ក.៣. ភូមិទួលរកា៣**

ភូមិទួលរកា៣ មានប្រជាពលរដ្ឋរស់នៅចំនួន ៣០៣គ្រួសារ និងមានផ្ទៃដីសរុប ១៥១១៨៤៩.៦៤ ម៉ែត្រការ៉េ។ ជាក់ស្តែងប្រជាពលរដ្ឋដែលកំពុងរស់នៅក្នុងភូមិទួលរកា ៣ ភាគច្រើនជាអ្នកប្រកបរបររកស៊ីលក់ដូរនៅតាមផ្ទះ នៅតាមរោងចក្រជាមន្ត្រីរាជការ និង អ្នកធ្វើការរោងចក្រ ។

**ខ.ភូមិព្រែកតាឡុង**

ភូមិព្រែកតាឡុង មានប្រជាពលរដ្ឋរស់នៅចំនួន ៤០៨គ្រួសារ និងមានផ្ទៃដីសរុប ៧៩៩៨៧៩.០៨ ម៉ែត្រការ៉េ។ ជាក់ស្តែងប្រជាពលរដ្ឋដែលកំពុងរស់នៅ ក្នុងភូមិព្រែកតាឡុងភាគច្រើនជាអ្នកប្រកបរបររកស៊ីលក់ដូរ ដាំដំណាំ នៅតាមផ្ទះ ចិញ្ចឹមត្រី ធ្វើការសំណង់ និងការងារ រោងចក្រ ។

**ខ.១.ភូមិព្រែកតាឡុង១**

ភូមិព្រែកតាឡុង១ មានប្រជាពលរដ្ឋរស់នៅចំនួន ៤៥០គ្រួសារ និងមានផ្ទៃដីសរុប ១៤៤០៦៦១.៣៦ ម៉ែត្រការ៉េ។ ជាក់ស្តែងប្រជាពលរដ្ឋដែលកំពុងរស់នៅក្នុងភូមិព្រែកតាឡុង ១ភាគច្រើនជាអ្នកប្រកបរបររកស៊ីលក់ដូរនៅតាមផ្ទះ នៅតាមរោងចក្រ ជាមន្ត្រីរាជការ និងជាកម្មករឡានដ្ឋ ។

[៥១] ជួបសម្ភាសន៍ផ្ទាល់ជាមួយ លោក ជឹម សុរិទ្ធិ ជាសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ នាពេលរសៀល

**ខ.២. ភូមិព្រៃកតាឡុង២**

ភូមិព្រៃកតាឡុង២ មានប្រជាពលរដ្ឋរស់នៅចំនួន ៣៣៣គ្រួសារ និងមានផ្ទៃដីសរុប ៩៨៨០៥៩.០៨ ម៉ែត្រការ៉េ។ ជាក់ស្តែងប្រជាពលរដ្ឋដែលកំពុងរស់នៅក្នុងភូមិព្រៃកតាឡុង២ ភាគច្រើនជាអ្នកប្រកបរបររកស៊ីលក់ដូរនៅតាមផ្ទះ នៅតាមរោងចក្រ ជាមន្ត្រីរាជការ និងអ្នកធ្វើការរោងចក្រ ។

**ខ.៣. ភូមិព្រៃកតាឡុង៣**

ភូមិព្រៃកតាឡុង៣ មានប្រជាពលរដ្ឋរស់នៅចំនួន ៣៧៣គ្រួសារ និងមានផ្ទៃដីសរុប ១៤១៩៥១៣.៨៤ ម៉ែត្រការ៉េ ។ ជាក់ស្តែងប្រជាពលរដ្ឋដែលកំពុងរស់នៅក្នុងភូមិព្រៃកតាឡុង ៣ភាគច្រើនជាអ្នកប្រកបរបររកស៊ីលក់ដូរនៅតាមផ្ទះ នៅតាមរោងចក្រ ជាមន្ត្រីរាជការ និងអ្នក ធ្វើការរោងចក្រ ។

## ២.៣. ការគ្រប់គ្រងរដ្ឋបាលសង្កាត់ចាក់អង្រែក្រោម

### ២.៣.១. ការងាររដ្ឋបាល

យោងតាមអនុក្រឹតលេខ ២២ អនក្រ.បក ស្តីពីការផ្ទេរមុខងារអំណាច តួនាទី និងភារកិច្ចទៅឲ្យក្រុមប្រឹក្សាឃុំ សង្កាត់ត្រង់មាត្រា៩ចែងថាៈ[៥២]

- ឃុំ សង្កាត់ គឺជាម្ចាស់លើរាល់លិខិត និងឯកសារដែលរៀបចំឡើងដោយក្រុមប្រឹក្សា សង្កាត់ ឬ ក្នុងនាមក្រុមប្រឹក្សាឃុំ សង្កាត់ និងជាម្ចាស់លើសិទ្ធិលើ តែម ត្រាឃុំសង្កាត់ព្រមទាំងឧបករណ៍ផ្សេងៗទាំងអស់របស់ឃុំសង្កាត់ ។
- ក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវធានាទុកដាក់ឯកសារទាំង លិខិតស្នាម តែម ត្រាឲ្យបានត្រឹមត្រូវនិងគង់វង្ស ។
- ការគ្រប់គ្រងឯកសារ គឺជាការរៀបចំទុកដាក់ និង ថែរក្សាឯសារទាំងឡាយតាមប្រពន្ធ័មួយមានសណ្តាប់ធ្នាប់និងមានសុវត្ថិភាព។ការគ្រប់គ្រងឯកសារនឹងផ្តល់នូវផលប្រយោជន៍ មួយចំនួនដូចជាៈ
    - បង្កលក្ខណៈងាយស្រួលក្នុងការស្វែងរកព័ត៌មាន និងទិន្នន័យសម្រាប់ដឹកនាំនៅ ក្នុងការពិភាក្សា និងការធ្វើសេចក្តីសម្រេច។
    - ជួយបន្តនិន្តរភាពព័ត៌មាននៅពេលមាន អ្នកមកកាន់ការងារថ្មី និងផ្លាស់ចេញ ។
    - ផ្តល់នូវភស្តុតាងជាក់លាក់ពីកិច្ចការ ឬព្រឹត្តិការណ៍ដែលកើតរួចមកហើយ ។
    - បង្កើតប្រសិទ្ធភាព និងសន្សំពេលវេលាដល់ការងាររដ្ឋបាលឃុំ សង្កាត់ ។

[៥២] អនុក្រឹតលេខ ២២ អនក្រ.បកស្តីពីការផ្ទេរមុខងារអំណាច តួនាទី និងភារកិច្ចទៅឲ្យក្រុមប្រឹក្សាឃុំ សង្កាត់

### ២.៣.២. ការគ្រប់គ្រងធនធានមនុស្ស

ការគ្រប់គ្រងបុគ្គលិករបស់រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវផ្តោតទៅលើអភិក្រមដូចជា ១/ការជ្រើសរើសត្រូវបានរៀបចំឡើងដោយផ្អែកតាមផែនការដែលបានកំណត់ និងត្រូវជ្រើសរើសឡើងតាមគោលការណ៍ប្រគួតប្រជែងប្រកបដោយតម្លាភាព យុត្តិធម៌ សមធម៌ និងផ្អែកលើគុណសម្បត្តិស័ក្តិសម ដោយផ្តល់អាទិភាពដល់ស្ត្រីជនពិការ និងជនជាតិដើមភាគតិចជាដើម ២/ ការដំឡើងថ្នាក់ ឋានន្តរស័ក្តិ និងការតែងតាំង ដោយពិចារណាជាពិសេសលើអតីតភាពការងារគុណសម្បត្តិ និងគុណផល ៣/ ការផ្ទេរ និងការផ្លាស់ប្តូរទីកន្លែងធ្វើការត្រូវបង្កើតគោលការណ៍ និងយន្តការសម្រាប់ការផ្ទេរ និងការផ្លាស់ប្តូរទីកន្លែងធ្វើការ ៤/ សីលធម៌ និងវិន័យត្រូវរៀបចំក្រមសីលធម៌ និងកំណត់អំពីវិធាននិងយន្តការក្នុងការដាក់វិន័យឲ្យបានច្បាស់លាស់ ៥/ ការចាកចេញពីអាជីពត្រូវកំណត់គោលការណ៍ចាកចេញពីមុខងារសាធារណៈសម្រាប់មន្ត្រីរាជការស៊ីវិលដូចជាការចូលនិវត្តន៍ការបាត់បង់សម្បទាវិជ្ជាជីវៈការសុំឈប់ដោយស្ម័គ្រចិត្តវិធានការណ៍ខាងវិន័យ និងមរណភាពជាដើមព្រមទាំងត្រូវកំណត់គោលការណ៍សម្រាប់ការបញ្ចប់ការងារបុគ្គលិកជាប់កិច្ចសន្យា ទីប្រឹក្សា និងបុគ្គលិកអណ្តែត។

### ២.៣.៣. ការវិនិយោគបីឆ្នាំរំកិល

#### ២.៣.៣.១. និយមន័យ

ការកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ គឺជាការធ្វើឲ្យខ្លឹមសារនៃផែនការអភិវឌ្ឍឃុំទៅជាសកម្មភាព ឬសេវាជាក់ស្តែងដោយមានភ្ជាប់នូវចំណាយមូលនិធិសំដៅលើកកម្ពស់ការផ្តល់សេវាសាធារណៈ និងកិច្ចអភិវឌ្ឍនៅក្នុងឃុំសម្រាប់រយៈពេលបីឆ្នាំ និងធ្វើបច្ចុប្បន្នភាពជារៀងរាល់ឆ្នាំ។

ការរៀបចំកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ ឆ្លុះបញ្ចាំងពីគម្រោង ឬសេវាជាអាទិភាព និងតម្លៃតាមបណ្តាឆ្នាំនីមួយៗដែលនឹងផ្តល់ធាតុចូលយ៉ាងសំខាន់អំពីបញ្ហាតម្រូវការរបស់ប្រជាពលរដ្ឋដល់ក្រុមប្រឹក្សា ស្រុក ខេត្ត ហើយក្រុមប្រឹក្សាស្រុក ខេត្តត្រូវពិចារណា និងឆ្លើយតបនឹងបញ្ហាតម្រូវការទាំងនោះព្រមទាំងត្រូវមានគណនេយ្យភាពចំពោះក្រុមប្រឹក្សាឃុំ និងប្រជាពលរដ្ឋ។

គម្រោងសកម្មភាពវិនិយោគគឺជាគម្រោងសកម្មភាពត្រូវចំណាយមូលនិធិដោយមានពេលចាប់ផ្តើម និងពេលបញ្ចប់ច្បាស់លាស់ដែលរៀបចំឡើងដើម្បីបង្កើតទ្រព្យសម្បត្តិសាធារណៈ (ហេដ្ឋារចនា សម្ព័ន្ធរូបវន្ត និងអរូបវន្ត) និងសេវានានាសម្រាប់ឆ្លើយតបតាមតម្រូវការជាអាទិភាពរបស់ប្រជាពលរដ្ឋ។

#### ២.៣.៣.២. គោលការណ៍

យោងតាមមាត្រា៥នៃអនុក្រឹត្យលេខ២១៩អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ការរៀបចំ និងកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ ត្រូវផ្អែកលើគោលការណ៍សំខាន់ដូចខាងក្រោម៖

១. ការចែករំលែកព័ត៌មាន

២. តម្លាភាព

៣. សង្គតិភាព និងសុខដុមនីយកម្ម

៤. ការចូលរួមពិគ្រោះយោបល់ជាទូទៅ

៥. ការឆ្លើយតបនឹងតម្រូវការ

៦. គណនេយ្យភាពតាមបែបប្រជាធិបតេយ្យ

៧. ប្រសិទ្ធភាព និងសុក្រឹតភាពសេដ្ឋកិច្ច និងសង្គម

៨. ការធានាចីរភាពធនធានធម្មជាតិ និងបរិស្ថាន

៩. ការធានាសមធម៌។

**២.៣.៣.៣. យន្តការ និងភារកិច្ច**

យន្តការដែលទទួលខុសត្រូវក្នុងការរៀបចំ និងកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំគឺ ៖

**ក. ក្រុមប្រឹក្សាឃុំ**

ក្រុមប្រឹក្សាឃុំមានភារកិច្ចដូចជាពិនិត្យ និងអនុម័តកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំដោយធានាឲ្យមានភាពគ្រប់ជ្រុងជ្រោយ និង ឆ្លើយតបនឹងសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋដូចជាស្រ្តី កុមារ ជនពិការ យុវជន និងជនងាយរងគ្រោះ។ល។ តាមដាន និងវាយតម្លៃអំពីលទ្ធផលនៃការអនុវត្តកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំពិនិត្យ និងអនុម័តលើរាល់ការកែតម្រូវកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ ក្នុងករណីចាំបាច់។

**ខ. មេឃុំ**

មេឃុំមានភារកិច្ចដូចជាដឹកនាំការងារកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំដាក់សេចក្តីព្រាងកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំជូនទៅក្រុមប្រឹក្សាឃុំដើម្បីពិនិត្យ និងអនុម័ត។

**គ. គណៈកម្មាធិការកសាងផែនការ និងថវិកាឃុំ (គ.៩.៩)**

គណៈកម្មាធិការកសាងផែនការ និងថវិការឃុំ (គ.៩.៩) មានភារកិច្ច ជួយមេឃុំក្នុងការរៀបចំ និងកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំដោយអនុវត្តតាមបែបបទនីតិវិធីដូចមានកំណត់ក្នុងសេចក្តីណែនាំបច្ចេកទេសនេះជួយមេឃុំក្នុងការរៀបចំថវិកាប្រចាំឆ្នាំរបស់ឃុំ។

**ឃ. គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ (គ.ក.ន.ក)**

គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ (គ.ក.ន.ក) មានភារកិច្ចចូលរួមផ្តល់ព័ត៌មាន និងការពារខ្លឹមសារការងារក្នុងដែនសមត្ថកិច្ចខ្លួននៅក្នុងដំណើរការកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំសហការបំពេញការងារតាមសំណូមពរពី គ.ផ.ថដើម្បីកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ។

**ង. មន្ទីរផែនការខេត្ត**

មន្ទីរផែនការខេត្តមានភារកិច្ចគាំទ្របច្ចេកទេសកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ ដូចជាការងារស្រង់ទិន្នន័យពីមូលដ្ឋាន ភូមិ ឃុំ ការងារចងក្រងកម្រងព័ត៌មានស្ថានភាពឃុំប្រចាំឆ្នាំ ឯកសារពិន្ទុវិស័យ និងគាំទ្រការងារ រៀបចំ និងសម្របសម្រួលក្នុងសិក្ខាសាលាសមាហរណកម្មនៅស្រុក។ សហការជាមួយមណ្ឌលអភិវឌ្ឍន៍ធនធានមនុស្សខេត្ត និងទីចាត់ការផែនការ និងវិនិយោគ ខេត្តក្នុងការបណ្តុះបណ្តាលអំពីបច្ចេកទេសកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ ការប្រើប្រាស់ទិន្នន័យ និងបច្ចេកទេសតាមដាន និងវាយតម្លៃលទ្ធផលអនុវត្តកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ។ សហការផ្តល់ការគាំទ្របច្ចេកទេសអំពីការកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ និងការតាមដាន និងវាយតម្លៃលទ្ធផលនៃការអនុវត្តកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំដល់សមាជិកក្រុមប្រឹក្សាឃុំ ស្មៀនឃុំ និងបុគ្គលិកសំខាន់ៗរបស់ឃុំ តាមសំណើពីអ្នកពាក់ព័ន្ធ។

**ច. ទីចាត់ការផែនការ និងវិនិយោគខេត្ត**

ទីចាត់ការផែនការ និងវិនិយោគខេត្តមានភារកិច្ចផ្តល់ការបណ្តុះបណ្តាលដល់សមាជិកក្រុមប្រឹក្សាឃុំ គ.ផ.ថ និងអ្នកពាក់ព័ន្ធអំពីនីតិវិធីកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំដោយមានកិច្ចសហការជាមួយមណ្ឌលអភិវឌ្ឍធនធានមនុស្ស ខេត្ត មន្ទីរផែនការខេត្ត និងឬអង្គភាពជំនាញក្នុងករណីចាំបាច់។ ជំរុញ និងគាំទ្រការប្រមូល និងរក្សាសៀវភៅកម្មវិធីវិនិយោគទុកជាឯកសារជួយក្រុមប្រឹក្សាឃុំ ក្នុងការរៀបចំអនុវត្តកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំតាមដាន និងវាយតម្លៃអំពីលទ្ធផលនៃការអនុវត្តកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ។

**ឆ. ការិយាល័យផែនការ និងគាំទ្រឃុំ សង្កាត់**

ការិយាល័យផែនការ និងគាំទ្រឃុំ សង្កាត់មានភារកិច្ចដូចជា៖

- ជួយក្រុមប្រឹក្សាឃុំ ក្នុងការវិភាគ វាយតម្លៃ និងរៀបចំកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ
- សហការគាំទ្រក្រុមប្រឹក្សាឃុំ ក្នុងការរៀបចំថវិកាឃុំ
- សហការពិនិត្យ និងលើកអនុសាសន៍ជូនអភិបាលខេត្ត អំពីការធ្វើអនុលោមភាពថវិកាឃុំ
- សម្របសម្រួល និងប្រមូលឯកសារបញ្ជូនទៅអង្គភាពពាក់ព័ន្ធ
- សិក្សាវាយតម្លៃ និងលើកយោបល់អំពីសមត្ថភាពរបស់ក្រុមប្រឹក្សាឃុំ និងតម្រូវការគាំទ្រ
- ជួយក្រុមប្រឹក្សាឃុំ ក្នុងការដោះស្រាយសំណើ សំណូមពរ និងបញ្ហាប្រឈមនានារបស់ឃុំ
- គាំទ្រក្រុមប្រឹក្សាឃុំក្នុងការរៀបចំការកសាង និងការអនុវត្តកម្មវិធីវិនិយោគឃុំ
- ជួយក្រុមប្រឹក្សាឃុំ ក្នុងការពិនិត្យ និងវាយតម្លៃការប្រើប្រាស់មូលនិធិវិនិយោគឃុំ ។

**ជ. ការិយាល័យផែនការស្រុក**

ការិយាល័យផែនការស្រុកមានភារកិច្ចដូចជា៖

- ជួយសម្របសម្រួល និងជំរុញអាជ្ញាធរភូមិ ឃុំក្នុងការស្រង់ទិន្នន័យមូលដ្ឋានភូមិ ឃុំ
- ជួយ គ.ផ.ថ ក្នុងការវិភាគព័ត៌មានស្ថានភាព និងពិន្ទុវិស័យភូមិ ឃុំ
- ជួយឃុំក្នុងការរៀបចំបណ្តាឧបករណ៍សម្រាប់ចូលរួមសិក្ខាសាលាសមាហរណកម្មនៅស្រុក។

**ឈ. មន្ទីរជំនាញ និងអង្គភាពពាក់ព័ន្ធនានាថ្នាក់ខេត្ត**

មន្ទីរជំនាញ និងអង្គភាពពាក់ព័ន្ធនានាថ្នាក់ខេត្តមានភារកិច្ចទទួលខុសត្រូវផ្តល់ជំនួយបច្ចេកទេសដែលពាក់ព័ន្ធនឹងជំនាញរបស់ខ្លួនដល់ការរៀបចំ និងកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំដូចជាយេនឌ័រការប្រែប្រួលអាកាសធាតុពិការភាព។ល។ ផ្តល់ការគាំទ្រគម្រោងសកម្មភាពវិនិយោគនានារបស់ឃុំនៅក្នុងសិក្ខាសាលាសមាហរណកម្មកម្មវិធីវិនិយោគបីឆ្នាំរំកិលនៅថ្នាក់ស្រុកជួយរដ្ឋបាលឃុំក្នុងការរៀបចំ និងអនុវត្តគម្រោងសកម្មភាពនានារបស់ឃុំ ។

**ញ. អង្គការសង្គមស៊ីវិល វិស័យឯកជន និងអ្នកពាក់ព័ន្ធនានា**

អង្គការសង្គមស៊ីវិលវិស័យឯកជននិងអ្នកពាក់ព័ន្ធនានាមានភារកិច្ចចូលរួមជាតំណាងឲ្យផលប្រយោជន៍របស់សហគមន៍មូលដ្ឋាន និងអ្នកពាក់ព័ន្ធណាមួយជាក់លាក់ដូចជាតំណាងឲ្យស្ត្រី កុមារ យុវជន ជនក្រីក្រជនជាតិដើមភាគតិច។ល។ ចូលរួមផ្តល់ចំណេះដឹង និងគំនិតល្អៗក្នុងការរៀបចំកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំចូលរួមក្នុងការពិភាក្សា និងពិគ្រោះយោបល់នានាដែលពាក់ព័ន្ធនឹងដំណើរការកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំព្រមទាំងផ្តល់ការគាំទ្រគម្រោងសកម្មភាពវិនិយោគនានារបស់ឃុំក្នុងសិក្ខាសាលាសមាហរណកម្មកម្មវិធីវិនិយោគបីឆ្នាំរំកិលនៅថ្នាក់ស្រុក។

**ដ. ប្រជាពលរដ្ឋ**

ក្នុងដំណើរការកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំប្រជាពលរដ្ឋក្នុងឃុំគប្បីត្រូវបានចូលរួមក្នុងកិច្ចប្រជុំពិគ្រោះយោបល់កំណត់បញ្ហា និងតម្រូវការអាទិភាពនានាក្នុងសមហគមន៍ និងមូលដ្ឋានខ្លួនទៅតាមស្ថានភាពជាក់ស្តែងរបស់សាមីខ្លួននីមួយៗ។

## ២.៤. ការគ្រប់គ្រងហិរញ្ញវត្ថុសង្កាត់ចាក់អង្រែក្រោម

ការគ្រប់គ្រងហិរញ្ញវត្ថុសង្កាត់ចាក់អង្រែក្រោម ត្រូវបានបង្កើតឡើងដែលរួមមានប្បញ្ញត្តិ និងនីតិវិធីទាក់ទងទៅនឹងការងារដូចជាថវិកាឃុំ សង្កាត់ប្រព័ន្ធគណនេយ្យ និងប្រព័ន្ធទូទាត់សម្រាប់ឃុំ សង្កាត់ការគ្រប់គ្រងចំណាយរបស់ឃុំ សង្កាត់ទ្រព្យសម្បត្តិឃុំ សង្កាត់សវនកម្ម និងរបាយការណ៍ហិរញ្ញវត្ថុឃុំ សង្កាត់។

### ២.៤.១. ការរៀបចំ និងអនុម័តថវិការសង្កាត់

គម្រោងថវិកាត្រូវរៀបចំឡើងក្រោមការទទួលខុសត្រូវរបស់មេឃុំ ចៅសង្កាត់ និងដោយមានជំនួយការពីគណៈកម្មាធិការកសាងផែនការ និងថវិការឃុំ សង្កាត់ហើយត្រូវបញ្ជូនទៅក្រុមប្រឹក្សាឃុំ សង្កាត់ ពិនិត្យ និងអនុម័ត។

ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវអនុម័តគម្រោងថវិកានាកិច្ចប្រជុំជាសាធារណៈឲ្យបានមុន ថ្ងៃទី៣១ ខែតុលា។ ក្រុមប្រឹក្សា ឃុំ សង្កាត់ត្រូវអនុម័តគម្រោងថវិកាតាមផ្នែកនឹងតាមប្រភេទនីមួយៗ។

មេឃុំ ចៅសង្កាត់ត្រូវធានាឲ្យមានការចូលរួមពីសាធារណជនមូលដ្ឋានក្នុងដំណើរការរៀបចំថវិកាតាមរយៈវិធានការទាំងឡាយដូចខាងក្រោម៖

- គម្រោងថវិកាត្រូវតែប្រកាសផ្សាយជាសាធារណៈយ៉ាងតិច២សប្តាហ៍មុនពេលកិច្ចប្រជុំរបស់ក្រុមប្រឹក្សាឃុំ សង្កាត់
- អង្គប្រជុំរបស់គណៈកម្មាធិការកសាងផែនការ និងថវិកាត្រូវបើកចំហដល់សាធារណជនដែលចាប់អារម្មណ៍លើការពិនិត្យកំពោងថវិកានេះ
- ប្រជាពលរដ្ឋត្រូវតែបានផ្តល់កាលានុវត្តភាពក្នុងការចូលរួមសម័យប្រជុំរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ដែលសម្រេចលើគម្រោងថវិកា ។
- ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវបង្កើតនូវយន្តការផ្សេងៗ ដើម្បីជំរុញឲ្យមានការចូលរួមពីសាធារណជនលើកិច្ចការមូលដ្ឋាន។

មេឃុំ ចៅសង្កាត់ត្រូវបញ្ជូនគម្រោងថវិកាដែលបានអនុម័តរួចទៅអភិបាលខេត្ត ក្រុងឲ្យបានមុនថ្ងៃ ទី៥ ខែវិច្ឆិកា ដើម្បីបញ្ជាក់ទទួលស្គាល់ ។

គម្រោងថវិកាត្រូវភ្ជាប់ជាមួយនូវឯកសារពាក់ព័ន្ធដូចខាងក្រោមៈ

- របាយការណ៍សង្ខេបស្តីពីមូលដ្ឋានក្នុងការរៀបចំចំណូល និងចំណាយព្រមទាំងកំរិតចូលរួមរបស់ប្រជាពលរដ្ឋក្នុងដំណើរការរៀបចំថវិកា
- របាយការណ៍ស្តីពីការអនុវត្តន៍ថវិកានៃឆ្នាំដំណើរការ
- តារាងសង្ខេបនៃការវិនិយោគហេដ្ឋារចនាសម្ព័ន្ធមូលដ្ឋានដែលបានបញ្ជាក់ក្នុងផែនការអភិវឌ្ឍឃុំសង្កាត់ ប្រសិនបើមានកំណត់ហេតុស្តីពីកិច្ចប្រជុំអន្លើតលើគម្រោងថវិការបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ។

អភិបាលខេត្ត ក្រុង ត្រូវត្រួតពិនិត្យអនុលោមភាព និងបញ្ជាក់ទទួលស្គាល់លើគម្រោងថវិកាឲ្យបានមុនថ្ងៃទី ៣០ ខែវិច្ឆិកា ។

ការត្រួតពិនិត្យអនុលោមភាពត្រូវឆ្លើយតបទៅនឹងចំណុចដូចខាងក្រោមៈ

១. ទម្រង់ថវិកា និងការចូលរួមរបស់ប្រជាពលរដ្ឋក្នុងការរៀបចំថវិកា

២. តុល្យភាពថវិកា និងការប្រើប្រាស់ចំណូលមូលធន

៣. ល័ក្ខខ័ណ្ឌនៃការប្រើប្រាស់មូលនិធិឃុំ សង្កាត់ដែលទទួលបាន

៤. ការគ្រោងឥណទានថវិកាទៅតាមគោលការណ៍ចំណាយចាំបាច់

៥. តម្រូវការថវិកាវិនិយោគសំរាប់ហេដ្ឋារចនាសម្ព័ន្ធមូលដ្ឋានដែលបានបញ្ជាក់ច្បាស់លាស់ក្នុងផែនការរបស់ឃុំ សង្កាត់ ។

អភិបាលខេត្តក្រុងមិនមានសិទ្ធិកែប្រែ ឬជំទាស់ទៅនឹងជំរើសនៃការចំណាយដែលបានសម្រេចដោយក្រុមប្រឹក្សាឃុំ សង្កាត់ក្រៅពីពិនិត្យលើលក្ខខ័ណ្ឌទាំងឡាយដែលឆ្លើយតបទៅនឹងការត្រួតពិនិត្យអនុលោមភាព ។

ប្រសិនបើគម្រោងថវិកាត្រូវបានបំពេញតាមល័ក្ខខ័ណ្ឌនៃការត្រួតពិនិត្យអនុលោមភាពដូចមានចែងក្នុងមាត្រា ១៤ នៃអនុក្រឹត្យនេះអភិបាលខេត្ត ក្រុងត្រូវបញ្ជាក់ទទួលស្គាល់លើគម្រោងថវិកា និងចេញសេចក្តីជូនដំណឹងជាលាយល័ក្ខអក្សរជូនមេឃុំ ចៅសង្កាត់ ។ សេចក្តីជូនដំណឹងត្រូវភ្ជាប់ជាមួយឯកសារថវិកាដែលមានហត្ថលេខាសង្ខេបរបស់អភិបាលខេត្ត ក្រុង នឹងបោះត្រាលើទំព័រនីមួយៗ ។

អភិបាលខេត្ត ក្រុងត្រូវចំលងជូនសេចក្តីជូនដំណឹងព្រមទាំងថវិកាដែលបានបញ្ជាក់ទទួលស្គាល់ទៅមន្ទីរសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រតនាគារខេត្ត ក្រុង ។

ក្នុងករណីដែលអភិបាលខេត្ត ក្រុងមិនបញ្ជាក់ទទួលស្គាល់លើគម្រោងថវិកាអភិបាលខេត្តក្រុងត្រូវជូនដំណឹងបន្ទាន់ជាលាយល័ក្ខអក្សរដល់មេឃុំ ចៅសង្កាត់ដោយបញ្ជាក់ពីមូលហេតុហើយពែកនាំដល់មេឃុំ ចៅសង្កាត់ឲ្យអនុវត្តវិធានការកែតម្រូវ ។

មេឃុំ ចៅសង្កាត់ត្រូវពិនិត្យកែសម្រួលគម្រោងថវិកាឡើងវិញតាមការណែនាំរបស់អភិបាលខេត្ត ក្រុងហើយដាក់ជូនក្រុមប្រឹក្សាឃុំ សង្កាត់អនុម័តក្នុងរង្វង់១៥ថ្ងៃបន្ទាប់ពីបានទទួលសេចក្តីជូនដំណឹងរបស់អភិបាល ខេត្ត ក្រុង ។

បន្ទាប់ពីការពិភាក្សាមេឃុំ ចៅសង្កាត់ធ្វើគម្រោងថវិកាកែតម្រូវជូនអភិបាលខេត្ត ក្រុងបញ្ជាក់ទទួលស្គាល់ ។

ប្រសិនបើមេឃុំ ចៅសង្កាត់ខកខានមិនបានបញ្ជូនគម្រោងថវិកាដែលបានពិនិត្យឡើងវិញដល់អភិបាលខេត្ត ក្រុង ក្នុងរង្វង់មួយខែបន្ទាប់ពីទទួលបានសេចក្តីជូនដំណឹងខាងលើ ឬគម្រោងថវិកាដែលបានពិនិត្យឡើងវិញនៅតែមិនទាន់ឆ្លើយតបបានទៅនឹងការត្រួតពិនិត្យអនុលោមភាពពេលនោះអភិបាលខេត្ត ក្រុងមានសិទ្ធិចាត់វិធានការកែសម្រួលចាំបាច់មុនពេលបញ្ជាក់ទទួលស្គាល់លើគម្រោងថវិកា ។ អភិបាលខេត្ត ក្រុងត្រូវជូនដំណឹងអំពីសេចក្តីសម្រេចរបស់ខ្លួនដល់មេឃុំ ចៅសង្កាត់ មន្ទីរ សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រតនាគារខេត្ត ក្រុងតាមនីតិវិធី។

ក្នុងករណីមានការមិនចុះសំរុងគ្នារវាងមេឃុំ ចៅសង្កាត់ជាមួយអភិបាលខេត្ត ក្រុង មេឃុំ ចៅសង្កាត់ត្រូវបញ្ជូនករណីនេះទៅរដ្ឋមន្ត្រីក្រសួងមហាផ្ទៃដើម្បីពិនិត្យសម្រេច។ សេចក្តីសម្រេចរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃមាត់ទុកជាការសម្រេចចុងក្រោយ ។

ក្នុងករណីអភិបាលខេត្ត ក្រុងមិនបានបញ្ជាក់ទទួលស្គាល់លើគម្រោងថវិកាមុនថ្ងៃទី០១ ខែមករានៃឆ្នាំ មេឃុំ ចៅសង្កាត់ត្រូវបានអនុញ្ញាតឲ្យអនុវត្តជាបណ្តោះអាសន្នលើចំណាយប្រចាំខែក្នុងកំរិត ១/១២ នៃថវិកាដែលបានអនុម័តឆ្នាំមុន និងលើការប្រមូលចំណូលរបស់ឃុំ សង្កាត់តាមល័ក្ខខ័ណ្ឌដែលបានអនុម័តដូចឆ្នាំមុនដែរ ។

### ២.៤.២. ចំណូល និងចំណាយថវិកា

ស្ថានភាពហិរញ្ញវត្ថុថវិកាឆ្នាំ២០២២ របស់សង្កាត់ចាក់អង្រែក្រោមមានចំណូល និងចំណាយដូចតទៅះ

ថវិកាចរន្ត

ក. ចំណូលចរន្ត ៥១៥,០០០,០០០៛ ក្នុងនោះ

ប្រភេទទី១. ចំណូលសារពើពន្ធក្នុងស្រុក (គ្មាន)

ប្រភេទទី២. ចំណូលមិនមែនសារពើពន្ធ: ៥១៥,០០០,០០០៛ ក្នុងនោះ

❖ ផលទុនពីការលក់ ជួលទ្រព្យសម្បត្តិ និងសេវាៈ ៦,០០០,០០០៛ ក្នុងនោះ

- ចំណូលពីការអនុញ្ញាតរដ្ឋបាលទម្រង់ការរដ្ឋបាល និងការគ្រប់គ្រងរដ្ឋបាល ៦,០០០,០០០៛
- សេវាសុរិយោដី ០៛
- សេវាសំណង់ ០៛

❖ ការឧបត្ថម្ភអំណោយ ៥០៩,០០០,០០០៛ ក្នុងនោះ

យោងតាមលិខិត (ជូនដំណឹង) លេខៈ ៥៨៧៧ សហវ.អហក ចុះថ្ងៃទី២១ ខែ កក្កដា ឆ្នាំ ២០២១ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានជូនដំណឹងស្តីពីការកែសម្រួលវិភាជន៍ធនធានមូលនិធិជូនដល់ឃុំ សង្កាត់សម្រាប់ឆ្នាំ ២០២២ សង្កាត់ចាក់អង្រែក្រោមបានទទួលថវិកាសម្រាប់ចំណាយះ

- ឧបត្ថម្ភកធនពីក្រសួងស្ថាប័ន សម្រាប់ចំណាយរដ្ឋបាល ២៩២,០០០,០០០៛
- ការចូលរួមធនធានពីសមាសភាគអភិវឌ្ឍន៍មូលធន ៨,០០០,០០០៛
- អតិរេកនៃកាលបរិច្ឆេទ ០៛
- ឧបត្ថម្ភកធនពីថ្នាក់ជាតិ សម្រាប់ចំណាយវិនិយោគ ២០៩,០០០,០០០៛

❖ មូលនិធិបម្រុង ២៦១,៧៣០,០១៩៛

ខ. ចំណាយចរន្ត ៥១៥,០០០,០០០៛ ក្នុងនោះ

ប្រភេទទី១ មធ្យោបាយ និងសេវាសរុបចំនួន ៤៨០ ៩៣៧ ៦០០៛ ក្នុងនោះ

❖ សម្ភារៈផ្គត់ផ្គង់ថែទាំ ១២,៨៨៦,០០០៛

- សម្ភារៈផ្គត់ផ្គង់សម្អាត និងអនាម័យ ៦៤០,៥០០/ខែ : ៧,៦៨៦,០០០៛
- សម្ភារៈផ្គត់ផ្គង់សម្រាប់ថែទាំអគារប្រាសាទ និងសំណង់ផ្សេងៗ ០៛
- សម្ភារៈផ្គត់ផ្គង់សម្រាប់ថែទាំ ឧបករណ៍ ១០០,០០០/ខែ× ១២ : ១,២០០,០០០៛
- ប្រេងឥន្ធនៈ និងប្រេងរំអិល ៣៣៣,៣៣៣/ខែ × ១២ : ៤,០០០,០០០។[៥៣]

[៥៣] គម្រោងថវិកាឆ្នាំ២០២២ របស់សង្កាត់ចាក់អង្រែក្រោម ខណ្ឌមានជ័យ រាជធានីភ្នំពេញ

# ជំពូកទី ៣
# សមិទ្ធផល បញ្ហាប្រឈម
# និងដំណោះស្រាយ

# ជំពូកទី៣

# សមិទ្ធផល បញ្ហាប្រឈម និងដំណោះស្រាយ

## ៣.១. ស្ថានភាពបច្ចុប្បន្ន និងបញ្ហាប្រឈម

### ៣.១.១. ស្ថានភាពសេដ្ឋកិច្ច

គ្រួសារដែលមានមុខរបរសិប្បកម្មជាចម្បងសំដៅលើគ្រួសារដែលធ្វើការផលិតទ្វារ បង្អួច ឧបភោគ បរិភោគ និងសប្បកម្មផ្សេងៗ ស្មើនឹង០,២% គ្រួសារប្រកបមុខរបរសេវាកម្មជាចម្បងរួមមានមុខរបរធ្វើជំនួញជាងជួសជុល មុខរបរដឹកជញ្ជូន និងសេវាកម្មផ្សេងៗមានចំនួន ៧២,៩២% គ្រួសារប្រកបមុខរបរមិនច្បាស់លាស់(ចម្រុះ) ក្រៅពីមុខរបរចម្បងខាងលើ ចំនួន ១៨,៣២% ដែលជាសក្តានុពលយ៉ាងសំខាន់ក្នុងការទ្រទ្រង់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋក្នុងសង្កាត់ទាំងមូល។[៥៥]

ក្នុងរយៈពេល៥ឆ្នាំកន្លងមកក្រុមប្រឹក្សាសង្កាត់ អាណត្តិទី៣ បានខិតខំបំពេញភារកិច្ចដោយយកអស់លទ្ធភាពអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធក្នុងមូលដ្ឋាន និងទទួលបានលទ្ធផលគួរឲ្យមោទនៈភាពខ្ពស់។ ប៉ុន្តែក៏នៅមានចំណុចសេសសល់ខ្លះទៀតដែលក្រុមប្រឹក្សាសង្កាត់អាណត្តិទី៤ នេះត្រូវពុះពារអភិវឌ្ឍន៍ឲ្យទទួលបានលទ្ធផលខ្ពស់ជាបន្តទៀតដើម្បីបំពេញសេចក្តីត្រូវការ និងសំណូមពរចាំបាច់របស់ប្រជាជន។

#### ៣.១.១.១. ការខាងអាជីវកម្ម

មូលដ្ឋានសង្កាត់មានទីតាំងអាជីវកម្មដូចជាផ្ទះសំណាក់ភោជនីយដ្ឋាន និងកន្លែងលក់ដូរជាច្រើនទៀត។ បច្ចុប្បន្នទីតាំងនេះកំពុងតែដំណើរការប្រកបដោយភាពល្អប្រសើរដែលអាចផ្តល់កាងារដល់ប្រជាពលរដ្ឋក្នុងមូលដ្ឋាន និងក្រៅមូលដ្ឋានជាច្រើននាក់។ ទន្ទឹមនឹងនេះយើងក៏ជួបប្រទះនូវបញ្ហាមួយចំនួនដូចជាការបង្កសម្លេងរំខានការកកស្ទះចរាចរណ៍ បញ្ហាសណ្តាប់ធ្នាប់ ការចោលកាកសំណល់មិនបានត្រឹមត្រូវ ដែលទាមទារនូវការដោះស្រាយជាចាំបាច់។

#### ៣.១.១.២. ការខាងសាធារណៈ

ផ្លូវបេទីមីណ៉ារ ផ្លូវកៅស៊ូ ផ្លូវបេតុង បានផុសឡើងស្ទើរតែគ្រប់ផ្លូវនៅក្នុងមូលដ្ឋាន។ សមិទ្ធផលទាំងនេះកើតឡើងដោយសារការខិតខំប្រឹងប្រែងរបស់អាជ្ញាធរមូលដ្ឋាននាពេលកន្លងមក ដោយមានការឧបត្ថម្ភពីរាជរដ្ឋាភិបាលតាមរយៈគម្រោងមូលនិធិរបស់សាលារាជធានី សាលាខណ្ឌ និងសាលាសង្កាត់។ ម្យ៉ាងវិញទៀតភ្លើងបំភ្លឺផ្លូវទទួលទាន ២៤ម៉ោងលើ២៤ម៉ោង។ ទោះជាយ៉ាងណាក៏ដោយផ្លូវមួយចំនួនត្រូវខូចខាតដោយសារ

[៥៥] សៀវភៅផែនការអភិវឌ្ឍ៣ឆ្នាំរំកិល សង្កាត់ចាក់អង្រែក្រោម ២០២០-២០២២

ការមិនចូលរួមថែរក្សាពីប្រជាពលរដ្ឋ និងដោយសារជំនន់ទឹកភ្លៀងនាពេលកន្លងមកដែលទាមទារនូវការយកចិត្តទុកដាក់ថែរក្សា និងជួសជុលឡើងវិញជាចាំបាច់។

### ៣.១.២. ផ្នែកសង្គមកិច្ច

#### ៣.១.២.១. ការងារអប់រំ

វិស័យអប់រំ គឺជាគ្រឹះស្ថានសិក្សាដ៏ធំមួយក្នុងមូលដ្ឋានដែលផ្តល់ការអប់រំចាប់ពីថ្នាក់ឧត្តមរហូតដល់ថ្នាក់ក្រោយឧត្តម។ ក្រៅពីនេះមានសាលារៀនឯកជននៅក្នុងមូលដ្ឋានដែលផ្តល់ការអប់រំទាំងភាសាខ្មែរ និងភាសាបរទេសចាប់ពីថ្នាក់មតេយ្យដល់ថ្នាក់បឋម រួមទាំងសាលារដ្ឋ និងឯកជនដែលនៅសង្កាត់ក្បែរខាងបានផ្តល់ការអប់រំដល់ថ្នាក់វិទ្យាល័យ។ ចំណុចនេះបានបង្កលក្ខណៈងាយស្រួលដល់ប្រជាពលរដ្ឋក្នុងមូលដ្ឋានក្នុងការបញ្ជូនកូនទៅរៀនដោយមិនចំណាយថវិកា និងពេលវេលាច្រើន។ ប៉ុន្តែដោយសារបញ្ហាជីវភាពគ្រួសារមួយចំនួនមិនបានបញ្ជូនកូនទៅរៀនទេដោយបានបញ្ជូនកូនដែលធំ ដឹងក្តីបន្តិចទៅប្រកបរបរផ្សេងៗ ដើម្បីរកចំណូលសម្រាប់គ្រួសារ។ បញ្ហានេះគឺជាអ្វីដែលអាជ្ញាធរយើងត្រូវយកចិត្តទុកដាក់ជាចាំបាច់។[៥៥]

#### ៣.១.២.២. សុខាភិបាល

ក្នុងមូលដ្ឋានសង្កាត់ចាក់អង្រែក្រោមមានមណ្ឌលសុខភាពមួយកន្លែងស្ថិតក្នុងភូមិព្រែកតាឡុង៣ ដែលផ្តល់សេវាសុខភាពជូនប្រជាពលរដ្ឋក្នុងតម្លៃទាប។ មួយវិញទៀតនៅក្នុងមូលដ្ឋានសង្កាត់ក៏ដូចជានៅសង្កាត់ក្បែរខាងមានឱសថស្ថាន មន្ទីរព្យាបាលជម្ងឺ និងមន្ទីរពេទ្យជាច្រើនកន្លែងដែលអាចផ្តល់សេវាសុខភាពជូនប្រជាពលរដ្ឋបានទាន់ពេលវេលា។ ទោះជាយ៉ាងណាប្រជាពលរដ្ឋមួយចំនួនតូចជាពិសេសប្រជាពលរដ្ឋក្រីក្រត្រូវជួបប្រទះនូវបញ្ហាខ្លះក្នុងការស្វែងរកសេវាសុភាពដោយសារគ្លីនិក មន្ទីរព្យាបាលមួយចំនួនមានតម្លៃថ្លៃ។

#### ៣.១.២.៣. វប្បធម៌និងសាសនា

ប្រជាពលរដ្ឋកម្ពុជាភាគច្រើនជាអ្នកកាន់ពុទ្ធសាសនា។ រាល់ពេលមានពិធីបុណ្យពុទ្ធសាសនាម្តងៗ ដូចជាពិធីបុណ្យចូលវស្សាចេញវស្សា បុណ្យកាន់បិណ្ឌ ភ្ជុំបិណ្ឌ ចូលឆ្នាំថ្មីប្រពៃណីខ្មែរ កឋិនទាន។ល។ ប្រជាពលរដ្ឋរួមទាំងអាជ្ញាធរ តែងតែចូលរួមមិនដែលអាក់ខានឡើយ។ រាល់ពេលមានពិធីបុណ្យនៅតាមទីវត្តអារាមនានាយើងសង្កេតឃើញប្រជាពលរដ្ឋភាគច្រើនស្លៀកសម្លៀកបំពាក់ប្រពៃណី។ ដោយសារសម័យនេះជាសម័យបច្ចេកវិទ្យាខ្ពស់ធ្វើឲ្យវប្បធម៌បរទេសបានចូលមកលុកលុយយ៉ាងខ្លាំងក្លាក្នុងស្រទាប់យុវវ័យរបស់ខ្មែរយើង ។ យុវវ័យមួយចំនួនស្លៀកពាក់មិនសមរម្យក្នុងការដើរហើយក៏ដូចជាការចូលរួមក្នុងពិធីផ្សេងៗ និងបាន

---

[៥៥] សៀវភៅផែនការអភិវឌ្ឍ៣ឆ្នាំរំកិល សង្កាត់ចាក់អង្រែក្រោម ២០២០-២០២២

ចូលយ៉ាងងប់ងល់ទៅនឹងពិធីមួយចំនួនដែលមានឥទ្ធិពលពីវប្បធម៌បរទេស។ នេះហើយជាអ្វីដែលយើងត្រូវយកចិត្តទុដាក់។

**៣.១.២.៤. យេនឌ័រ**

បច្ចុប្បន្នយើងសង្កេតឃើញស្ត្រីមានតួនាទីក្នុងស្ថាប័នជាច្រើនទាំងក្នុងវិស័យសាធារណៈ និងវិស័យឯកជនដែលសឲ្យឃើញពីការចូលរួមយ៉ាងសកម្មរបស់ស្ត្រីក្នុងការងារសង្គម។ ជាក់ស្តែងក្នុងសង្គមគ្រួសារក៏ដូចគ្នាដែរស្ត្រីមួយចំនួនបានក្លាយជាបង្គោលយ៉ាងសំខាន់ដែលមានតួនាទីទទួលខុសត្រូវនូវកិច្ចការគ្រប់បែបយ៉ាងនៅក្នុងសង្គមគ្រួសារ។ ទោះជាយ៉ាងនេះក្តីនៅមានគ្រួសារមួយចំនួនតូចបានចាត់ទុកស្ត្រីគ្រាន់តែជាមនុស្សម្នាក់ដែលអាចធ្វើបានតែកិច្ចការផ្ទះហើយគ្រួសារមួយចំនួនទៀតបានកើតមាននូវអំពើហិង្សាក្នុងគ្រួសាររបស់ខ្លួនដោយសារការឈ្លោះទាស់ទែងគ្នាដែលកើតឡើងដោយសារការរស់នៅមិនចុះសម្រុងនឹងគ្នា ឬអាចមកពីការទទួលរងនូវឥទ្ធិពលនៃគ្រឿងស្រវឹង។

**៣.១.៣. ផ្នែកធនធានធម្មជាតិនិងបរិស្ថាននិងការបន្សាំនឹងការប្រែប្រួលអាកាសធាតុ**

**៣.១.៣.១. ការគ្រប់គ្រងដីធ្លី**

មានច្បាប់ភូមិបាលអនុក្រឹត្យលេខ៨៦ ស្តីពីលិខិតអនុញ្ញាតសាងសង់សារាចរលេខ០៣ ស្តីពីការដោះស្រាយសំណង់បណ្តោះអាសន្នលើដីរបស់រដ្ឋដែលត្រូវបានទន្ទ្រានកាន់កាប់ដោយខុសច្បាប់តាមរាជធានីទីក្រុង និងទីប្រជុំជន សេចក្តីណែនាំសេចក្តីណែនាំលិខិតបទដ្ឋានការចុះបញ្ជីដីធ្លីលក្ខណៈជាប្រព័ន្ធជាច្រើនសម្រាប់ធ្វើជាមូលដ្ឋានក្នុងការគ្រប់គ្រងដីធ្លី។ ប៉ុន្តែនៅតែមានការរំលោភដីសាធារណៈទំនាស់ព្រំប្រទល់សំណង់មិនរៀបរយការសាងសង់មិនគោរពនគរូបនីយកម្មបញ្ញត្តិ។ កត្តាទាំងនេះកើតឡើងដោយសារមិនយល់ច្បាប់ភូមិបាលមានចិត្តលោភលន់ប្រជាពលរដ្ឋមួយចំនួនមិនទាន់មានប័ណ្ណកម្មសិទ្ធិតំបន់មិនទាន់អភិវឌ្ឍន៍ប្រជាបលរដ្ឋរស់នៅលើចិញ្ចើមផ្លូវ។

**៣.១.៣.២. ការខារលូទឹក**

នៅក្នុងសង្កាត់ចាក់អង្រែក្រោមបណ្តាញលូទាំងនេះកើតឡើងដោយសារថវិការបស់សសរាជធានីភ្នំពេញថវិកា ខណ្ឌ សប្បុរសជន ថវិកាវិភាជរដ្ឋបាលតាមរយៈក្រសួងសេដ្ឋកិច្ចហិរញ្ញវត្ថុដែលបានផ្តល់សម្រាប់គម្រោងកម្មវិធីគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គជអប) និងមានទុនចូលរួមពីប្រជាពលរដ្ឋផងដែរ។ ផ្អែកតាមលក្ខណៈភូមិសាស្ត្រសង្កាត់ចាក់អង្រែក្រោមតំបន់ខ្លះមានលក្ខណៈជាបាត បណ្តាលឲ្យផ្លូវលំនៅដ្ឋានមួយចំនួនលិចទឹកនៅរដូវវស្សាគួបផ្សំនិងកត្តាមួយចំនួនដូចជាប្រព័ន្ធលូតូច ចាស់ពុកផុយ លូនៅជ្រៅជាងប្រភពទឹក ការចោលសំរាមក្នុងអណ្តូងលូបិតទមុខលូ ប្រឡាយមាន

សភាពគោករាក់ ការចាក់លុបបឹងប្រឡាយ និងមិនទាន់ប្រព័ន្ធលូនៅឡើយ ដែលទាមទាការជួសជុលស្តារឡើងវិញ និងរៀបចំប្រព័ន្ធលូ ប្រឡាយថ្មីបន្ថែមទៀត។

**៣.១.៣.៣. ការងារបរិស្ថាន**

សង្កាត់ចាក់អង្រែក្រោមបានទទួលសេវាសំរាមពីក្រុមហ៊ុនស៊ីនទ្រីសម្រាប់ធ្វើការប្រមូលសំរាមជារៀងរាល់ថ្ងៃ ដែលធានាការពារបាននូវគុណភាព ទឹក ដូច ខ្យល់ និងការគញ្ចប់គ្រងសំណល់ រឹងរាវ ត្រឹមត្រូវដែលធ្វើឲ្យបរិស្ថានរស់នៅបាន។

**៣.១.៤. ផ្នែករដ្ឋបាល និងសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ**

**៣.១.៤.១. ផ្នែករដ្ឋបាល**

ជារៀងរាល់ថ្ងៃយើងតែងតែស្រង់ទិន្នន័យ ភូមិសង្កាត់ដើម្បីវិភាគពីស្ថានភាពរបស់មូលដ្ឋាន។ ជាក់ស្តែងទិន្នន័យមួយចំនួនដែលទទួលបានហាក់ដូចជាមានភាពមិនច្បាស់លាស់ដែលតម្រូវឲ្យយើងត្រូវអនុវត្តន៍បន្តទៀត។ ម្យ៉ាងវិញទៀតសមត្ថភាពថ្នាក់ដឹកនាំភូមិមួយ និងក្រុមប្រឹក្សាសង្កាត់មួយចំនួននៅមានកម្រិតនៅឡើយ ដែលតម្រូវឲ្យយកចិត្តទុកដាក់រៀនសូត្របន្ថែមទៀតដើម្បីអាចមានសមត្ថភាពគ្រប់គ្រាន់ដើម្បីបម្រើប្រជាពលរដ្ឋឲ្យមានប្រសិទ្ធភាព។

**៣.១.៤.២. ការងារសន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ**

បញ្ហាសន្តិសុខក្នុងមូលដ្ឋានជារឿងចាំបាច់ដែលទាក់ទនឹងសុវត្ថិភាពក្នុងការរស់នៅរបស់ប្រជាពលរដ្ឋក្នុងមូលដ្ឋាន។ អាជ្ញាធរសង្កាត់បានសហការជាមួយកម្លាំងនគរបាលនគបាលប៉ុស្តិ៍ ចុះល្បាតតាមគោលដៅសំខាន់ៗទៀតជារៀងរាល់ថ្ងៃ។ ជារៀងរាល់ខែយើងតែងតែរៀបចំវេទិកាសាធារណៈជាមួយប្រពលរដ្ឋក្នុងមូលដ្ឋានដើម្បីដោះស្រាយនូវសំណូមពរនានាជូនប្រជាពលរដ្ឋ ទាក់ទងនឹងភូមិ សង្កាត់មានសុវត្ថិភាព។ ទោះយ៉ាងណាក៏ដោយបញ្ហាសន្តិសុខសុវត្ថិភាពក្នុងមូលដ្ឋានក៏នៅមិនទាន់បានល្អប្រសើរមួយរយភាគរយនៅឡើយដែរអាជ្ញាធរត្រូវយកចិត្តទុកដាក់ជម្រុញបន្ថែមទៀត។

បញ្ហាមួយទៀតគឺ សណ្តាប់ធ្នាប់សាធារណៈ ការលក់ដូរ ការចតយានជំនិះលើចិញ្ចើមផ្លូវបានធ្វើឲ្យគ្មានផ្លូវធ្វើដំណើរសម្រាប់ថ្មើជើង និងធ្វើឲ្យកកស្ទះចរាចរស្ទើររាល់ថ្ងៃ។ បច្ចុប្បន្នរដ្ឋបាលរាជធានីភ្នំពេញ រដ្ឋបាលខណ្ឌមានជ័យក៏ដូចជារដ្ឋបាលសង្កាត់កំពុងយកចិត្តទុកដាក់ខ្លាំងបំផុតក្នុងការរំដោះចិញ្ចើមផ្លូវដើម្បីកាត់បន្ថយការកកស្ទះចរាចរ និងជៀសវាងការកើតមានគ្រោះថ្នាក់ជាយថាហេតុដល់អ្នកថ្មើជើង។[៥៦]

[៥៦] សៀវភៅផែនការអភិវឌ្ឍ៣ឆ្នាំរំកិល សង្កាត់ចាក់អង្រែក្រោម ២០២០-២០២២

## ៣.២. ដំណោះស្រាយ

### ៣.២.១. ហេដ្ឋារចនាសម្ព័ន្ធ

ដោយមើលឃើញពីបញ្ហាប្រឈមទាក់ទងទៅនឹងហេដ្ឋារចនាសម្ព័ន្ធដោយតាមបណ្តាផ្លូវមួយចំនួនពុំទាន់បានដាក់លូ ហើយបណ្តាផ្លូវខ្លះទៀតដាក់លូមិនត្រូវតាមបច្ចេកទេស(ទំហំតូច) ដែលធ្វើឲ្យមានការស្ទះលូទើបនៅពេលមានភ្លៀងធ្លាក់ធ្វើឲ្យមានការស្ទះនិងបង្កឲ្យមានការលិចផ្លូវដែលបណ្តាលឲ្យការខូចខាតផ្លូវជាបន្តបន្ទាប់បណ្តាលឲ្យផ្លូវខូចដែលធ្វើឲ្យប៉ះពាល់យ៉ាងខ្លាំងដល់ការធ្វើដំណើររបស់ប្រជាពលរដ្ឋដែលរស់នៅក្នុងតំបន់នោះ។ ហេតុដូចនេះហើយទើបខាងសង្កាត់ចាក់អង្រែក្រោមបានធ្វើការដោះស្រាយនូវបញ្ហានេះជូនប្រជាពលរដ្ឋដោយត្រួតពិនិត្យ និងស្តារប្រព័ន្ធលូឲ្យត្រូវទៅតាមបច្ចេកទេសហើយធ្វើការដាក់លូបន្ថែមនៅផ្លូវដែលមិនទាន់បានដាក់ប្រព័ន្ធលូ។ ម្យ៉ាងវិញទៀតចំពោះផ្លូវដែលខូចខាតត្រូវបានជួសជុលនិងចាក់បេតុងដើម្បីផ្តល់នូវភាពងាយស្រួលជូនដល់ប្រជាពលរដ្ឋ។

ចំពោះបញ្ហាទាក់ទងទៅនិងផ្លូវខូចខាតដោយសារការមិនចូលរួមថែពីសំណាក់ប្រជាពលរដ្ឋក៏ដូចជាបង្កមកពីបញ្ហាអាកាសធាតុផងនោះខាងសង្កាត់មានវិធានការចុះជួសជុលផ្លូវណាដែលបានខូចខាតឲ្យមានសភាពល្អប្រសើរឡើងវិញផ្តល់ភាពងាយស្រួលជូនដល់ប្រជាពលរដ្ឋក្នុងការធ្វើដំណាហើយចំពោះប្រព័ន្ធអគ្គិសនីវិញកន្លែងដែលខ្វះខាតប្រព័ន្ធអគ្គិសនីខាងសង្កាត់ក៏មានវិធានការក្នុងការចុះតម្លើងបង្គោលភ្លើងនឹងមានការតភ្ជាប់នៅប្រព័ន្ធភ្លើងជូនដល់ប្រជាពលរដ្ឋប្រើប្រាស់កាន់តែប្រសើរជាងមុន។

### ៣.២.២. ការលើកកម្ពស់គុណភាពវិស័យអប់រំ

ដើម្បីជម្រុញឲ្យការអប់រំនៅក្នុងសង្កាត់ចាក់អង្រែក្រោមឲ្យកាន់តែមានប្រសិទ្ធភាពនោះខាងអាជ្ញាធរធ្វើការចុះណែនាំដល់ប្រជាពលរដ្ឋឲ្យមានការយល់ដឹងកាន់តែច្រើនទាក់ទងនិងការបណ្តុះបណ្តាល និងប្រព័ន្ធអប់រំព្រមទាំងលើកទឹកចិត្តឲ្យប្រជាពលរដ្ឋមានចិត្តចង់ឲ្យកូនមានចំណេះដឹងផងដែរ ដោយមានផ្តល់នៅអាហារូបករណ៍ដល់សិស្សក្រីក្រថែមទៀតផង។

### ៣.២.៣. ការរក្សាសន្តិសុខ និងសណ្តាប់ធ្នាប់

ដើម្បីឲ្យសង្កាត់ចាក់អង្រែក្រោមកាន់តែមានភាពស្រស់ស្អាតនឹងកាន់តែមានសណ្តាប់ធ្នាប់ល្អជាងនេះទៀតនោះខាងអាជ្ញាធរបានយកចិត្តទុកដាក់ធ្វើការចុះណែនាំដល់ប្រជាពលរដ្ឋដែលធ្វើការចតលក់ដូរគ្មានសណ្តាប់ធ្នាប់ឲ្យបានយល់ដឹងពីផលវិបាកនៃការចតបែបអាណាធិបតេយ្យថាមានការប៉ះពាល់អ្វីខ្លះ ក៏ដូចជាចាត់ប្រជាការពារចុះទៅត្រួតពិនិត្យរៀបចំសណ្តាប់ធ្នាប់ឲ្យមានរបៀបរៀបរយ។ ហើយចំពោះការទុកដាក់សម្រាមវិញ ខាងសង្កាត់បានមានវិធានការចាត់ឲ្យខាងឡានដឹកសម្រាមមានការយកចិត្តទុកដាក់មកប្រមូលយកសម្រាមឲ្យបានឆាប់

របស់ និងទាន់ពេលវេលាព្រមទាំងមានការចុះណែនាំអំពីការទុកដាក់សម្រាមឲ្យបានត្រឹមត្រូវ និងចាត់ប្រជាការពារឲ្យមកត្រួតពិនិត្យរបៀបរៀបរយសណ្តាប់ធ្នាប់ថែមទៀតផង។

ចំពោះផ្នែកសន្តិសុខវិញខាងសង្កាត់ចាក់អង្រែក្រោមបានចាត់វិធានការ និងគោលនយោបាយគឺធ្វើយ៉ាងណាឲ្យសង្កាត់ចាក់អង្រែក្រោម ភូមិចំណុះក្លាយជាមូលដ្ឋានមានលក្ខណៈសម្បត្តិដូចជា គ្មានការលួច ប្លន់ គាស់ផ្ទះរបស់ប្រជាពលរដ្ឋដោយសម្តកិច្ចសហការចុះល្បាតជាប្រចាំ និងដាក់អំពូលភ្លើងដើម្បីបំភ្លឺផ្លូវ។ មិនឲ្យមានការផលិត ការចែកចាយ និងប្រើប្រាស់គ្រឿងញៀន គ្មានអំពើអនាចារ ការជួញដូរស្ត្រី និងកុមារ គ្មានក្មេងទំនើងគ្មានការលេងល្បែងស៊ីសងខុសច្បាប់ការប្រើប្រាស់អាវុធខុសច្បាប់គ្រប់ប្រភេទគ្មានគ្រោះថ្នាក់ចរាចរណ៍គ្មានគ្រោះថ្នាក់ដោយសារយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះមានវិធានការទប់ស្កាត់ គ្រប់គ្រង និងឆ្លើយតបចំពោះគ្រោះមហន្តរាយប្រកបដោយប្រសិទ្ធភាពព្រមទាំងលុបបំបាត់ការប្រើប្រាស់អំពើហឹង្សាក្នុងគ្រួសារដោយធ្វើការផ្សព្វផ្សាយច្បាប់ប្រឆាំងអំពើហឹង្សាក្នុងគ្រួសារអប់រំពីផលវិបាកនៃការប្រើប្រាស់គ្រឿងញៀន និងគ្រឿងស្រវឹង។[៥៧]

## ៣.៣. ទិសដៅអនាគត

### ៣.៣.១. ការអភិវឌ្ឍផ្នែកហេដ្ឋារចនាសម្ព័ន្ធ

បន្ទាប់ពីការអនុវត្តការងារផ្នែកហេដ្ឋារចនាសម្ព័ន្ធក្នុងគម្រោងវិនិយោគបីឆ្នាំរំកិល ឆ្នាំ២០២០ ដល់ ២០២២ រួចមកសង្កាត់ចាក់អង្រែក្រោមមានទិសដៅការងារជាអទិភាពសម្រាប់ឆ្នាំ២០២៣ដូចខាងក្រោម៖

- បន្តរៀបចំសណ្តាប់ធ្នាប់តាមទីសាធារណៈ និងផ្លូវសំខាន់ៗឲ្យបានល្អ
- ចុះពិនិត្យលើការដ្ឋានសំណង់ទប់ស្កាត់សំណង់ណាដែលគ្មានច្បាប់អនុញ្ញាត និងសំណង់ខុសប្លង់
- ចុះជម្រុញមូលដ្ឋានសិប្បកម្មផលិតស្បៀងអាហារ ភេសជ្ជៈ អំពីគុណភាពផលិត
- ពិនិត្យនិងយកចិត្តទុកដាក់ទៅលើការកសាងផ្លូវថ្មល់ដោះស្រាយនៅបញ្ហាផ្លូវខូចខាត

### ៣.៣.២. ពង្រឹងផ្នែកសណ្តាប់ធ្នាប់សាធារណៈ

បន្ទាប់ពីការអនុវត្តការងារផ្នែកសណ្តាប់ធ្នាប់សាធារណៈឆ្នាំមុនៗរួចមកសង្កាត់ចាក់អង្រែក្រោមមានទិសដៅជាអាទិភាពសម្រាប់ឆ្នាំបន្ទាប់ដូចខាងក្រោម៖

- បន្តកាត់បន្ថយជនអនាថាតាមចិញ្ចើមផ្លូវ និងទីសាធារណៈ
- បន្តការអប់រំ និងផាកពិន័យអ្នកបោះចោលសម្រាមគ្មានសណ្តាប់ធ្នាប់
- ពង្រឹងការគ្រប់គ្រងអាជីវកម្មមណ្ឌលកំសាន្តមនុស្សពេញវ័យ
- បន្តផ្សព្វផ្សាយដល់ប្រជាពលរដ្ឋស្តីអំពីសីលធម៌ តម្លៃស្ត្រី និងគ្រួសារខ្មែរ

[៥៧] សៀវភៅផែនការអភិវឌ្ឍ៣ឆ្នាំរំកិល សង្កាត់ចាក់អង្រែក្រោម ២០២០-២០២២

- ជម្រុញការងារសហការជាមួយក្រុមហ៊ុនប្រមូលសម្រាម ក្នុងការប្រមូលសម្រាមឲ្យបានស្អាត និងទៀងទាត់ពេលវេលា
- បន្តជម្រុញ និងណែនាំម្ចាស់សណ្ឋាគារ ផ្ទះសំណាក់ ឲ្យកត់ត្រាអត្តសញ្ញាណភ្ញៀវស្នាក់នៅប្រចាំថ្ងៃ សំដៅពង្រឹងការគ្រប់គ្រងស្ថិតិភ្ញៀវឲ្យបានច្បាស់លាស់ និងការពារសន្តិសុខ សុវត្ថិភាពភ្ញៀវ ឲ្យបានល្អ
- សហការជាមួយនិងមន្ទីរការងារជម្រុញដល់សហគ្រាសធនតូច មធ្យមឲ្យលើកល័ក្ខខណ្ឌការងារ និងសន្តិសុខ សុវត្ថិភាបការងាររបស់កម្មករនិយោជិត តាមសហគ្រាស និងគ្រឹះស្ថាន
- សហការជាមួយនិងមន្ទីរបរិស្ថានរាជធានីភ្នំពេញ ត្រួតពិនិត្យការបំពុលបរិស្ថាន
- ធ្វើយ៉ាងណាកាត់បន្ថយដល់ការលក់ដូរតាមដងផ្លូវ។

**៣.៣.៣. យន្តការសេវាសាធារណៈ**

សង្កាត់ចាក់អង្រែក្រោមបង្កើនការបម្រើសេវាសាធារណៈជូនដល់ប្រជាពលរដ្ឋឲ្យកាន់តែឆាប់រហ័ស និងយកចិត្តទុកដាក់បង្កើតទំនាក់ទំនងឲ្យកាន់តែជិតស្និតជាមួយនិងប្រជាពលរដ្ឋ។

# សេចក្ដីសន្និដ្ឋាន

# សេចក្តីសន្និដ្ឋាន

ការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់គឺត្រូវបង្កើតឡើងនៅតាមបណ្តាឃុំ សង្កាត់ទាំងអស់នៃព្រះរាជាណាចក្រកម្ពុជាដើម្បីធ្វើការគ្រប់គ្រងក៏ដូចជាអភិវឌ្ឍឃុំ សង្កាត់ឲ្យមានការីកចម្រើន និងបម្រើប្រជាពលរដ្ឋឲ្យកាន់តែប្រសើរឡើងប្រកបទៅដោយប្រសិទ្ធភាព គុណភាព និងតម្លាភាព។ ក្នុងដំណើរការនៃការគ្រងគ្រងរដ្ឋបាលឃុំ សង្កាត់ ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវបានជ្រើសរើសឡើងតាមរយៈការបោះឆ្នោតជាសកលពីប្រជាពលរដ្ឋដែលមានអាណត្តិ ៥ឆ្នាំ និងមានមេឃុំ ឬចៅសង្កាត់ជាប្រធាននៃក្រុមប្រឹក្សា។

ជាក់ស្តែងសង្កាត់ចាក់អង្រែក្រោមដែលកំពុងដឹកនាំដោយ លោក ជា សុខែ ជាចៅសង្កាត់ និងក្រុមប្រឹក្សា បុគ្គលិកបានបំពេញតួនាទីយ៉ាងល្អក្នុងការបម្រើសេវាជូនប្រជាពលរដ្ឋតាមតម្រូវការបានយ៉ាងល្អប្រសើរ និងឆាប់រហ័សដែលជំរុញឲ្យប្រជាពលរដ្ឋរស់នៅទីនោះមានភាពកក់ក្តៅ និងមានការរស់នៅប្រកបដោយសន្តិសុខសណ្តាប់ធ្នាប់សង្គមសាធារណៈគ្មានអំពើចោរកម្ម ក៏ដូចជាក្មេងទំនើងកើតមានបានឡើយ។ ក្នុងការអនុវត្តនេះដែរ ក្រុមប្រឹក្សាឃុំ សង្កាត់ មានអំណាច២ ក្នុងការគ្រប់គ្រងគឺ អំណាចនីតិបញ្ញត្តិផង និង អំណាចនីតិប្រតិបត្តិ ដែលអំណាចនីតិបញ្ញត្តិ ក្រុមប្រឹក្សា ចេញដីកា លិខិតបទដ្ឋានផ្សេងដែលមានការចុះហត្ថលេខាដោយមេឃុំ ចៅសង្កាត់។ រីឯអំណាចនីតិប្រតិបត្តិ គឺសំដៅលើការប្រតិបត្តិរបស់មេឃុំ ចៅសង្កាត់ចំពោះបទប្បញ្ញត្តិរាជរដ្ឋាភិបាលដីការដ្ឋបាលខេត្ត ដីការដ្ឋបាលស្រុក និងដីកាដែលក្រុមប្រឹក្សាបានដាក់ចេញ។

សរុបសេចក្តីមក ការគ្រប់គ្រងរដ្ឋបាលសង្កាត់ចាក់អង្រែក្រោមពិតជាបានគោរព និងប្រតិបត្តិតាមបទប្បញ្ញត្តិពីរាជរដ្ឋាភិបាលដែលញាំងឲ្យការគ្រប់គ្រងទទួលបានលទ្ធផលល្អគួរជាទីគាប់ចិត្តរបស់ប្រជាពលរដ្ឋប្រកបទៅដោយភាពសុខដុមរមនា និងមានអភិបាលកិច្ចល្អ។

# អនុសាសន៍

# អនុសាសន៍

ឆ្លងតាមការសិក្សាស្រាវជ្រាវ និងចងក្រងនូវឯកសារទាំងអស់នេះរួចមកយើងខ្ញុំទាំងពីរយល់ឃើញថារាល់ការគ្រប់គ្រងដឹកនាំរដ្ឋបាលទាំងអស់នេះគឺមានភាពល្អប្រសើដោយហេតុថាសមិទ្ធផលដែលទទួលបានពីការអនុវត្តការងារនេះបានច្រើនគួរឲ្យកត់សម្គាល់ និងមានការអភិវឌ្ឍស្ទើរតែពេញសង្កាត់ទាំងមូល។ ឯកសារនេះអាចមានសារៈសំខាន់យ៉ាងខ្លាំងដល់ការសិក្សាសម្រាប់សិស្សនិស្សិតគ្រប់រូបផងដែរ។ ដោយហេតុនេះហើយទើបយើងខ្ញុំទាំងពីរសូមចូលរួមជាមួយអាជ្ញាធរ សង្កាត់ចាក់អង្រែក្រោម ក្នុងការគ្រប់គ្រងរដ្ឋបាលដែនដីជាពិសេសពង្រឹង លើការអនុវត្តនូវគោលនយោបាយវិមជ្ឈការ នូវអនុសាសន៍មួយចំនួនដូចខាងក្រោមៈ

- អាជ្ញាធរសង្កាត់គួរតែបង្កើតឲ្យមានវេទិកាសាធារណៈឲ្យបានញឹកញាប់ជាមួយប្រជាពលរដ្ឋដើម្បីបង្កើនភាពស្និតស្នាលរវាងអាជ្ញាធរ និងប្រជាពលរដ្ឋដែលអាចឲ្យប្រជាពលរដ្ឋទទួលបានព័ត៌មានច្បាស់លាស់អំពីដំណើរនៃការអភិវឌ្ឍសង្កាត់របស់ខ្លួន។ ម្យ៉ាងវិញទៀតប្រជាពលរដ្ឋក៏អាចបញ្ចេញមតិយោបល់ និងជម្រាបពីបញ្ហាដែលខ្លួនកំពុងជួបប្រទះដើម្បីឲ្យអាជ្ញាធរដោះស្រាយបានទាន់ពេលវេលា។
- អាជ្ញាធរសង្កាត់គួរតែជម្រុញនិងបណ្តុះនូវផ្នត់គំនិតរបស់ប្រជាពលរដ្ឋមួយចំនួនតូចឲ្យមានការយល់ដឹងពីរបៀបទុកដាក់សំរាមឲ្យបានត្រឹមត្រូវជៀសវាងការចោលសំរាមផ្តេសផ្តាសដែលបង្កឲ្យមានការបំពុលបរិស្ថានបាត់បង់សោភ័ណភាព និងជាពិសេសបណ្តាលឲ្យមានការស្ទះលូនៅពេលមានភ្លៀងធ្លាក់។
- សូមអាជ្ញាធរសង្កាត់ គួរតែបង្កើនការយកចិត្តទុកដាក់ឲ្យបានខ្ពស់ក្នុងការជួយសម្រួលការកកស្ទះចរាចរណ៍នៅតាមដងផ្លូវដែលមានផ្សារ សាលារៀន និងរោងចក្រជាដើម ជាពិសេសនៅពេលប្រជាពលរដ្ឋធ្វើដំណើរទៅធ្វើការ និងត្រឡប់មកពីធ្វើការវិញ។ ម្យ៉ាងវិញទៀត ការសម្រួលចរាចរណ៍ក៏អាចជួយកាត់បន្ថយនូវការកើតមានឡើងនូវបញ្ហាគ្រោះថ្នាក់ចរាចរណ៍បានផងដែរ

# ឯកសារយោង

# ឯកសារយោង

## ១. ច្បាប់ លិខិតបទដ្ឋានគតិយុត្ត

1. ច្បាប់ស្តីពីវិសោធនកម្ម ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានីខេត្ត ក្រុង ស្រុក ខណ្ឌ ២០១៩
2. ច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់
3. ច្បាប់ស្តីពីលទ្ធកម្មសាធារណៈ
4. ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ឆ្នាំ ២០០១
5. ច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់
6. សេចក្តីណែនាំ ស្តីពីការកសាងផែនការអភិវឌ្ឍឃុំ សង្កាត់ និងកម្មវិធីវិនិយោគបីឆ្នាំរំកិល
7. ការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ តាមបែបវិមជ្ឈការ ខែកក្កដា ឆ្នាំ២០១៧
8. គោលនយោបាយស្តីពី ការគ្រប់គ្រង និងការអភិវឌ្ឍធនធានមនុស្សនៅរដ្ឋបាលថ្នាក់ក្រោមជាតិ
9. គោលនយោបាយស្តីពី ការផ្តល់សេវាសាធារណៈ
10. អនុក្រឹត្យស្តីពីប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុឃុំ សង្កាត់
11. អនុក្រឹត្យលេខ ស្តីពីការផ្ទេរធនធានពីថវិការដ្ឋជូនមូលនិធិឃុំ សង្កាត់
12. សេចក្តីណែនាំបច្ចេកទេស ស្តីពីការរៀបចំ និងកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ
13. សេចក្តីណែនាំស្តីពីបែបបទនីតិវិធីនៃការជ្រើសរើសមេភូមិការចូលកាន់តំណែង ការផ្លាស់ប្តូរមេភូមិ ការតែងតាំងជំនួយការមេភូមិ និងរបៀបរបបធ្វើការងាររបស់ភូមិ
14. កម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
15. រាជរដ្ឋាភិបាលកម្ពុជាក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល កម្រងព័ត៌មានសេវាសាធារណៈ

## ២. សៀវភៅតែងនិពន្ធ

1. ប្រព័ន្ធគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិនៅកម្ពុជា កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ
2. នីតិរដ្ឋបាលទូទៅ  រៀបរៀងដោយ អនុបណ្ឌិត ហៀង សាង ឆ្នាំ ២០១៧
3. ក្រសួងមហាផ្ទៃ ការគ្រប់គ្រងរដ្ឋបាល ឃុំ សង្កាត់ ឆ្នាំ ២០២២
4. សៀវភៅការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់តាមបែបវិមជ្ឈការ របស់ក្រសួងមហាផ្ទៃ ឆ្នាំ២០១៧

## ៣. ឯកសារផ្សេងៗ

1. កម្មវិធីវិនិយោគបីឆ្នាំរំកិល ឆ្នាំ២០២០ ដល់ឆ្នាំ២០២២ របស់សង្កាត់ចាក់អង្រែក្រោម
2. គម្រោងថវិកាឆ្នាំ២០២២ របស់សង្កាត់ចាក់អង្រែក្រោម ខណ្ឌមានជ័យ រាជធានីភ្នំពេញ
3. បទសម្ភាសន៍ផ្ទាល់ជាមួយសមាជិកក្រុមប្រឹក្សាសង្កាត់ចាក់អង្រែក្រោម

# ឧបសម្ព័ន្ធ

# បញ្ជីឧបសម្ព័ន្ធ

## ១. ឧបសម្ព័ន្ធគតិយុត្ត

ឧបសម្ព័ន្ធទី១៖ ព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ប្រកាសឲ្យប្រើច្បាប់ស្តីពី ការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់

ឧបសម្ព័ន្ធទី២៖ ប្រកាសស្តីពីការទទួលស្គាល់សមាសភាពក្រុមប្រឹក្សានៃសង្កាត់ចាក់អង្រែក្រោម

## ២. ឧបសម្ព័ន្ធរូបភាព

ឧបសម្ព័ន្ធទី១៖ ផែនទីសង្កាត់ចាក់អង្រែក្រោម

ឧបសម្ព័ន្ធទី២៖ កម្រងសំណួរការជួបសម្ភាសន៍ជាមួយសមាជិកក្រុមប្រឹក្សា សង្កាត់ចាក់អង្រែក្រោម

ឧបសម្ព័ន្ធទី៣៖ កម្រងរូបភាពជាមួយលោកចៅសង្កាត់ និងសមាជិកក្រុមប្រឹក្សាសង្កាត់ចាក់អង្រែក្រោម

# ឧបសម្ព័ន្ធទី១៖

# ព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី ១៩ ខែមីនា ឆ្នាំ២០០១ ប្រកាសឲ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់

# ឧបសម្ព័ន្ធទី២៖
# ប្រកាសស្តីពីការទទួលស្គាល់
# សមាសភាពក្រុមប្រឹក្សានៃសង្កាត់
# ចាក់អង្រែក្រោម

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
ក្រសួងមហាផ្ទៃ
លេខ: ៣៤២៥ ប្រក

# ប្រកាស

## ស្តីពីការទទួលស្គាល់សមាសភាពប្រធានក្រុមប្រឹក្សាសង្កាត់ ចៅសង្កាត់ ចៅសង្កាត់រង និងសមាជិកក្រុមប្រឹក្សាសង្កាត់ នៃសង្កាត់ចាក់អង្រែក្រោម ខណ្ឌមានជ័យ រាជធានីភ្នំពេញ

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៥/០១៥ ចុះថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១៥ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០១៧/០១២ ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៧ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់
- បានឃើញអនុក្រឹត្យលេខ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ១៦៧ អនក្រ.បក ចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ២០២១ ស្តីពីការកំណត់ចំនួនសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិទី៥
- យោងលទ្ធផលនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់នៅសង្កាត់**ចាក់អង្រែក្រោម** លេខកូដ **១២-០៦៣** នៃរាជធានីភ្នំពេញ (ទម្រង់បែបបទ១១១៨) របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ចុះថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០២២

## សម្រេច

**ប្រការ១.-**

ទទួលស្គាល់សមាសភាពជាប្រធានក្រុមប្រឹក្សាសង្កាត់ និងសមាជិកក្រុមប្រឹក្សាសង្កាត់**ចាក់អង្រែក្រោម ខណ្ឌមានជ័យ រាជធានីភ្នំពេញ** ដូចមានរាយនាមខាងក្រោម ៖

| | | | |
|---|---|---|---|
| ១- | លោក | ជា សុខៃ | ជាប្រធានក្រុមប្រឹក្សាសង្កាត់ |
| ២- | លោក | សេង ឈុនហេង | ជាសមាជិកក្រុមប្រឹក្សាសង្កាត់ |
| ៣- | លោក | នូ សេងហេង | ជាសមាជិកក្រុមប្រឹក្សាសង្កាត់ |
| ៤- | លោក | កែវ វេតនា | ជាសមាជិកក្រុមប្រឹក្សាសង្កាត់ |
| ៥- | លោកស្រី | លី ណារី | ជាសមាជិកក្រុមប្រឹក្សាសង្កាត់ |
| ៦- | លោក | ជា វង្សា | ជាសមាជិកក្រុមប្រឹក្សាសង្កាត់ |
| ៧- | លោកស្រី | អ៊ឹម ស៊ីផាត | ជាសមាជិកក្រុមប្រឹក្សាសង្កាត់ |
| ៨- | លោក | ជឹម សុរិទ្ធិ | ជាសមាជិកក្រុមប្រឹក្សាសង្កាត់ |
| ៩- | លោក | ហុង គីមហ័រ | ជាសមាជិកក្រុមប្រឹក្សាសង្កាត់ |
| ១០- | លោក | ហ៊ុល សំអឿន | ជាសមាជិកក្រុមប្រឹក្សាសង្កាត់ |
| ១១- | លោក | យិន ចាន់ដារិទ្ធ | ជាសមាជិកក្រុមប្រឹក្សាសង្កាត់។ |

**ប្រការ២.-**

ទទួលស្គាល់សមាសភាពជាចៅសង្កាត់ ចៅសង្កាត់រងទី១ និងចៅសង្កាត់រងទី២ នៃសង្កាត់**ចាក់អង្រែក្រោម ខណ្ឌមានជ័យ រាជធានីភ្នំពេញ** ដូចមានរាយនាមខាងក្រោម ៖

| | | | |
|---|---|---|---|
| ១- | លោក | ជា សុខៃ | ជាចៅសង្កាត់ |
| ២- | លោក | សេង ឈុនហេង | ជាចៅសង្កាត់រងទី១ |
| ៣- | លោក | នូ សេងហេង | ជាចៅសង្កាត់រងទី២។ |

**ប្រការ៣.-**

ការអនុវត្តការងារប្រធានក្រុមប្រឹក្សាសង្កាត់ ចៅសង្កាត់ ចៅសង្កាត់រង និងសមាជិកក្រុមប្រឹក្សាសង្កាត់ នៃសង្កាត់**ចាក់អង្រែក្រោម** ត្រូវអនុវត្តតាមរដ្ឋធម្មនុញ្ញ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានាជាធរមាន។

**ប្រការ៤.-**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៥.-**

ប្រកាសនេះ មានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

លេខ 8900

ថ្ងៃ ... ខែ ... ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី ... ខែ ... ឆ្នាំ២០២២

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**សម្តេចក្រឡាហោម ស ខេង**

**បានថតចំលងត្រឹមត្រូវតាមច្បាប់ដើម**
ខណ្ឌមានជ័យ,ថ្ងៃទី 04 JUL 2022
**អភិបាលរងគណៈអភិបាលខណ្ឌមានជ័យ**
**អភិបាលរង**
**មា_សុភាព**

**កន្លែងទទួល**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងមុខងារសាធារណៈ
- គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- អង្គភាពប្រឆាំងអំពើពុករលួយ
  "ដើម្បីជូនជ្រាប"
- រដ្ឋបាលរាជធានី ខណ្ឌ សង្កាត់ សាមី
- ដូចក្នុងប្រការ១
  "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

# ឧបសម្ព័ន្ធទី១៖
# ផែនទីសង្កាត់ចាក់អង្រែក្រោម

# ផែនទីព្រំប្រទល់រដ្ឋបាលខណ្ឌមានជ័យ



# ឧបសម្ព័ន្ធទី២៖

# កម្រងសំណួរការជួបសម្ភាសន៍ជាមួយសមាជិកក្រុមប្រឹក្សាសង្កាត់ចាក់អង្រែក្រោម

# ឧបសម្ព័ន្ធទី៣៖

# កម្រងរូបភាពជាមួយលោកចៅសង្កាត់ និងសមាជិកក្រុមប្រឹក្សាសង្កាត់ចាក់អង្រែក្រោម




ការថតរូបភាពជាមួយសមាជិកក្រុមប្រឹក្សាសង្កាត់ចាក់អង្រែក្រោម




កម្រងរូបភាពជាមួយលោកចៅសង្កាត់

